ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

## ប្រសិទ្ធភាពនៃការអនុវត្តការគ្រប់គ្រងតាមសាលារៀន (SBM)

## នៅមធ្យមសិក្សាបឋមភូមិ

## (ករណីសិក្សានៅរាជធានីភ្នំពេញ)

## Effect of Implementation School Based Management

## In Secondary School

## Case Study : Phnom Penh

**ដោយ/By**

**ហើល ម៉ូណូ**

**HELL MONO**

**ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦**

**ឆ្នាំសិក្សា ២០១៧-២០១៩**

**ឧបត្ថម្ភដោយៈ មូលនិធិគាំទ្រការអប់រំអន្តរជាតិនៅកម្ពុជា**

**Supported by Cambodia International Education Support Foundation (CIESF)**

ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education


# និក្ខេបបទ

## ប្រសិទ្ធភាពនៃការអនុវត្តការគ្រប់គ្រងតាមសាលារៀន (SBM)

## នៅមធ្យមសិក្សាបឋមភូមិ

## ( ករណីសិក្សានៅរាជធានីភ្នំពេញ )

## Effect of Implementation School Based Management In Secondary School

## Case Study : Phnom Penh


**ដោយ/By**

**ហ៊ែល ម៉ូណូ**

**HELL MONO**


**ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦**

**ឯកទេស៖ គ្រប់គ្រងអប់រំ**

**ឆ្នាំសិក្សា ២០១៧-២០១៩**


**សាស្ត្រាចារ្យដឹកនាំ៖** បណ្ឌិត ឌី ខាំបូលី

**សាស្ត្រាចារ្យដឹកនាំរង៖** ថៃ ហេង



ឧបត្ថម្ភដោយ៖ មូលនិធិគាំទ្រការអប់រំអន្តរជាតិនៅកម្ពុជា

Supported by Cambodia International Education Support Foundation ( CIESF )

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអប់រំ យុវជន និងកីឡា**

**លេខ:** ៩៧២៩ **អយក.** ប្រក

**(ការសម្ងាត់)**

### លិខិតឧទ្ទេសនាម

**យោង៖** -បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

-ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦ និងទី៧ ឆ្នាំសិក្សា២០១៨-២០១៩ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៨។

មន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារនិក្ខេបបទ** សម្រាប់ការការពារនិក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | |
|---|---|---|
| ១-ឯ.ឧ បណ្ឌិត ជ័យ សារិន | អគ្គាធិការដ្ឋាន | ប្រធាន |
| ២-ឯ.ឧបណ្ឌិត សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | អនុប្រធាន |
| ៣-ឯកឧត្តម លឹម សុធា | អគ្គនាយកដ្ឋានគោលនយោបាយនិងផែនការ | សមាជិក |
| ៤-លោកបណ្ឌិត នូវ វីរ៉ា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥-ឯកឧត្តម នៀ សុផន | នាយកដ្ឋានបុគ្គលិក | សមាជិក |
| ៦-លោកជំទាវបណ្ឌិត យូន វិច្ឆិកា | អគ្គនាយកដ្ឋានអប់រំ | សមាជិក |
| ៧-លោក ឌី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-ឯ.ឧបណ្ឌិត ម៉ុក សារ៉ុម | អគ្គនាយកដ្ឋានអប់រំ | សមាជិក |
| ៩-ឯ.ឧបណ្ឌិត ឌី ខាំបូលី | អគ្គនាយកដ្ឋានគោលនយោបាយ | សមាជិក |
| ១០-ឯ.ឧ បណ្ឌិត សិន សេងហុក | នាយកដ្ឋាននីតិកម្ម | សមាជិក |
| ១១-លោកបណ្ឌិត សិត សេង | វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ | សមាជិក |
| ១២-លោកបណ្ឌិត ឈូក ច័ន្ទឆាយា | នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ | សមាជិក |
| ១៣-លោកបណ្ឌិត នី រដ្ឋា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

ឯកឧត្តម លោកជំទាវ អស់លោក ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតនៅថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅនៅវិទ្យាស្ថានជាតិអប់រំ។ ៤

ថ្ងៃ សុក្រ ១ កើត ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែវិច្ឆិកា ឆ្នាំ២០១៩

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**
- អគ្គនាយដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីក្រសួងអយក
- គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ "ដើម្បីជ្រាបជាព័ត៌មាន"
- សាមីខ្លួន "ដើម្បីអនុវត្ត"
- កាលប្បវត្តិ - ឯកសារវិទ្យាស្ថានជាតិអប់រំ

# **សេចក្តីប្រកាសអះអាងរបស់បេក្ខជន**

ខ្ញុំបាទសូមបញ្ជាក់ថានិក្ខេបបទស្រាវជ្រាវដែលមានចំណងជើងថា “**ប្រសិទ្ធភាពនៃការអនុវត្តការគ្រប់គ្រងតាមសាលារៀន (SBM) នៅកម្រិតមធ្យមសិក្សាបឋមភូមិក្នុងរាជធានីភ្នំពេញ**” សម្រាប់បំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំគឺជាស្នាដៃសិក្សាស្រាវជ្រាវរបស់ខ្ញុំពិតប្រាកដមែន។ ស្នាដៃនេះមិនដែលបាន ប្រើប្រាស់ដើម្បីបំពេញលក្ខខណ្ឌសម្រាប់ទទួលសញ្ញាបត្រនៅវិទ្យាស្ថាន ឬសាកលវិទ្យាល័យណាមួយឡើយ ។ បន្ថែមលើនេះ ទៅទៀតរាល់សេចក្តីដកស្រង់និងខ្លឹមសារផ្សេងៗ ដែលបានយកមកប្រើប្រាស់ នៅក្នុងអត្ថបទនេះសុទ្ធតែ បានចុះបញ្ជីក្នុងឯកសារយោងទាំងអស់ ។ និក្ខេបបទស្រាវជ្រាវនេះ ពិតជាចងក្រងដោយខ្ញុំបាទផ្ទាល់ពិតប្រាកដមែន

ថ្ងៃ អង្គារ ១៤ កើត ខែ មិគសិរ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ២០១៩

ហត្ថលេខាបេក្ខជន

**ហ៊ើល ម៉ូណា**

# លិខិតបញ្ជាក់

| | | |
|---|---|---|
| ឯកឧត្តមបណ្ឌិត | **ឌី ខាំបូលី** | ជាសាស្ត្រាចារ្យដឹកនាំ |
| លោក | **ថៃ ហេង** | ជាសាស្ត្រាចារ្យដឹកនាំរង |

**សូមបញ្ជាក់ និងទទួលស្គាល់ថា**

**លោក ហ៊ើល ម៉ូណា** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦ ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវ "**ប្រសិទ្ធភាពនៃការអនុវត្ត ការគ្រប់គ្រងតាមសាលារៀន (SBM) នៅមធ្យម សិក្សាបឋមភូមិក្នុងរាជធានីភ្នំពេញ**" ពិតប្រាកដមែន។

ថ្ងៃ អង្គារ ១៤ កើត ខែ មិគសិរ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ២០១៩

| | |
|---|---|
| ...................................... | ...................................... |
| **បណ្ឌិត ឌី ខាំបូលី** | **លោក ថៃ ហេង** |
| អគ្គនាយករងនៃអគ្គនាយកដ្ឋានអប់រំ | អនុប្រធានដេប៉ាតឺម៉ង់គ្រប់គ្រង និងផែនការ |

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទ ហៃល ម៉ូណូ ជានិស្សិតថ្នាក់បិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦ នៃ វិទ្យាស្ថានជាតិអប់រំ ឆ្នាំសិក្សា២០១៧-២០១៩ ពិតជាមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែងដោយបានបញ្ចប់ការស្រាវជ្រាវថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ដោយជោគជ័យ។ ជាមួយលទ្ធផលដ៏ត្រចះត្រចង់នេះខ្ញុំបាទក៏មិនភ្លេចផងដែរចំពោះការជួយជ្រោមជ្រែង គាំទ្រ និងយកចិត្តទុកដាក់ពីសំណាក់មជ្ឈដ្ឋានជាច្រើន។

ខ្ញុំបាទសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ៖

លោកឪពុក អ្នកម្តាយ ដែលបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សា ផ្តល់ដំបូន្មាន និងការឧបត្ថម្ភ និងផ្តល់ឱកាសឱ្យខ្ញុំបានរៀនសូត្រ ទទួលបានផ្លែផ្កា ដូចសព្វថ្ងៃ។

គណៈកម្មការគ្រប់គ្រងការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ ព្រមទាំងលោកសាស្ត្រាចារ្យទាំងអស់ដែលបានចំណាយពេលដ៏មមាញឹក និងមានតម្លៃមកបង្ហាត់បង្រៀនដល់ខ្ញុំបាទដោយមិនគិតពីការនឿយហត់។

លោកបណ្ឌិត **ឌី ខាំបូលី** ដែលជាសាស្ត្រាចារ្យដឹកនាំ និងណែនាំ ដែលលោកតែងតែឆ្លៀតពេលដ៏មានតម្លៃរបស់លោក ក្នុងការផ្តល់គំនិតណែនាំជាពុទ្ធិ ទ្រឹស្តីល្អៗ និងផ្តល់កម្លាំងចិត្ត បញ្ញា ស្មារតី បច្ចេកទេស វិធីសាស្ត្រនានា មិនតែប៉ុណ្ណោះ លោកបានផ្តល់ ជាឯកសារ ដែលទាក់ទងនឹងប្រធានបទ ព្រមទាំងជួយបង្ហាញ ទិសដៅដល់រូបខ្ញុំរហូតការសិក្សាស្រាវជ្រាវនេះ ទទួលបាន ជោគជ័យជាស្ថាពរ ។

មិត្តរួមថ្នាក់ជំនាន់ទី៦ ទាំងអស់ដែលតែងតែផ្តល់កម្លាំងចិត្តដល់រូបខ្ញុំបាទ តាមរយៈចែករំលែកចំណេះដឹង បទពិសោធន៍ និងព័ត៌មានទាំងឡាយ ធ្វើឱ្យខ្ញុំបាទមានទឹកចិត្តតស៊ូ និងពុះពាររាល់ការលំបាក និងឧបសគ្គទាំងឡាយ ដើម្បីសម្រេចគោលដៅ ។

លោកនាយក នាយិកា លោកគ្រូ អ្នកគ្រូ សិស្សានុសិស្សតាមសាលាគោលដៅទាំងអស់ ដែលបានចូលរួមសម្របសម្រួល ឆ្លើយនូវកម្រងសំណួរ និងសហការក្នុងការចុះប្រមូលទិន្នន័យ ធ្វើឱ្យការសិក្សាស្រាវជ្រាវនេះទទួលបានជោគជ័យ។

ជាទីបញ្ចប់នេះខ្ញុំបាទ សូមគោរពជូនពរ និងប្រសិទ្ធពរ ជូនដល់ លោកអ្នកដ៏មានគុណទាំងពីរ ឯកឧត្តម លោកជំទាវ លោក លោកស្រី ថ្នាក់ដឹកនាំ ក្រសួងអប់រំ យុវជន និងកីឡា និងឯកឧត្តម លោក លោកជំទាវ លោក លោកស្រី តំណាងអង្គការ CIESF ឯកឧត្តមបណ្ឌិត សាស្ត្រាចារ្យជាតិ និងអន្តរជាតិ ទាំងអស់នៃវិទ្យាស្ថានជាតិអប់រំ សូមជួបប្រទះតែសេចក្តីសុខគ្រប់ប្រការ មានសុខភាពល្អបរិបូណ៌ សម្រេចជោគជ័យគ្រប់ភារកិច្ច និងទទួលបាននូវពុទ្ធពរទាំងបួនប្រការគឺៈ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាត ឡើយ។

# មូលន័យសង្ខេប

ការគ្រប់គ្រងតាមសាលារៀន ជាយន្តការដ៏មានប្រសិទ្ធភាពមួយក្នុងការអនុវត្តវិមជ្ឈការនៃការអប់រំដើម្បីធានាឱ្យសេវាអប់រំមានប្រសិទ្ធភាព។ ដោយយល់ឃើញថាការគ្រប់គ្រងតាមសាលារៀនមានសារៈសំខាន់បែបនេះ អ្នកសិក្សាស្រាវជ្រាវ បានជ្រើសរើសយកប្រធានបទស្តីពី " **ប្រសិទ្ធភាពនៃការអនុវត្តការគ្រប់គ្រងតាមសាលារៀន SBM នៅកម្រិតមធ្យមសិក្សាបឋមភូមិក្នុងរាជធានីភ្នំពេញ** " មកសិក្សាស្រាវជ្រាវ ។

ការសិក្សាស្រាវជ្រាវនេះ បានធ្វើឡើងនៅតាមវិទ្យាល័យចំនួនប្រាំពីរ ក្នុងរាជធានីភ្នំពេញដែលជាសាលាគោលដៅក្នុងការអនុវត្តការគ្រប់គ្រងតាមសាលារៀនSBM។ ការសិក្សាស្រាវជ្រាវនេះផ្តោតលើកម្រិតការអនុវត្តការគ្រប់គ្រងតាមសាលារៀននៅតាមវិទ្យាល័យគោលដៅទាំងប្រាំពីរក្នុងរាជធានីភ្នំពេញហើយធ្វើការប្រៀបធៀបទៅនឹងស្តង់ដាសាលាមានប្រសិទ្ធភាព ដោយមានគោលបំណងដើម្បីរកឱ្យឃើញកម្រិតនៃការអនុវត្តការគ្រប់គ្រងតាមសាលារៀនរបស់សាលាគោលដៅទាំងប្រាំពីរ និងបញ្ហាប្រឈមផ្សេងៗធៀបនឹងស្តង់ដាសាលាមានប្រសិទ្ធភាព។

អ្នកសិក្សាស្រាវជ្រាវបានប្រើប្រាស់ឧបករណ៍កម្រងសំណួរ ដើម្បីធ្វើការចុះប្រមូលទិន្នន័យបឋមនៅតាមសាលាគោលដៅទាំងប្រាំពីរ ដោយផ្តល់ជូននាយកសាលា៧នាក់ គ្រូបង្រៀន៥៧នាក់ សិស្ស១៥០នាក់ គណៈកម្មការគ្រប់គ្រងសាលារៀន និងសហគមន៍២១នាក់បំពេញ ព្រមទាំងមានការសម្ភាសន៍ផងដែរ។ ទិន្នន័យដែលប្រមូលបាន អ្នកសិក្សាស្រាវជ្រាវបានយកមកវិភាគតាមកម្មវិធី SPSS និងExel ដោយវិភាគតាម Frequencies And Descriptive ដោយបង្ហាញជាតារាងស្ថិតិ និងដ្យាក្រាម ។

ការសិក្សាស្រាវជ្រាវនេះបានរកឃើញថា ការអនុវត្តការគ្រប់គ្រងតាមសាលារៀននៅកម្រិតមធ្យមសិក្សាបឋមភូមិក្នុងរាជធានីភ្នំពេញមិនទាន់មានប្រសិទ្ធភាពនៅឡើយទេ ដោយសាលាគោលដៅទាំងប្រាំ ពីរក្នុងរាជធានីភ្នំពេញបំពេញមិនទាន់បាននូវស្តង់ដាសាលាមានប្រសិទ្ធភាព។ ចំពោះបញ្ហាប្រឈមនៃការអនុវត្តការគ្រប់គ្រងតាមសាលារៀននៅកម្រិតមធ្យមសិក្សាបឋមភូមិក្នុងរាជធានីភ្នំពេញ ជារួមគឺផ្នែកអំណាន របស់សិស្សនៅមានកម្រិតនៅឡើយ សិស្សត្រួតថ្នាក់,សិស្សបោះបង់នៅមានកម្រិតនៅឡើយសម្រាប់កម្រិតមធ្យមសិក្សាបឋមភូមិ ខ្វះគ្រូឯកទេសផ្នែកព័ត៌មានវិទ្យា គ្រូមិនប្រើប្រាស់សម្ភារៈឧបទ្ទេសក្នុងម៉ោងបង្រៀនគ្រូប្រើប្រាស់កិច្ចតែងការក្នុងម៉ោងបង្រៀននៅមានកម្រិត សិស្សអវត្តមានក្នុងម៉ោងសិក្សានៅមានកម្រិតមធ្យម ក្លឹបសិក្សាពុំមានដំណើរការលើសេវាសិស្សជួយសិស្ស ខ្វះការចូលរួមជំរុញពីមាតាបិតាលើការសិក្សារបស់កូន ខ្វះការជំរុញសិស្សអោយប្រើប្រាស់បណ្ណាល័យ ប្រើប្រាស់បន្ទប់ពិសោធន៍ និងការប្រើប្រាស់កុំព្យូទ័រ ខ្វះការចុះពិនិត្យតាមដានរបស់ថ្នាក់លើក្នុងការអនុវត្តការគ្រប់គ្រងតាមសាលារៀននៅមានកម្រិតទាបនៅឡើយ។

# Abstract

School-Based management is an effective mechanism for implementing decentralization of education to ensure effective education services. Knowing the importance of such school-based management, the researcher chose the topic “Effectiveness of Implementing School-Based Management (SBM) in Lower Secondary Schools in Phnom Penh”.

The study was conducted at seven high schools in Phnom Penh which are the target schools implementing school-based manangement (SBM). This study focuses on the levels of school-based management implementation at target schools in Phnom Penh and compares them to effective school standards with the aim of discovering the levels of SBM implementation and other facing problems comparing to effective school stardards.

The researcher used questionnaires to collect primary data at seven target schools by providing them to 7 principals, 57 teachers, 150 students, and 21 community management committees, as well as interviews. The researcher analyzed data collected by SPSS and Exel using Frequency And Descriptive by presenting with statistical tables and diagrams.

The study found that the implementation of school-based management in lower secondary schools in Phnom Penh was not effective, because the seven target schools in Phnom Penh have failed to meet effective school standards. The facing problems in implementing school-based management in lower secondary schools in Phnom Penh are reading understanding with limitation, students’ repetition, student dropout with limitation in the secondary level, lack of ICT teachers, teaching without using enough study materials, using lesson plans with limitation in teaching, students’ absences during studying with medium level, study clubs not working on students helping students, lack of encouraging from parents, lack of encouraging students to come to library, laboratory, and ICT rooms, lack of checking and evaluating from the top ranking on target school-based management implementation.

## មាតិកា

សេចក្តីប្រកាសអះអាងរបស់បេក្ខជន....................i
លិខិតបញ្ជាក់....................ii
សេចក្តីថ្លែងអំណរគុណ....................iii
មូលន័យសង្ខេប....................iv
Abstract....................v

**ជំពូកទី១**

**សេចក្តីផ្តើម**

**១.១ លំនាំបញ្ហានៃការស្រាវជ្រាវ**....................១
**១.២ ចំណោទបញ្ហាស្រាវជ្រាវ**....................២
**១.៣ គោលបំណងនៃការស្រាវជ្រាវ**....................៤
**១.៤. សំណួរស្រាវជ្រាវ**....................៤
**១.៥ ដែនកំណត់នៃការស្រាវជ្រាវ**.................... ៤
**១.៦ សារៈសំខាន់នៃការស្រាវជ្រាវ** .................... ៥
**១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ** .................... ៥

**ជំពូកទី២**7

**រំលឹកទ្រឹស្តី**7

**២.១ វិមជ្ឈការនៃការអប់រំនៅក្នុងបរិបទកម្ពុជា** ....................7
**២.២ ទស្សនាទានរួមស្តីពីការគ្រប់គ្រងតាមសាលារៀន** (SBM) ....................8
**២.៣ ទស្សនៈផ្សេងៗលើការគ្រប់គ្រងតាមសាលារៀន** (SBM)....................9
**២.៣.១ កត្តាចាំបាច់សម្រាប់អនុវត្តការគ្រប់គ្រងតាមសាលារៀន** (SBM) **នៅកម្ពុជា**....................10
**២.៤ បទពិសោធន៍ការគ្រប់គ្រងតាមសាលារៀន** (SBM) **នៅកម្ពុជា** ....................13

២.៥ សមាសភាគទាំង៤នៃការគ្រប់គ្រងតាមសាលារៀន (SBM)............................14
២.៥.១ ការគ្រប់គ្រងរដ្ឋបាលសាលារៀន ..............................................................................15
២.៥.២ ការគ្រប់គ្រងការរៀន និងការបង្រៀន........................................................................16
២.៥.៣ ការគ្រប់គ្រងធនធានមនុស្ស ......................................................................................17
២.៥.៤ ការគ្រប់គ្រងហិរញ្ញវត្ថុ.............................................................................................18
២.៦ ស្តង់ដារទាំង៩ស្តីពីប្រសិទ្ធភាពការគ្រប់គ្រងតាមសាលារៀន ៖ .......................19
២.៦.១ វត្ថុបំណងគោលនយោបាយសាលារៀន.......................................................................20
២.៦.២ ការបង្រៀន និងបំណែងចែកកម្មវិធីបង្រៀន...............................................................20
២.៦.៣ មាតាបិតា និងសហគមន៍ជួយដល់ការរៀនសូត្រ .........................................................21
២.៦.៤ សិស្ស និងសេវាជួយសិស្ស.........................................................................................23
២.៦.៥ ការដឹកនាំ និងគ្រប់គ្រង ...........................................................................................24
២.៦.៦ ធនធានមនុស្ស ៖........................................................................................................25
២.៦.៧ សៀវភៅសិក្សាគោល និងសម្ភារៈបង្រៀន និងរៀន.......................................................27
២.៦.៨ ហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថានសាលារៀន................................................................29
២.៦.៩ ហិរញ្ញប្បទាន និងការគ្រប់គ្រងហិរញ្ញវត្ថុ .....................................................................30
ជំពូកទី៣ ....................................................................................................................33
វិធីសាស្ត្រនៃការស្រាវជ្រាវ...........................................................................................33
៣.១ ព័ត៌មានទូទៅនៃគម្រោងស្រាវជ្រាវ.........................................................................33
ការស្រាវជ្រាវនេះ ត្រូវបានរៀបចំធ្វើឡើងដោយប្រើទិន្នន័យបរិមាណវិស័យ និងគុណវិស័យដែល បានយកមកវិភាគ ដើម្បីស្វែងយល់ពីប្រសិទ្ធភាពនៃការអនុវត្តការគ្រប់គ្រងតាមសាលារៀននៅ មធ្យមសិក្សាបឋមភូមិនៅតាមគ្រឹះស្ថានសិក្សាដែលជាគោលដៅនៃការស្រាវជ្រាវលើប្រធានបទ នេះ ។..........................................................................................................................33
៣.២ ទីកន្លែងសិក្សាស្រាវជ្រាវ..........................................................................................33

ការសិក្សានេះជ្រើសរើសយករាជធានីភ្នំពេញជាទីតាំងសម្រាប់ធ្វើការប្រមូលទិន្នន័យ ។ ដូចដែលបានរៀបរាប់ក្នុងជំពូកទី១ខាងលើ ការស្រាវជ្រាវនេះមានវត្ថុបំណងសំខាន់ៗចំនួនពីរគឺ ៖ ..... 33
**៣.៣ ការជ្រើសរើសសំណាក** ..... 33
**៣.៤ ឧបករណ៍ស្រាវជ្រាវ** ..... 34
**៣.៥. កម្រងសំណួរ និងគោលបំណងនៃកម្រងសំណួរ** ..... 34
**៣.៥.១ កម្រងសំណួរសម្រាប់នាយក** ..... 34
(៦) ហិរញ្ញប្បទាន និងការគ្រប់គ្រងហិរញ្ញវត្ថុ ..... 35
ខ. កម្រងសំណួរសម្រាប់សម្ភាស គឺចង់វាស់ស្ទង់មតិរបស់លោកនាយកពីការអនុវត្តការ ..... 35
គ្រប់គ្រងតាមសាលារៀន ធៀបទៅនឹងស្តង់ដាសាលាមានប្រសិទ្ធភាព ។ ..... 35
**៣.៥.២ កម្រងសំណួរសម្រាប់គ្រូ** ..... 35
**៣.៥.៣ កម្រងសំណួរសម្រាប់សិស្ស** ..... 35
**៣.៥.៤ កម្រងសំណួរសម្រាប់សហគមន៍ និងគណៈកម្មការគ្រប់គ្រងសាលារៀន** ..... 35
**៣.៦ ដំណើរការប្រមូលទិន្នន័យ** ..... 36
**៣.៧ ការវិភាគទិន្នន័យ** ..... 36
**៣.៨ ក្រមសីលធម៌នៃការស្រាវជ្រាវ** ..... 36
**ជំពូកទី៤** ..... 38
**លទ្ធផលនៃការស្រាវជ្រាវ និងការពិភាក្សា** ..... 38
**៤.១ លទ្ធនៃការសិក្សាស្រាវជ្រាវ** ..... 38
**៤.១.១ អ្នកចូលរួមក្នុងការផ្តល់ព័ត៌មានក្នុងការស្រាវជ្រាវ** ..... 38
**៤.១.២ ប្រសិទ្ធភាពនៃការអនុវត្តការគ្រប់គ្រងតាមសាលារៀន** (SMB) ..... 40
**៤.២ ការពិភាក្សា** ..... 58

ក- ចំណុចវិជ្ជមានលើការអនុវត្តការគ្រប់គ្រងតាមសាលារៀន (SBM) - វត្ថុបំណងគោលនយោបាយសាលារៀនមានចំណុចល្អ បំពេញបាននូវស្តង់ដាធៀបទៅនឹងស្តង់ដាសាលាមានប្រសិទ្ធភាព ។ 58

ខ- បញ្ហាប្រឈមលើការអនុវត្តការគ្រប់គ្រងតាមសាលារៀន (SBM) ........................................58

**ជំពូកទី៥**....................................................................................................63

**សេចក្តីសន្និដ្ឋាន និងសំណូមពរ**....................................................................63

**៥.១ សេចក្តីសន្និដ្ឋាន** .....................................................................................63

**៥.២ សំណូមពរ**...............................................................................................66

**ឯកសារយោង** ................................................................................................68

**ឧបសម្ព័ន្ធ១**....................................................................................................69

**ឧបសម្ព័ន្ធ២**..................................................................................................lxix

# ជំពូកទី១

# សេចក្តីផ្តើម

# ជំពូកទី១
# សេចក្តីផ្តើម
## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

ប្រទេសកម្ពុជាជាប្រទេសមួយដែលបានឆ្លងកាត់សង្រ្គាមជាញឹកញាប់។ ក្នុងរបបខ្មែរក្រហមបានបំផ្លិចបំផ្លាញវប្បធម៌ខ្មែរ ហេដ្ឋារចនាសម្ព័ន្ធ បំបាត់មិនឱ្យមានវត្តអារាម សាលារៀន ទំនៀមទំលាប់រៀបអាពាហ៍ពិពាហ៍ ការបង្ខំមនុស្សឱ្យធ្វើការលើសកម្លាំង ការកាប់សម្លាប់មនុស្សយ៉ាងព្រៃផ្សៃ។ តែក្រោយសម័យរំដោះ៧មករា ឆ្នាំ១៩៧៩ មកសេដ្ឋកិច្ចប្រទេសជាតិ និងវប្បធម៌ខ្មែរត្រូវបានស្តារឡើងវិញជាបន្តបន្ទាប់។ សព្វថ្ងៃរាជរដ្ឋាភិបាល បានយកចិត្តទុកដាក់អភិវឌ្ឍន៍ប្រទេសជាតិឡើងវិញដោយបានបង្កើតយុទ្ធសាស្ត្រចតុកោណនីតិកាលទី៥ ដំណាក់កាលទី៣ ដែលចតុកោណទាំងបួននោះ គឺមានចតុកោណទី១ ការលើកស្ទួយវិស័យកសិកម្ម ចតុកោណទី២ការអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ចតុកោណទី៣ការអភិវឌ្ឍវិស័យឯកជននិងការងារ និងចតុកោណទី៤ ការកសាងសមត្ថភាព និងការអភិវឌ្ឍធនធានមនុស្ស (សម្តេច ហ៊ុន សែន ឆ្នាំ២០១៣)។ ស្របជាមួយចតុកោណទីបួនខាងលើ ក្រសួងអប់រំបានបង្កើតផែនការយុទ្ធ-សាស្ត្រវិស័យអប់រំ (២០១៤–២០១៨) បានកំណត់គោលនយោបាយចំនួន៣គឺ (១)ធានាលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌ (២)លើកកម្ពស់គុណភាព និងប្រសិទ្ធភាពសេវាអប់រំ (៣) អភិវឌ្ឍស្ថាប័ន និងអភិវឌ្ឍសមត្ថភាពមន្ត្រីអប់រំសម្រាប់ធ្វើវិមជ្ឈការ[1]។ ក្នុងនេះដែរក្រសួងអប់រំ យុវជន និងកីឡា បានសម្រេចថាគុណភាពអប់រំជាគោលនយោបាយអាទិភាពសម្រាប់កម្រិតនៃការអប់រំ ហើយគុណភាពអប់រំនឹងដើរតួនាទីជាយុទ្ធសាស្ត្រធ្វើឱ្យកើនឡើងនូវការចូលរៀនរបស់សិស្ស។ ដើម្បីធានាបាននូវផែនការយុទ្ធសាស្ត្រខាងលើ ថ្នាក់ដឹកនាំក្រសួងអប់ យុវជន និងកីឡា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានបំណងធ្វើឱ្យសាលារៀនក្លាយជាកន្លែងផ្តល់សេវាអប់រំប្រកបដោយគុណភាព បរិយាបន្ន័ ប្រសិទ្ធភាព និងលើកកម្ពស់ការអប់រំពេញមួយជីវិតសម្រាប់ទាំងអស់គ្នា តាមរយៈការអនុវត្តការគ្រប់គ្រងតាមសាលារៀន។ ការគ្រប់គ្រងតាមសាលារៀនមានគោលបំណងពីរគឺ (១)រៀបចំសាលារៀនឱ្យបំពេញបាននូវស្តង់ដារសាលារៀនមានប្រសិទ្ធភាព ដោយការកសាងសមត្ថភាពដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងសាលារៀន ដើម្បីធានាថាការគាំទ្រត្រូវបានផ្តល់ឱ្យសាលារៀនទាន់ពេលវេលា និង(២) កសាងមសត្ថភាពគ្រូបង្រៀនដើម្បីអនុវត្តកម្មវិធីសិក្សារបស់ជាតិ។ ដើម្បីសម្រេចបាននូវគោលបំណងទាំងពីរខាងលើនេះមានសកម្មភាពចំនួន៣ដែលត្រូវអនុវត្តៈ ១- ពង្រឹងការគ្រប់គ្រងតាមសាលារៀន ២- បំប៉នបន្ថែម និងផ្តល់ការគាំទ្រផ្ទាល់ដល់គ្រូបង្រៀន ៣- សាងសង់និងកែលម្អអគារសិក្សា និងបរិស្ថានសិក្សា[2]។

ម្យ៉ាងវិញទៀត នៅក្នុងផែនការអភិវឌ្ឍជាតិឆ្នាំ ២០១៤-២០១៨ ក៏ដូចជាផែនការយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ក៏បានផ្តោតយកចិត្តទុកដាក់សំខាន់លើការកសាងសមត្ថភាពនិងការអភិវឌ្ឍធនធានមនុស្សរួមមានៈ ការពង្រឹងគុណភាពវិស័យអប់រំ

[1] ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០១៤-២០១៨ (ទំព័រទី៣)
[2] សៀវភៅណែនាំប្រតិបត្តិស្តីពីការគ្រប់គ្រងតាមសាលារៀន (ទំព័រទី៥)

វិទ្យាសាស្ត្រនិងបច្ចេកទេស ការបណ្តុះបណ្តាលជំនាញបច្ចេកទេស ហើយក៏បានចាត់ទុកវិស័យអប់រំជាវិស័យអាទិភាពមួយក្នុងចំណោមវិស័យអាទិភាពដទៃទៀត ដែលអាចកសាងធនធានមនុស្សមួយដែលពោរពេញដោយសមត្ថភាព និងជំនាញច្បាស់លាស់ ដើម្បីចូលរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចសង្គមកម្ពុជាឱ្យមានការរីកចម្រើនប្រកបដោយចីរភាព និងមានភាពជឿនលឿនកាន់តែឆាប់រហ័សនាពេលអនាគតយ៉ាងខ្លី **(RGC, 2014-2018)**។

ដោយសារបញ្ហាប្រឈមថ្មីៗ ភាពស្មុគស្មាញ និងការប្រកួតប្រជែងដែលបណ្តាលមកពីការបង្កើតថ្មីនៃបច្ចេកវិទ្យានិងវិទ្យាសាស្ត្រផ្លាស់ប្តូរនយោបាយនិងសេដ្ឋកិច្ច និងការផ្លាស់ប្តូរសង្គមសាលារៀនត្រូវមានតម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាព។ អភិបាលកិច្ចសាលារៀន និងការសម្រេចចិត្តត្រូវមានការផ្លាស់ប្តូរដើម្បីឆ្លើយតបនឹងស្ថានភាព **(Sackney and Dibski, 1995)**។ ការបង្កើតសិទ្ធិសម្រេចចិត្តកាន់តែធំត្រូវបានបែងចែកដល់អ្នកពាក់ព័ន្ធក្នុងវិស័យអប់រំក្នុងស្រុករួមទាំងនាយកសាលា គ្រូបង្រៀន ឪពុកម្តាយ និងសមាជិកសហគមន៍ដើម្បីកំណត់នូវយុទ្ធសាស្ត្រដែលឆ្លើយតបបានល្អបំផុតចំពោះកុមារ**(Gamage and Zajda,2009)**។ យុទ្ធសាស្ត្រកំណែទម្រង់ថ្មីនេះត្រូវបានគេហៅថាការគ្រប់គ្រងតាមសាលារៀន ដែលប្រតិបត្តិការសាលារៀនស្ថិតនៅក្នុងដៃរបស់អ្នកពាក់ព័ន្ធក្នុងមូលដ្ឋាន ប៉ុន្តែពួកគេត្រូវគោរពតាមក្របខណ្ឌនៃគោលនយោបាយ ឬបទបញ្ញត្តិ **(Caldwell, 2005)**។

ថ្វីបើការគ្រប់គ្រងតាមសាលារៀនដែលត្រូវបានបង្កើតឡើងតាំងពីទសវត្សឆ្នាំ១៩៦០ ក៏ដោយតែថ្មីៗនេះបានក្លាយទៅជាចំណុចស្នូលនៃរលកកំណែទម្រង់ការអប់រំ **( Sackneyand Diski, 1995)**។ ដោយមានការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុពីធនាគារពិភពលោកប្រទេសកម្ពុជាបានណែនាំកម្មវិធីគ្រប់គ្រងតាមសាលារៀន ដែលមានឈ្មោះថាគម្រោងកែលម្អគុណភាពអប់រំ (EQIP) ចាប់តាំងពីឆ្នាំ១៩៩៨ (ធនាគារពិភពលោកឆ្នាំ១៩៩៩)។ គោលបំណងចម្បងនៃកម្មវិធីនេះ គឺដើម្បីលើកកម្ពស់គុណភាពនៃការអប់រំមូលដ្ឋានតាមរយៈ «វិធីសាស្ត្រសម្រេចចិត្តចូលរួម»។ កម្មវិធីនេះបានស្វែងរកការកែលំអផែនការ និងបែងចែកធនធានដែលខ្វះខាត **( Pellini, 2007)** និងដើម្បីកាត់បន្ថយបន្ទុកចំណាយទៅលើគ្រួសារក្រីក្របំផុតដើម្បីកាត់បន្ថយការបោះបង់ការសិក្សារបស់កុមារនៅក្នុងការអប់រំមូលដ្ឋាន។ លោក **Shoraku** (ឆ្នាំ ២០០៨) បានកត់សម្គាល់ថាកម្មវិធីនេះបានរួមចំណែកយ៉ាងសំខាន់ក្នុងការសំរេចគោលដៅ អប់រំសម្រាប់ទាំងគ្នា (EFA) និងគោលដៅអភិវឌ្ឍសហស្សវត្ស (MDG) សម្រាប់ការអប់រំនៅកម្ពុជា ។

## ១.២ ចំណោទបញ្ហាស្រាវជ្រាវ

ការគ្រប់គ្រងតាមសាលារៀន (SBM) បានក្លាយជាចំណុចសំខាន់បំផុតនៃប្រព័ន្ធគ្រង់គ្រងសាលារៀនសាធារណៈនៅក្នុងប្រទេសភាគច្រើននៅជុំវិញពិភពលោក។ បណ្តាប្រទេសជាច្រើនបានធ្វើការសាកល្បង ឬណែនាំពីកំណែទម្រង់ការគ្រប់គ្រងតាមសាលារៀន (SBM) រួមមានដូចជាប្រទេសអូស្ត្រាលី ប្រទេសកាណាដា សហរដ្ឋអាមេរិច ប្រេស៊ីល អេស្ប៉ាញ ចក្រភពអង់គ្លេស និងនូវែលសេឡង់ **(World Bank,2007)**។ បណ្តាលប្រទេសមួយចំនួនផ្សេងទៀតបានខិតខំប្រឹងប្រែងឆ្ពោះទៅរកការប្រើប្រាស់គំរូនេះ **(World Bank, 2007)**។ ប្រទេសកម្ពុជា គឺជាប្រទេសមួយក្នុងចំណោមពួកគេដែលពឹងផ្អែកលើការគ្រប់គ្រងសាលារៀនក្នុងស្រុកតាមរយៈការអនុវត្តវិមជ្ឈការតាមវិស័យអប់រំ។

ការអនុវត្តការគ្រប់គ្រងតាមសាលារៀនក៏បានចាប់ផ្ដើមអនុវត្តនៅតាមបណ្ដាលប្រទេសមួយចំនួននៅអាស៊ីផងដែរគឺនៅចន្លោះទសវតស្សឆ្នាំ ១៩៩០ និងដើមឆ្នាំ២០០០ ដែលក្នុងនោះមានដូចជា (១)ឆ្នាំ១៩៩១ ហុងកុង (២)ឆ្នាំ១៩៩៧ ប្រទេសថៃ (៣)ឆ្នាំ១៩៩៨ ប្រទេសកម្ពុជា (៤)ឆ្នាំ១៩៩៩ ប្រទេសឥណ្ឌូណេស៊ី និងឆ្នាំ២០០១ ប្រទេសហ្វីលីពីន។ ការចាប់ផ្ដើមអនុវត្តការគ្រប់គ្រងតាមសាលារៀននេះ គឺមានទំនាក់ទំនងទៅនឹងការលើកទឹកចិត្តខាងហិរញ្ញវត្ថុ និងនយោបាយ **(Ai Shoraku and Tonegawa 2016)**។

ដោយមានការគាំទ្រផ្នែកបច្ចេកទេស និងផ្នែកហិរញ្ញវត្ថុពីធនាគារពិភពលោកប្រទេសកម្ពុជាបានណែនាំកម្មវិធីគ្រង់គ្រងតាមសាលារៀនដែលមានឈ្មោះថាគម្រោងកែលម្អគុណភាពអប់រំ **(EQIP)** ចាប់ផ្ដើមពីឆ្នាំ១៩៩៨ **(World Bank, 1999)**។ គោលបំណងចម្បងនៃកម្មវិធីនេះគឺ ដើម្បីលើកកម្ពស់គុណភាពនៃការអប់រំមូលដ្ឋានតាមរយៈវិធីសាស្រ្តសម្រេចចិត្តរួម។ កម្មវិធីនេះបានស្វែងរកការកែលម្អផែនការ និងបែងចែកធនធានដែលខ្វះខាត **(Pellini, 2007)** និងដើម្បីកាត់បន្ថយបន្ទុកចំណាយទៅលើគ្រួសារក្រីក្របំផុតដើម្បីកាត់បន្ថយការបោះបង់ការសិក្សា របស់កុមារនៅក្នុងការអប់រំមូលដ្ឋាន។ **Soraku (2008)** បាត់កត់សម្គាល់ថាកម្មវិធីនេះបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការសំរេចគោលដៅអប់រំសម្រាប់ទាំងអស់គ្នា **(EFA)** និងគោលដៅអភិវឌ្ឍសហវត្ស **(MDG)** សម្រាប់អប់រំនៅកម្ពុជា។ នៅក្នុងផែនការយុទ្ធសាស្រ្តវិស័យអប់រំ (២០១៤-២០១៨) បានកំណត់គោលនយោបាយចំនួន៣ ដែលក្នុងនេះគោលនយោបាយទី៣ គឺពាក់ព័ន្ធជាមួយនឹងការអភិវឌ្ឍស្ថាប័ន និងអភិវឌ្ឍសមត្ថភាពមន្ត្រីអប់រំសម្រាប់ធ្វើវិមជ្ឈការ។ ក្នុងនេះដែរដើម្បីសំរេចអោយបាននូវគោលនយោបាយនេះ ក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុមានបំណងធ្វើឱ្យសាលារៀនក្លាយជាកន្លែងផ្ដល់សេវាអប់រំដែលប្រកបដោយគុណភាព បរិយាប័ន្ន ប្រសិទ្ធភាព និងលើកកម្ពស់ការអប់រំពេញមួយជីវិតសម្រាប់ទាំងអស់គ្នា តាមរយៈការអនុវត្តការគ្រប់គ្រងតាមសាលារៀន។

ការគ្រប់គ្រងតាមសាលារៀនជាយន្តការដ៏មានប្រសិទ្ធភាពមួយក្នុងការអនុវត្តវិមជ្ឈការនៃការអប់រំដើម្បីធានាឱ្យសេវាអប់រំមានប្រសិទ្ធភាពខ្ពស់។ ការគ្រប់គ្រងតាមសាលារៀនត្រូវបានចាត់ទុកជាវិធី (១) ការប្រកួតប្រជែង ការរក្សា ការពិនិត្យនិតុល្យភាពផ្ទៃក្នុងរបស់ ក្រសួងអប់រំ យុវជន និងកីឡា រួមមានការផ្ដល់ធនធាន សិទ្ធអំណាច និងការកសាងសមត្ថភាពដើម្បីបង្កើនលទ្ធផលសិក្សា (២)ធ្វើឱ្យក្រសួងអប់រំ យុវជន និងកីឡា អាចឆ្លើយតបបានច្រើនជាងមុនក្នុងការផ្ដល់សេវាអប់រំនៅសាលារៀន និងក្នុងការដោះស្រាយបញ្ហាបានទាន់ពេល និងមានប្រសិទ្ធភាពខ្ពស់ (៣)កាត់បន្ថយភាពតានតឹងសង្គម និងនយោបាយ និងធានាបាននូវស្វ័យភាព និងតម្លាភាពមូលដ្ឋាន ដោយសារតែសារធារណជនបានរួមចំណែកទទួលខុសត្រូវ និងដោះស្រាយបញ្ហាជាមួយរដ្ឋ។ ក្នុងន័យនេះការគ្រប់គ្រងតាមសាលារៀន គឺជាការផ្ដល់ស្វ័យភាពក្នុងការសម្រេចចិត្តទៅកម្រិតមូលដ្ឋាន ដោយផ្អែកលើលទ្ធផលនៃការអនុវត្តការងាររបស់សាលារៀន និងលទ្ធផលសិក្សារបស់សិស្ស។ ប្រការនេះជាជំហរអនុវត្តនូវការសម្រេចចិត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាដើម្បីឱ្យសាលារៀនទាំងអស់អាចសម្រេចទទួលបាននូវស្តង់ដាទាំង៩ ស្ដីពីសាលារៀនមានប្រសិទ្ធភាព[3] ។

ថ្វីបើមានការអនុវត្តយ៉ាងទូលំទូលាយនៃការគ្រប់គ្រងតាមសាលារៀននៅកម្ពុជាក៏ដោយ ក៏គោលនយោបាយវិមជ្ឈការថ្នាក់ជាតិ ដែលគ្រប់គ្រងដោយសាលារៀនមិនត្រូវបានកំណត់ឱ្យបានច្បាស់លាស់ទេ។

[3] សៀវភៅណែនាំប្រតិបត្តិស្ដីពីការគ្រប់គ្រងតាមសាលារៀនសម្រាប់មធ្យមសិក្សា

អាជ្ញាធរដែលធ្វើការសម្រេចចិត្តត្រូវបានផ្ទេរមន្ត្រីថ្នាក់ក្រោមជាតិទៅកម្រិតសាលារៀននៅតែមិនមានភាពច្បាស់លាស់ហើយការចូលរួមរបស់អ្នកពាក់ព័ន្ធក្នុងមូលដ្ឋាន ក្នុងការធ្វើសេចក្តីសំរេចគឺមិនច្បាស់លាស់ **(Samith, 2003)**។ ភាពមិនច្បាស់លាស់នេះនាំឱ្យមានការធ្លាក់ចុះនៃការគ្រប់គ្រងរបស់សាលារៀន និងមិនមានសក្តានុពលផលិតកម្ម **(Wohlstetter and Odden, 1992)**។ លើសពីនេះទៀតការយល់ច្រឡំ និងភាពតានតឹងរវាងកម្រិតថ្នាក់ក្រោមជាតិ និងថ្នាក់មូលដ្ឋានទំនងជាកើតឡើង។ **Chapman(2002)** បានសង្កត់ធ្ងន់ថានៅពេលដែលបន្ទាត់នៃការទទួលខុសត្រូវ និងសិទ្ធអំណាចសម្រាប់ការគ្រប់គ្រងអប់រំមានការយល់ច្រឡំការគ្រប់គ្រងទន់ខ្សោយ និងភាពអន់ថយនៃការអប់រំអាចកើតឡើង។ ត្រង់ចំណុចនេះហើយទាមទារឱ្យមានការសិក្សាស្រាវជ្រាវបន្ថែមទៀតដោយធ្វើការសិក្សាស្រាវជ្រាវផ្អែកលើប្រសិទ្ធភាពនៃការអនុវត្តការគ្រប់គ្រងតាមសាលារៀន (SBM) នៅកម្រិតមធ្យមសិក្សាបឋមភូមិ។

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះមានគោលបំណងសំខាន់គឺ៖

(១) សិក្សាពីប្រសិទ្ធភាពការអនុវត្តការគ្រង់គ្រងតាមសាលារៀន (SBM) លើកម្រិតមធ្យមសិក្សាបឋមភូមិ។

## ១.៤. សំណួរស្រាវជ្រាវ

សំនួរនៃការស្រាវជ្រាវសម្រាប់ការសិក្សានេះគឺ៖

១- តើប្រសិទ្ធភាពនៃការអនុវត្តការគ្រប់គ្រងតាមសាលារៀន (SBM) នៅកម្រិតមធ្យមសិក្សាបឋមភូមិក្នុងរាជធានីភ្នំពេញស្ថិតក្នុងកម្រិតណា ?

## ១.៥ ដែនកំណត់នៃការស្រាវជ្រាវ

អាស្រ័យដោយពេលវេលាឯកសារដែលពាក់ព័ន្ធនឹងការស្រាវជ្រាវពិបាករក ធនធានមានកំណត់ និងដោយសារកង្វះលទ្ធភាពក្នុងការចុះប្រមូលទិន្នន័យឱ្យបានគ្រប់វិទ្យាល័យទូទាំងប្រទេស ដែលត្រូវការចំណាយថវិកាច្រើនដូចនេះការសិក្សាស្រាវជ្រាវនេះ នឹងផ្តោតលើវិទ្យាល័យមួយចំនួនក្នុងរាជធានីភ្នំពេញប៉ុណ្ណោះ។ ការស្រាវជ្រាវនេះផ្តោតទៅលើ នាយក គ្រូបង្រៀន សិស្ស និងគណៈគ្រប់គ្រងសាលារៀន និងប្រជាជន។ ភាគ-សំណាកទាំងអស់ នឹងត្រូវជ្រើសរើសយកវិទ្យាល័យចំនួន៧ នៃខណ្ឌចំនួន៦ ក្នុងរាជធានីភ្នំពេញដើម្បីស្រាវជ្រាវ។ វិទ្យាល័យដែលបានចុះស្រាវជ្រាវក្នុងនោះរួមមាន វិទ្យាល័យបាក់ទូក វិទ្យាលជាស៊ីមជ្រោយចង្វារ វិទ្យាល័យទួលប្រាសាទសែនសុខ វិទ្យាល័យកោះដាច់ វិទ្យាល័យព្រែកឯង វិទ្យាល័យចាក់អង្រែ និងវិទ្យាល័យឬស្សីកែវ។ អ្នកស្រាវជ្រាវនឹងសិក្សាស្រាវជ្រាវដោយរៀបចំតាក់តែងកម្រងសំណួរសម្រាប់បំពេញ និងធ្វើការសម្ភាសសហគមន៍ គណៈកម្មការគ្រប់គ្រងសាលារៀន គ្រូ សិស្ស នាយកនៅតាមសាលានីមួយៗ។ ការសម្ភាសផ្តោតលើសមាសភាគទាំងប្រាំបួននៃស្តង់សាលាមានប្រសិទ្ធភាពមធ្យមសិក្សាដែលរួមមាន **សមាសភាគទី១** វត្ថុបំណងគោលនយោបាយសាលារៀន **សមាសភាគទី២** ការបង្រៀន និងបំណែងចែកកម្មវិធីបង្រៀន **សមាសភាគទី៣** មាតាបិតា និងសហគមន៍ជួយដល់ការរៀនសូត្រ **សមាសភាគទី៤** សិស្ស និងសេវាជួយសិស្ស **សមាសភាគទី៥** ការដឹកនាំ និងគ្រប់គ្រង **សមាសភាគទី៦** ធនធានមនុស្ស **សមាសភាគទី៧** សម្ភារៈបង្រៀន និងរៀន **សមាសភាគទី៨** ហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថាន

សាលារៀន និង**សមាសភាគទី៩** ហិរញ្ញប្បទាន និងការគ្រប់គ្រងហិរញ្ញវត្ថុ។ ចំពោះចំនួនសំណាកដែលត្រូវចូលរួមបំពេញកម្រងសំណួររួមមាន នាយកសាលា ៧នាក់ (០១នាក់ក្នុងមួយសាលា) គ្រូបង្រៀន ៥៧នាក់ (៨នាក់ក្នុងមួយសាលា) សិស្ស ១៥០នាក់ (២១នាក់ ក្នុងមួយសាលា) គណៈកម្មការគ្រប់គ្រងសាលារៀន និងសហគមន៍ ២១នាក់ (៣នាក់ ក្នុងមួយសាលា) ។

## ១.៦ សារៈសំខាន់នៃការស្រាវជ្រាវ

តាមការបង្ហាញខាងលើ ការគ្រប់គ្រងតាមសាលារៀន (SBM) នេះមានសារៈសំខាន់ណាស់ក្នុងការរួមចំណែកការអភិវឌ្ឍគុណ-ភាពអប់រំ។ ការគ្រប់គ្រងតាមសាលារៀន (SBM) គឺជាការផ្តល់ស្វ័យភាពក្នុងការសម្រេចចិត្តទៅកម្រិតមូលដ្ឋាន ដោយផ្អែកលើលទ្ធផលនៃការអនុវត្តការងាររបស់សាលារៀន និងលទ្ធផលសិក្សារបស់សិស្ស។ ការសិក្សាស្រាវជ្រាវនេះ នឹងបង្ហាញអំពីស្ថានភាពនាពេលបច្ចុប្បន្ននៃការអនុវត្តការគ្រប់គ្រងតាមសាលារៀន (SBM) នៅកម្រិតមធ្យមសិក្សាបឋមភូមិក្នុងរាជធានីភ្នំពេញ។ ការសិក្សានេះក៏នឹងក្លាយជាព័ត៌មានដ៏មានប្រយោជន៍សម្រាប់ជាជំនួយដល់ ក្រសួងអប់រំ យុវជន និងកីឡា ក្នុងការពង្រឹងបន្ថែមលើការអនុវត្តការងារគ្រប់គ្រងតាមសាលារៀនដើម្បីអោយសាលារៀនប្រកបដោយប្រសិទ្ធភាពតាមស្តង់ដាទាំង៩ ស្តីពីសាលារៀនមានប្រសិទ្ធភាព។ ម៉្យាងវិញទៀតការសិក្សាស្រាវជ្រាវនេះក៏ជាទុនសម្រាប់អ្នកសិក្សាជំនាន់ក្រោយៗអាចសិក្សាបន្ត ឱ្យបានកាន់តែមានលក្ខណៈលម្អិតនូវរាល់បញ្ហាប្រឈម និងបង្កើនប្រសិទ្ធភាពនៃការអនុវត្តការគ្រប់គ្រងតាមសាលារៀន (SBM) នៅកម្រិតមធ្យមសិក្សាបឋមភូមិ ។

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះចែកចេញជាប្រាំជំពូករួមមាន៖

**ជំពូកទី១ សេចក្តីផ្តើម៖** សេចក្តីផ្តើម ក្នុងជំពូកនេះអ្នកសិក្សាស្រាវជ្រាវ នឹងលើកឡើងពីលំនាំបញ្ហាចំណោទបញ្ហាគោលបំណងស្រាវជ្រាវ សំណួរស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ និងវិសាលភាពនៃការស្រាវជ្រាវ។

**ជំពូកទី២ ការរំលឹកទ្រឹស្តី៖** រាល់ទ្រឹស្តីរបស់អ្នកសិក្សាស្រាវជ្រាវមុនៗ ដែលពាក់ព័ន្ធនឹងប្រធានបទនេះត្រូវបានលើកឡើងដើម្បីធ្វើជាគំនិត និងឆ្លុះបញ្ចាំងទៅនឹងការរកឃើញថ្មី នៅក្នុងស្នាដៃស្រាវជ្រាវនេះផងដែរ។

**ជំពូកទី៣ វិធីសាស្ត្រស្រាវជ្រាវ៖** នៅក្នុងជំពូកនេះអ្នកសិក្សាស្រាវជ្រាវនឹងបង្ហាញ នូវឧបករណ៍ស្រាវជ្រាវវិធីសាស្ត្រប្រមូលទិន្នន័យ វិធីជ្រើសរើសគំរូសំណាក ព្រមទាំងវិធីសាស្ត្រវិភាគទិន្នន័យដែលប្រមូលបាន ។

**ជំពូកទី៤ លទ្ធផលនៃការស្រាវជ្រាវ៖** លទ្ធផលនៃការស្រាវជ្រាវ នឹងត្រូវបានយកមកបកស្រាយ និងពិភាក្សាយ៉ាងក្បោះក្បាយ ដើម្បីរកឱ្យឃើញនូវចំណុចល្អ និងចំណុចដែលត្រូវធ្វើឱ្យប្រសើរឡើងវិញនៅក្នុងស្ថានភាពជាក់ស្តែង របស់សាលារៀននីមួយៗ ។

**ជំពូកទី៥ សេចក្តីសន្និដ្ឋាន និងសំណូមពរ៖** នេះជាផ្នែកដែលអ្នកស្រាវជ្រាវ ធ្វើការសន្និដ្ឋានទៅលើចំណុចទាំងអស់ដែលបានយកមកវិភាគ ព្រមទាំងលើកឡើងនូវសំណូមពរមួយចំនួនក្នុងបំណងលើកកម្ពស់ការអនុវត្តការគ្រប់គ្រងតាមសាលារៀន (SBM) នៅមធ្យមសិក្សាបឋមភូមិអោយមានលក្ខណៈល្អប្រសើរឡើង។

# ជំពូកទី២

# រំលឹកទ្រឹស្តី

# ជំពូកទី២
# រំលឹកទ្រឹស្តី

ការគ្រប់គ្រងតាមសាលារៀន (SBM) គឺទាក់ទងទៅនឹងការផ្ទេរអំណាច និងពត៌មាន (Mash, 1992) ការទទួលខុសត្រូវ (Candoli, 1995) ធនធាន (Caldwell & Spinks, 1992) និងការសម្រេចចិត្តលើការអភិវឌ្ឍ និងការគ្រប់គ្រងធនធានមនុស្ស ការគ្រប់គ្រងហិរញ្ញវត្ថុ និងការផ្តល់កម្មវិធីសិក្សា (Wong, 2003) ពីការិយាល័យកណ្តាលទៅសាលារៀន។ លើសពីនេះទៀតវាត្រូវការការចូលរួមមិនត្រឹមតែពីអ្នកជំនាញនៅសាលារៀនប៉ុណ្ណោះទេថែមទាំងពីឳពុកម្តាយសិស្ស និងសមាជិកសហគមន៍ ក្នុងការបង្កើតគោលនយោបាយសាលារៀន និងធ្វើការសម្រេចចិត្តសម្រាប់សាលារៀន (Duhou, 1999)។ នេះមានន័យថាការចូលរួមពីសហគមន៍ ការទទួលបានព័ត៌មាន ការទទួលខុសត្រូវ ការសំរេចចិត្តទាក់ទងនឹងការប្រើប្រាស់ធនធាន និងការគ្រប់គ្រងសាលារៀននៅមូលដ្ឋាន គឺជាធាតុសំខាន់ក្នុងការអនុវត្តគោលនយោបាយអប់រំដែលមានលក្ខណៈវិមជ្ឈការ ដែលអាចនាំអោយមានការគ្រប់គ្រងតាមសាលារៀន (SBM)។

ជំពូកនេះនឹងពិភាក្សាអំពីប្រសិទ្ធភាពនៃការអនុវត្តការគ្រប់គ្រងតាមសាលារៀន (SBM) នៅកម្រិតមធ្យមសិក្សាបឋមភូមិក្នុងរាជធានីភ្នំពេញ ។

## ២.១ វិមជ្ឈការនៃការអប់រំនៅក្នុងបរិបទកម្ពុជា

ទ្រឹស្តីពីវិមជ្ឈការនៃការអប់រំ បង្ហាញថាដើម្បីបង្កើនគុណភាពអប់រំបាន គឺទាមទារអោយមានការចូលរួមរបស់សហគមន៍នៅក្នុងការគ្រប់គ្រងសាលារៀន។ វាគឺជាគោលការណ៍ណែនាំវិមជ្ឈការដែលថា « អភិបាលកិច្ចដ៏មានប្រសិទ្ធភាពបំផុតរបស់អង្គភាពមួយកើតឡើងនៅពេលអាជ្ញាធរ មានសមត្ថកិច្ចសម្រាប់ការសម្រេចចិត្តត្រូវបានតាមដែលអាចធ្វើទៅបានចំពោះទីកន្លែងដែលសកម្មភាពនេះកើតឡើង » ( Mcginn and Welch 1999, p94)។ គោលនយោបាយអប់រំនៅកម្ពុជា បានលើកទឹកចិត្តយ៉ាងច្បាស់ដល់ការចូលរួមរបស់សហគមន៍ដែលជាមធ្យោបាយក្នុងការបញ្ចូលទំនួលខុសត្រូវសាលារៀនដល់សហគមន៍។ គោលនយោបាយកំណែទម្រង់ទាមទារឱ្យសហគមន៍ដែលតំណាងដោយគណៈកម្មាធិការគាំទ្រសាលា (SSC) គាំទ្រផែនការអភិវឌ្ឍសាលារៀន និងរបាយការណ៍ចំណាយ។ ឯកសារទាំងនេះត្រូវតែចុះហត្ថលេខាដោយអ្នកតំណាងរបស់ SSC មុននឹងដាក់ស្នើទៅ DoEs និងPoEs។

ការសិក្សាអំពីគោលនយោបាយវិមជ្ឈការនៅកម្ពុជា ( Pellini, 2007) បានរកឃើញថាគោលការណ៍ណែនាំរបស់ ក្រសួងអប់រំ យុវជន និងកីឡា (MoEYS Cluster Schools) បានពិពណ៌នាអំពីក្រុមសិក្សាជាវេទិកាបើកទូលាយនិងប្រជាធិបតេយ្យដែលអនុញ្ញាតឱ្យមានការចូលរួមកាន់តែជ្រៅនៃសហគមន៍ជាភាគីសំខាន់ៗដូចជាគ្រូ និងនាយកសាលា។ ក្រសួងអប់រំ យុវជន និងកីឡា បានបន្ថែមថារាជរដ្ឋាភិបាលកម្ពុជាបានខិតខំប្រឹងប្រែងយ៉ាងខ្លាំងដើម្បីសម្រេចបាននូវការធានារ៉ាប់រងដល់កុមារគ្រប់រូបក្នុងការទទួលបានការអប់រំ និងការរៀនសូត្រប្រកបដោយគុណភាព។ ទោះរដ្ឋាភិបាលបានខិតខំប្រឹងប្រែងយ៉ាងណាក៏

ដោយក៏មិនមានលទ្ធភាពឈានដល់ចំណុចនេះដែរ។ នេះគឺដោយសារតែការចូលរួមមិនគ្រប់គ្រាន់របស់សហគមន៍ ( p384) ។

ការសង្កត់ធ្ងន់លើការចូលរួមក្នុងការប្រាស្រ័យទាក់ទងមិនល្អ គឺគួរឱ្យភ្ញាក់ផ្អើលដោយសារតែមូលហេតុពីរ។ ទី១ហាក់ដូចជាមិនអើពើនឹងការពិតដែលជាគ្រួសារផ្តល់នូវធនធានភាគច្រើនសម្រាប់ការអប់រំ។ ទី២ខណៈដែលវាជាការពិតថាការចូលរួមក្នុងការប្រាស្រ័យទាក់ទងអាចកាន់តែរឹងមាំ ។

យោងទៅតាម Bradenberg (2002) ការសន្ទនាគ្នារវាងសហគមន៍ និងសាលារៀនត្រូវបានជំរុញដោយការទាមទាររបស់សាលាសម្រាប់ការគាំទ្រសម្ភារៈ នឹងការចូលរួមរបស់សហគមន៍ក្នុងការរួមចំណែកក្នុងមូលដ្ឋានសម្រាប់ការសាងសង់ និងថែរក្សាអគារសិក្សា។ ទោះជាយ៉ាងណា « ទំនាក់ទំនងរវាងសាលារៀន និងសហគមន៍នៅតែមិនទាន់ស៊ីសង្វាក់គ្នា »។

នៅថ្នាក់គោលនយោបាយមន្ត្រីក្រសួងអប់រំ ដឹងថាសហគមន៍អាចដើរតួ ប៉ុន្តែមិនបានបញ្ជាក់អំពីតួនាទីដែលអាចធ្វើបានរបស់សហគមន៍នៅក្នុងប្រព័ន្ធអប់រំ។ គោលការណ៍ណែនាំរបស់រដ្ឋមន្ត្រីបានព្យាយាមកែលម្អស្ថានភាពនេះដែលចែងអំពីសកម្មភាពផ្សព្វផ្សាយ ដើម្បីផ្សព្វផ្សាយព័ត៌មានអំពីផែនការសាលារៀន (MoEYS 2000)។ លើសពីនេះមានគោលការណ៍ណែនាំថ្នាក់ជាតិ ក៏បានផ្តល់ការណែនាំអំពីការបង្កើតគណៈកម្មាធិការ និងអនុគណៈកម្មការដែលមានបំណងលើកកម្ពស់អភិបាលកិច្ចសាលារៀនដោយលើកទឹកចិត្តឱ្យគ្រូបង្រៀនអនុវត្តការងាររបស់ខ្លួនឱ្យបានល្អ ឬប្រមូលសហគមន៍សម្រាប់ការសាងសង់ និងការជួសជុលសាលារៀន។ ទោះយ៉ាងណាក៏ដោយវាមិនប្រាកដថាតើសហគមន៍ទាំងនេះដំណើរការ។

ដើម្បីឱ្យមានប្រសិទ្ធភាពការធ្វើវិមជ្ឈការត្រូវតែប៉ងឱ្យបាន ដើម្បីផ្លាស់ប្តូររចនាសម្ព័ន្ធនៃអំណាចរបស់សហគមន៍ដែលកំពុងមានបច្ចុប្បន្ន ធ្វើឱ្យមានច្រើននូវឱកាសសម្រាប់ការចូលរួម និងបង្ហាញនូវគំនិតយោបល់របស់សហគមន៍ និងឱ្យគ្រប់ប្រជាពលរដ្ឋទាំងអ្នកក្រ និងអ្នកជួបការលំបាកឱ្យចូលរួម (Bardhan 2002)។

វាហាក់ដូចជាមានការឯកភាពគ្នាតាំងពីឆ្នាំ១៩៨០ ទាំងការធ្វើវិមជ្ឈការហួសហេតុពេក ឬការផ្តល់សិទ្ធអំណាចទាំងស្រុងទៅមូលដ្ឋាននាំមកនូវមហន្តរាយ ដូចនេះហើយត្រូវតែមានការរៀបចំឱ្យមាននូវប្រព័ន្ធសហប្រតិបត្តិការប្រសើររវាងថ្នាក់កណ្តាល ថ្នាក់ក្រោមជាតិ និងថ្នាក់មូលដ្ឋាន ស្តីពីសិទ្ធក្នុងការធ្វើការសម្រេចចិត្ត[4] ។

## ២.២ ទស្សនាទានរួមស្តីពីការគ្រប់គ្រងតាមសាលារៀន (SBM)

ការគ្រប់គ្រងតាមសាលារៀន (SBM) គឺជាវិធីសាស្ត្រអនុវត្តវិមជ្ឈការនៃការអប់រំ ដើម្បីឱ្យសេវាអប់រំមានប្រសិទ្ធភាពដែលបង្ហាញតាមរយៈភ័ស្តុតាងសមិទ្ធកម្ម នៃការអនុវត្តគោលនយោបាយអប់រំជំនួសអោយការគ្រប់គ្រងតាមបែបមជ្ឈការពីថ្នាក់កណ្តាល។ ការគ្រប់គ្រងតាមសាលារៀន បានផ្តល់នូវគុណប្រយោជន៍ដូចជា (១)ណែនាំឱ្យមាននូវការប្រកួតប្រជែង ការរក្សាការពិនិត្យសមិទ្ធកម្មផ្ទៃក្នុង និង តុល្យ

[4] MoEYs (បទបង្ហាញស្តីពី ផែនការសកម្មភាព និងក្របខ័ណ្ឌលទ្ធផលគម្រោងកែលម្អការអប់រំនៅមធ្យមសិក្សា, ២០១៨)

ភាពផ្ទៃក្នុងរដ្ឋ (ផ្តល់ធនធាន អំណាច និងការកសាងសមត្ថភាព ), (២)ធ្វើឱ្យរដ្ឋមានការឆ្លើយតបច្រើនជាងមុន និងឱ្យសេវាសាធារណៈមានប្រសិទ្ធភាព (ដោះស្រាយបញ្ហាទាន់ពេល និងមានប្រសិទ្ធ ភាព), (៣) បន្ថយភាពតានតឹងក្នុងសង្គម និងនយោបាយ និងធានានូវស្វ័យភាពមូលដ្ឋាន (សាធារណៈរួមចំណែកទទួលខុសត្រូវ និងដោះស្រាយបញ្ហាជាមួយរដ្ឋ )។

### ២.៣ ទស្សនៈផ្សេងៗលើការគ្រប់គ្រងតាមសាលារៀន (SBM)

ការគ្រប់គ្រងតាមសាលារៀន គឺជាយុទ្ធសាស្ត្រកំណែទម្រង់ធំទូលាយក្នុងចំណោមអ្នកបង្កើតគោលនយោបាយនៅទូទាំងពិភពលោក។ និយមន័យនៃការគ្រប់គ្រងសាលារៀនដែលមានមូលដ្ឋានខុសប្លែកពីគ្នាទៅតាមបណ្តាប្រទេសពិសេសដោយផ្អែកលើលក្ខណៈ និងគោលដៅនៃកម្មវិធី ( Caldwell ,2009) ដែលទទួលនូវឥទ្ធិពលពីវប្បធម៌ និងបរិបទនយោបាយ (Gamage and Zajda 2009, p4)។ Sackney and Dibski (1995) បានចាត់ទុកការគ្រប់គ្រងដែលមានមូលដ្ឋាននៅសាលារៀនថាជា « សំណើរដើម្បីវិមជ្ឈការ និងធ្វើការិយាល័យគ្រប់គ្រងលើការគ្រប់គ្រងសាលារៀន » ទាក់ទងនឹងការសម្រេចចិត្តរួមគ្នាដែលពាក់ព័ន្ធនឹងឪពុកម្តាយ និងអ្នកពាក់ព័ន្ធផ្សេងទៀត (p30)។ ការគ្រប់គ្រងតាមសាលារៀនក៏អាចត្រូវបានកំណត់ជាទម្រង់វិមជ្ឈការ តាមរយៈការដាក់អាទិភាពលើសាលារៀននីមួយៗដែលមានមុខងារដើម្បីកែលម្អ និងទ្រទ្រង់ប្រសិទ្ធភាពសាលារៀន និងប្រសិទ្ធភាពក្នុងការសម្រេចចិត្តថ្មីឱ្យអាជ្ញាធរ និងការទទួលខុសត្រូវ (Malen et al, p290)។ យោងទៅតាមអ្នកជំនាញគ្រប់គ្រងនៅសាលារៀន (Caldwell (2009) « ការគ្រប់គ្រងតាមសាលារៀនក្នុងប្រព័ន្ធអប់រំសាធារណៈ គឺជាប្រព័ន្ធនៃវិមជ្ឈការជាមួយ នឹងស្របតាមកម្រិតថ្នាក់អាជ្ញាធរ និងការទទួលខុសត្រូវក្នុងការធ្វើសេចក្តីសម្រេចលើបញ្ហាសំខាន់ៗទាក់ទងនឹងប្រតិបត្តិការសាលាក្នុងក្របខ័ណ្ឌនៃការកំណត់គោលដៅគោលនយោបាយកម្មវិធីសិក្សាបទដ្ឋាន និង គណនេយ្យភាព (p. 55)។ ទ្រឹស្តីនេះបានបង្ហាញថាការគ្រប់គ្រងតាមសាលារៀន គឺជាយុទ្ធសាស្ត្រកំណែទម្រង់ការអប់រំសកលដែលត្រូវបានជំរុញដោយមូលហេតុមួយចំនួន (Grauwe, 2005)។ មូលហេតុទី១ គឺថាការគ្រប់គ្រងតាមសាលារៀន គឺជាភស្តុតាងដើម្បីបង្ហាញពីលទ្ធិប្រជាធិបតេយ្យដែលគ្រូ និងមាតាបិតាត្រូវបានផ្តល់កន្លែងទំនេរដើម្បីចូលរួមក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត។ ហេតុផលទី២ បង្ហាញពីការគ្រប់គ្រងរបស់សាលារៀនដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់អ្នកពាក់ព័ន្ធក្នុងតំបន់។ ខណៈដែលអាជ្ញាធរមានសមត្ថកិច្ចក្នុងការធ្វើសេចក្តីសម្រេចចិត្ត គឺនៅជិតប្រជាជនក្នុងស្រុកដោះស្រាយអាចឆ្លើយតបបានល្អប្រសើរ។ មូលហេតុទី៣ គឺថាការគ្រប់គ្រងតាមសាលារៀនកាត់បន្ថយការអនុវត្តការិយាធិបតេយ្យនៅក្នុងប្រព័ន្ធ ។ បញ្ហាអាចត្រូវបានដោះស្រាយយ៉ាងឆាប់រហ័សក្នុងចំណោមអ្នកពាក់ព័ន្ធក្នុងស្រុក។ ជាចុងក្រោយការគ្រប់គ្រងតាមសាលារៀនអនុញ្ញាត ឱ្យមានការទទួលខុសត្រូវកាន់តែច្រើនដោយផ្តល់សាលារៀន និងគ្រូនូវសិទ្ធអំណាចខ្ពស់ដែលគ្រប់គ្រងដោយផ្ទាល់ដល់ឪពុកម្តាយ និងសហគមន៍។ ដោយសារផលប៉ះពាល់វិជ្ជមាននៃការគ្រប់គ្រងសាលារៀនប្រទេសជាច្រើននៅជុំវិញពិភពលោកពិសេសតំបន់អាស៊ី និងប៉ាស៊ីហ្វិកបានអនុវត្តកម្មវិធីគ្រប់គ្រងតាមសាលារៀនជាច្រើន។ ឧទាហរណ៍ការគ្រប់គ្រងតាមសាលារៀននៅហុងកុង

ក្រោមឈ្មោះថាគំនិតផ្តួចផ្តើមគ្រប់គ្រងសាលារៀន (SIM) ត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៩១។ គោលបំណងនេះ គឺដើម្បីលើកកម្ពស់គុណភាពអប់រំដោយការជំរុញឱ្យមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ (Wong, 2003)។ លើសពីនេះទៀតកម្មវិធីនេះបានលើកកំពស់វប្បធម៌ ដែលមានគុណភាពសង្កត់ធ្ងន់លើយុទ្ធសាស្ត្រដែលផ្តោតលើអ្នកសិក្សាដែលមានមូលដ្ឋាននៅសាលារៀន និងគណនេយ្យភាព (Gamage and Zajda, 2009)។ ជាក់ស្តែងសាលារៀនត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ធនធានចាំបាច់ និងអាចបញ្ជាក់ពីមុខងារ និងការទទួលខុសត្រូវសម្រាប់ការផ្តល់ការអប់រំ (Heun, 2003)។ នៅឆ្នាំ២០០១ប្រទេសឥណ្ឌូនេស៊ីបានបង្កើតកម្មវិធីគ្រប់គ្រងសាលារៀននៅទូទាំងប្រទេសដែលផ្តោតសំខាន់លើទិដ្ឋភាពបួនគឺ គុណភាព សមាសភាពពាក់ព័ន្ធ និងប្រសិទ្ធភាព (Shoraku, 2008)។ វិធីសាស្ត្រជាច្រើនត្រូវបានគេអនុវត្តដើម្បីសំរេចបំណងប្រាថ្នាដែលបានបញ្ជាក់។ វិធិសាស្ត្ររបស់សាលារៀនបាន ផ្តល់សិទ្ធស្វ័យភាពបន្ថែមដល់នាយកសាលានៅពេលដែលវិធីសាស្ត្ររបស់សហគមន៍ បានផ្សារភ្ជាប់ទាំងសាលារៀន និងសហគមន៍មូលដ្ឋានដែលជាការចូលរួមចំណែកដ៏សំខាន់ដល់ភាពជោគជ័យនៃការគ្រប់គ្រងសាលារៀន និងសមិទ្ធផលរបស់សិស្ស (Indriyanto, 2003)។ ការអនុវត្តការគ្រប់គ្រងតាមសាលារៀន នៅប្រទេសហ្វីលីពីនមានគោលបំណងដើម្បីលើកកម្ពស់អភិបាលកិច្ច ដែលបានចែករំលែកការសំរេចចិត្តតាមបែបប្រជាធិបតេយ្យការទទួលខុសត្រូវ និងតម្លាភាព និងទំនាក់ទំនងរវាងអ្នកពាក់ព័ន្ធ (Guzman, 2003)។ កម្រិតថ្នាក់កណ្តាល និងថ្នាក់ស្រុក និងធ្វើឱ្យអាជ្ញាធរមានសមត្ថកិច្ចក្នុងការធ្វើសេចក្តីសម្រេចចិត្ត ចំពោះការបែងចែកសាលារៀននៅតាមបណ្តាខេត្ត និងក្រុងនានាដែលក្នុងនោះមានការទទួលខុសត្រូវផ្នែកអប់រំជាមួយអ្នកពាក់ព័ន្ធដូចជាអង្គភាពរដ្ឋបាលមូលដ្ឋាន និងសហគមន៍មាតាបិតា (PTAs)។ ទ្រឹស្តីហួសសម័យ មិនត្រឹមតែបង្ហាញពីកំលាំងចលករនៃការគ្រប់គ្រងតាមសាលារៀនប៉ុណ្ណោះទេប៉ុន្តែក៏ពន្យល់ពីគោលបំណងទូទៅនៃការគ្រប់គ្រងតាមសាលារៀនផងដែរ។ ទោះបីជាមានកម្មវិធីគ្រប់គ្រងសាលារៀនជាច្រើន ដែលទទួលឥទ្ធិពលពីកត្តាវប្បធម៌សង្គម និងនយោបាយ (Santibanez, 2006) ពួកគេអាចនឹងមានគោលបំណងដូចខាងក្រោមនេះដែលរួមមាន (១)ការចូលរួមជាមួយឪពុកម្តាយ និងសហគមន៍ក្នុងសាលារៀន (២)ផ្តល់អំណាចដល់អ្នកគ្រប់គ្រងសាលារៀននិងគ្រូបង្រៀន (៣)កសាងសមត្ថភាពថ្នាក់មូលដ្ឋាន (៤)បង្កើតយន្តការគណនេយ្យភាពសម្រាប់ភ្នាក់ងារដែលមានមូលដ្ឋានៅតាមតំបន់ និងដើម្បីលើកកំពស់តម្លាភាពនៃដំណើរការដោយវិមជ្ឈការអំណាច និង(៥)បង្កើតគុណភាពនិងប្រសិទ្ធភាពនៃការរៀនសូត្រដែលលើកកម្ពស់គុណភាពសិក្សា (Gertler et al, 2007)។

### ២.៣.១ កត្តាចាំបាច់សម្រាប់អនុវត្តការគ្រប់គ្រងតាមសាលារៀន (SBM) នៅកម្ពុជា

ការដាក់បញ្ចូលការគ្រប់គ្រងតាមសាលារៀននៅកម្រិតមធ្យមសិក្សាបឋមភូមិ ដែលបានជ្រើសរើសនៅក្នុងប្រទេសកម្ពុជា គឺមិនខុសគ្នាពីអ្វីដែល (Grauwe,2006) បានកំណត់ថាមានឥទ្ធិពលពីកំណែទម្រង់នយោបាយ និងយុទ្ធសាស្ត្រជាតិ (ស្ថាប័នជាតិ និងអ្នកជំនាញខាងអប់រំ)។ ក្រសួងអប់រំ យុវជន និងកីឡា (MoEYS) បានបង្ហាញនូវការប្តេជ្ញាចិត្តក្នុងការកែលំអវិស័យអប់រំតាមរយៈ គំនិតផ្តួចផ្តើមកំណែទម្រង់

ការអប់រំ។ ដូចដែលបានចង្អុលបង្ហាញផែនការយុទ្ធសាស្ត្រ (ESP) ២០០៦-២០១០ និង២០០៩-២០១៣ ដើមឡើយបានបង្កើតឡើងនៅឆ្នាំ២០០០ បានសង្កត់ធ្ងន់លើទិដ្ឋភាពសំខាន់ៗបីគឺ (១)ការទទួលបានសេវាអប់រំប្រកបដោយសមធម៌ (២)គុណភាព និងប្រសិទ្ធភាពនៃសេវាកម្មអប់រំ និង(៣)ការអភិវឌ្ឍស្ថាប័ន និងការកសាងសមត្ថភាពសម្រាប់វិមជ្ឈការ។ កំណែទម្រង់ការអប់រំត្រូវបានចាប់ផ្តើមដោយជំនួយបច្ចេកទេស និងហិរញ្ញវត្ថុពីភ្នាក់ងារអន្តរជាតិនានា។ ធនាគារពិភពលោក និងធនាគារអភិវឌ្ឍន៍អាស៊ីបានដើរតួនាទីយ៉ាងសំខាន់ក្នុងការគាំទ្រដំណើរការនៃការបង្កើតគោលនយោបាយអប់រំ។ ទោះជាយ៉ាងណាក៏ដោយ ស្ថាប័នទាំងនេះមិនមានឥទ្ធិពលដោយផ្ទាល់ ឬការចូលរួមនៅកម្រិតសាលារៀន ដែលការគ្រប់គ្រងតាមសាលារៀន SBM ត្រូវបានអនុវត្ត ។

កិច្ចខិតខំប្រឹងប្រែងរួមគ្នារបស់រាជរដ្ឋាភិបាល និងសហគមន៍អភិវឌ្ឍអន្តរជាតិបាននាំមកនូវកម្មវិធីគ្រប់គ្រងសាលារៀនជាច្រើនដែលរួមមាន គម្រោងកែលម្អគុណភាពការអប់រំ កម្មវិធីសកម្មភាពអាទិភាព និងថវិកាកម្មវិធីនៅក្នុងឆ្នាំ ២០០១-២០០៣ ឆ្នាំ២០០១-២០០៦ និង២០០៧ រៀងគ្នា។ ការអនុវត្តការគ្រប់គ្រងតាមសាលារៀនមានគោលបំណងសំដៅលើ (១)កែលម្អការអប់រំប្រកបដោយគុណភាពតាមរយៈផ្ញើសម្ភារៈណែនាំដែលចាំបាច់នៅសាលារៀន (២)ពង្រីកលទ្ធភាពទទួលបានការអប់រំតាមរយៈការលុបបំបាត់ចោលគោលនយោបាយឆ្នាំសិក្សាបង់ថ្លៃ (៣)លើកកម្ពស់វិធីសាស្ត្រក្នុងការធ្វើសេចក្តី សម្រេចរួមដោយការផ្តល់សិទ្ធិដល់អាជ្ញាធរធ្វើសេចក្តីសម្រេចចិត្តដល់អ្នកពាក់ព័ន្ធនានាក្នុងមូលដ្ឋាន និង(៤)បង្កើនប្រសិទ្ធភាព និងប្រសិទ្ធភាពនៃការគ្រប់គ្រងថវិការនៅសាលារៀន។ នៅក្នុងការអនុវត្តការគ្រប់គ្រងតាមសាលារៀនវិធីសាស្ត្រក្នុងការសម្រេចចិត្ត ដែលមានការចូលរួមត្រូវបានលើកទឹកចិត្តតាមរយៈ ការបង្កើតគណៈកម្មាធិការទ្រទ្រង់សាលា ដែលបាននាំមកនូវអ្នកពាក់ព័ន្ធសំខាន់ៗក្នុងតំបន់ជាមួយគ្នា។ សាលារៀនទាំងអស់មានគណៈកម្មាធិការគាំទ្រសាលារៀនដែលមាន (១)តំណាងអាជ្ញាធរមូលដ្ឋាននៅថ្នាក់ស្រុកខណ្ឌ ភូមិ ឬចៅអធិការវត្ត (២)នាយកសាលា (៣)អ្នកតំណាងសហគមន៍ម្នាក់ដែលគួរឱ្យសរសើរ និងមានប្រជាប្រិយ៍ (៤)សមាជិកម្នាក់នៃសហគមន៍ (៥)គណនេយ្យករម្នាក់ (ជាប់ឆ្នោតក្នុងចំណោមសមាជិក) (៦)ហេរញ្ញិកម្នាក់ (ជាប់ឆ្នោតក្នុងចំណោមសមាជិក) និងលេខាធិការម្នាក់ (ដែលបានជ្រើសរើសក្នុងចំណោមសមាជិកម្នាក់)។ មុខងារ និងតួនាទីរបស់គណៈកម្មាធិការរួមមាន (១)បង្កើតការចុះឈ្មោះរបស់កុមារតាមរយៈយុទ្ធនាការអប់រំ និងការលើកទឹកចិត្តពីឪពុកម្តាយ (២)ចូលរួមក្នុងការកៀរគរប្រាក់ចំណូល និងថវិកាតាមរយៈផែនការអភិវឌ្ឍសាលារៀន (៣)ការកែលម្អ ថែទាំសាលារៀន និងទ្រព្យសម្បត្តិសាលារៀន (៤)ពាក់ព័ន្ធនឹងការសាងសង់និងជួសជុលសាលារៀនតាមរយៈការបង្កើនមូលនិធិ និងការចូលរួមជាមួយឪពុកម្តាយ (៥)រារាំងភាពមិនប្រក្រតីនៅក្នុង និងក្រៅសាលារៀន (៦)ចូលរួមក្នុងការរៀបចំផែនការ និងការអនុវត្តសាលារៀន និង(៧)តាមដានការរៀនសូត្ររបស់សិស្សតាមរយៈការប្រជុំសហគមន៍។

ដូចដែលបានពិពណ៌នាដោយ (Grauwe, 2005) ថាវិធីសាស្ត្រនៃការសម្រេចចិត្តដែលបានចូលរួមបានលើកកម្ពស់គំនិតប្រជាធិបតេយ្យក្នុងចំណោមអ្នកពាក់ព័ន្ធក្នុងស្រុកនៅពេលពួកគេចូលរួមក្នុងការ

អភិវឌ្ឍសាលារៀន។ ការសិក្សានាពេលបច្ចុប្បន្នគាំទ្រជាពិសេសនូវសារៈសំខាន់ដែលសមាជិក សហគមន៍ ឪពុកម្តាយបានចូលរួមកាន់តែច្រើននៅក្នុងសកម្មភាពសាលារៀន។ ការចូលរួមរបស់អ្នកពាក់ព័ន្ធទាំងអស់នេះបង្ហាញពីលក្ខណៈនៃប្រព័ន្ធវិមជ្ឈការ ដែលបានអំពាវនាវដល់ការគ្រប់គ្រងតាមសាលារៀនសាធារណៈ និងការស្រាវជ្រាវ (Gamage& Zajda, 2009: p3)។ មានការកត់សម្គាល់មួយថាស្ថាប័នមិនមែនរដ្ឋាភិបាលបានដើរតួនាទីយ៉ាងសំខាន់ក្នុងការគាំទ្រដល់ការអភិវឌ្ឍ និងការគ្រប់គ្រងសាលារៀនតាមរយៈជំនួយបច្ចេកទេស និងហិរញ្ញវត្ថុ។ ឧទាហរណ៍សេវាស្ម័គ្រចិត្តក្រៅប្រទេស អង្គការភាពជាដៃគូរអប់រំ អង្គការមិនមែនរដ្ឋាភិបាល TIMA អង្គការ SAWA ការអប់រំពិភពលោក និងSVA បានគាំទ្រផ្នែកនានានៃបរិស្ថានសាលារៀន (ការសាងសង់សួនកុមារ និងសួនច្បារ) កម្មវិធីបំណិនជីវិត និងការបណ្តុះបណ្តាលសម្ភារៈបង្រៀន និងរៀន និងបន្ថែម-សកម្មភាពកីឡា។

វិសាលភាពដែលគណៈកម្មាធិការគាំទ្រសាលា ឪពុកម្តាយ និងសហគមន៍ និងអង្គការមិនមែនរដ្ឋាភិបាលចូលរួមក្នុងការអភិវឌ្ឍសាលារៀនបង្ហាញពីលក្ខណៈពិសេសនៃសាលារៀនដែលចូលរួម។ សាលារៀនដែលចូលរួមយ៉ាងសកម្មពីគណៈកម្មាធិការទ្រទ្រង់សាលារៀន ឪពុកម្តាយ និងសហគមន៍ក៏ដូចជាការផ្តល់ជំនួយផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុដោយផ្ទាល់ពីអង្គការមិនមែនរដ្ឋាភិបាលនានាបង្ហាញពីភាពប្រសើរឡើងនៃបរិស្ថាន និងហេដ្ឋារចនាសម្ព័ន្ធ សម្ភារៈបង្រៀន និងការចូលរួមរបស់បុគ្គលិក នៅពេលសាលារៀនមានតិច ឬគ្មានការគាំទ្រដោយផ្ទាល់ ដើម្បីឱ្យមានភាពប្រសើរឡើងតិចតួច។ ការសិក្សានេះបង្ហាញថាដើម្បីទាមទារការចូលរួម និងការគាំទ្រដោយផ្ទាល់ពីអង្គការដឹកនាំសាលាដ៏រឹងមាំ គឺមានសារៈសំខាន់ជាទូទៅដូចដែលបានលើកឡើងដោយ (Grauwe, 2005) ដែលថាសមត្ថភាព និងរចនាបទភាពជាអ្នកដឹកនាំសំខាន់គឺទាក់ទងទៅនឹងគុណភាពនៃការអប់រំ និងការអភិវឌ្ឍសាលារៀន។ លោកបានបន្ថែមថានាយកសាលាបានចូលរួមជាមួយសហគមន៍ក្នុងសកម្មភាពសាលា និងធ្វើឱ្យពួកគេយល់ដឹងពីស្ថានការណ៍ និងបង្កើតការជឿទុកចិត្តជានិច្ច។

កត្តាបួនយ៉ាងដែលបានចូលរួមចំណែកដល់ការអនុវត្តការគ្រប់គ្រងតាមសាលារៀននៅក្នុងប្រទេសកម្ពុជាគឺ (១)កត្តាចាំបាច់ទីមួយ គឺជាកត្តាសំខាន់ក្នុងការអនុវត្តការគ្រប់គ្រងតាមសាលារៀន SBM គឺត្រូវការសម្រាប់គណៈកម្មាធិការ ដែលមានសិទ្ធធ្វើសេចក្តីសម្រេចចិត្តកាន់តែធំចំពោះសាលារៀនក្នុងស្រុក និងសហគមន៍របស់ពួកគេពីព្រោះពួកគេដោះស្រាយដោយផ្ទាល់ជាមួយអ្នកសិក្សាហើយការសម្រេចចិត្តខាងការអប់រំរបស់ពួកគេបានប្រសើរជាងតម្រូវការរបស់សិស្ស។ អាជ្ញាធរដែលទទួលសិទ្ធតំណាងគ្របដណ្តប់លើវិស័យដូចជាការធ្វើផែនការសាលារៀនមូលដ្ឋាន និងគោលនយោបាយការគ្រប់គ្រងធនធានមនុស្ស ថវិកា និងការសម្របសម្រួលកម្មវិធីសិក្សា។ ស្របពេលជាមួយគ្នាសាលារៀននិង សហគមន៍ក្នុងសហគមន៍ត្រូវមានគណនេយ្យភាពចំពោះការសម្រេចចិត្តដែលពួកគេបានធ្វើទាក់ទងនឹងការប្រើប្រាស់ធនធាន និងការគ្រប់គ្រងតាមសាលារៀន។ (២)កត្តាសំខាន់ទីពីរដែលបានលេចឡើងទាក់ទងនឹងការបែងចែកធនធាន និងមូលនិធិទៅសាលារៀនសាធារណៈដោយរដ្ឋាភិបាល ផ្អែកលើយន្តការផ្តល់ធនធានស្មើ

គ្នានិងស្មើភាពគ្នា និងការអនុវត្តក្នុងការផ្តល់សាលារៀនដែលមានអំណាចកាន់តែធំជាងការគ្រប់គ្រង និងភាពបត់បែននៃថវិកា និងធនធានរបស់ពួកគេបានការបែងចែក។ នាយកដ្ឋានកណ្តាលចាំបាច់ត្រូវផ្លាស់ប្តូរតួនាទីរបស់ខ្លួនពីអ្នកដឹកនាំផ្ទាល់ទៅអោយអ្នកគាំទ្រ និងទីប្រឹក្សា និងដើម្បីធានាថាច្បាប់និងគោលនយោបាយអប់រំចាំបាច់ត្រូវប្រើនៅក្នុងប្រព័ន្ធអប់រំថ្មីត្រូវបានអនុម័ត។ នាយកដ្ឋានកណ្តាលក៏ត្រូវការប្រគល់សិទ្ធិអំណាចក្នុងការសម្រេចចិត្តធំជាងការគ្រប់គ្រងសាលារៀនដល់សាលារៀនមូលដ្ឋាន ដើម្បីបង្កើតរចនាសម្ព័ន្ធការសំរេចចិត្តក្នុងប្រព័ន្ធ និងដើម្បីកសាងសមត្ថភាពរបស់សមាជិកសាលារៀនក្នុងស្រុកដើម្បីអនុវត្តការគ្រប់គ្រងតាមសាលារៀន SBM។ ការិយាល័យស្រុកត្រូវដាក់សិទ្ធិអំណាចក្នុងការសម្រេចចិត្តនៅក្នុងសាលារៀន និងដើម្បីផ្តល់ការបណ្តុះបណ្តាលព័ត៌ចាំបាច់ និងគោលការណ៍ណែនាំច្បាស់លាស់សម្រាប់សាលារៀន។ សាលារៀនត្រូវមានចក្ខុវិស័យរួមគ្នា ដើម្បីបង្កើតការងារជាក្រុមដើម្បីអនុវត្តការសម្រេចចិត្តរួមគ្នាដើម្បីប្រជាធិបតេយ្យនិងចែករំលែកការដឹកនាំ និងអំណាចជាមួយគ្រូបង្រៀនឪពុកម្តាយ និងសមាជិកសហគមន៍។ (៣)កត្តាទីបីដែលពាក់ព័ន្ធនឹងការគ្រប់គ្រងនិងការអភិវឌ្ឍធនធានមនុស្ស។ ការបណ្តុះបណ្តាលជំនាញត្រូវបានគេមើលឃើញថាជាតម្រូវការសម្រាប់សាលារៀន ដើម្បីគ្រប់គ្រងដោយខ្លួនឯង។ ដូច្នេះការអភិវឌ្ឍវិជ្ជាជីវៈចាំបាច់ត្រូវ កំណត់ជាគោលដៅលើមូលដ្ឋានកំពុងបន្ត។ ជាពិសេសនាយកសាលាក្រុមមេដឹកនាំ និងសមាជិកក្រុមប្រឹក្សាភិបាលត្រូវការបណ្តុះបណ្តាលនៅក្នុងគោលនយោបាយនិងការធ្វើផែនការការអភិវឌ្ឍថវិកា ការរៀបចំសេចក្តីសម្រេចចិត្តការទំនាក់ទំនងការត្រួតពិនិត្យ និងការវាយតម្លៃនិងការគ្រប់គ្រងធនធានមនុស្ស។ (៤)កត្តាទីបួនការចូលរួមប្រាស្រ័យទាក់ទង គឺជាកត្តាសំខាន់មួយទៀតដែលទទួលបានជោគជ័យក្នុងការទទួលបានជោគជ័យពីព្រោះមាតាបិតា និងសមាជិកសហគមន៍ គឺជាអ្នកគាំទ្រនិងជាដៃគូររបស់សាលារៀនក្នុងស្រុក។ ពួកគេផ្តល់នូវការបញ្ចូលសំខាន់ៗចំនួនពីរដល់សាលារៀននៅតាមមូលដ្ឋានការចូលរួមរបស់ពួកគនៅក្នុងអភិបាលកិច្ចតាមសាលារៀនតាមរយៈការតំណាងនៅតាមសាលារៀន និងការរួមចំណែកហិរញ្ញវត្ថុ និងសម្ភារៈរបស់ពួកគេ[5] ។

## ២.៤ បទពិសោធន៍ការគ្រប់គ្រងតាមសាលារៀន (SBM) នៅកម្ពុជា

គម្រោងកែលម្អគុណភាពអប់រំ (Education Quality Improvement Project) ដែលបានអនុវត្តនៅប្រទេសកម្ពុជាឆ្នាំ១៩៩៩-២០០៤ បានផ្តល់មូលនិធិដល់សាលារៀន ដោយប្រើប្រាស់អភិក្រមការគ្រប់គ្រងសាលារៀន។ ជាលទ្ធផលបង្ហាញថា (១)មានការពិភាក្សាការងារជាប្រចាំនៅថ្នាក់សាលារៀនការរៀន-បង្រៀន បរិស្ថានសាលារៀន ការចូលរៀន អត្រាឡើងថ្នាក់ ការចូលរួមរបស់សិស្សស្រី គណនេយ្យភាពក្នុងការគ្រប់គ្រងសាលារៀន ការដឹកនាំ និងការឆ្លើយតបតម្រូវការមូលដ្ឋាន។ ប្រការនេះធ្វើឱ្យគ្រូបង្រៀន និងគណៈគ្រប់គ្រងសាលារៀន ទទួលបានការបំប៉នសមត្ថភាពជាប្រចាំ គោរពក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀនបានប្រសើរ និងធ្វើឱ្យសហគមន៍មានទំនុកចិត្តលើសាលារៀន។

ការផ្លាស់ប្តូរជាវិជ្ជមាន នៅសាលារៀនត្រូវបានបង្ហាញ តាមរយៈការរៀបចំឱ្យមាន ការប្រើប្រាស់

[5] សារណាបញ្ចប់ថ្នាក់អនុបណ្ឌិតសាកលវិទ្យាល័យភូមិន្ទភ្នំពេញ២០១២ ( Hong Hoklim p.20)

បណ្ណាល័យប្រកបដោយប្រសិទ្ធភាព។ មន្ទីរអប់រំ យុវជន និងកីឡាខេត្ត រាជធានី និងការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ស្រុក ខណ្ឌ បានជួយគាំទ្រដល់សាលារៀនផ្ទាល់បានអនុវត្តគោលនយោបាយអប់រំប្រកបដោយភាពបត់បែន បានបង្កើតបណ្តាញគាំទ្ររឹងមាំ រវាងថ្នាក់កណ្តាល អ្នកជំនាញការក្នុងក្រុង ស្រុក ខណ្ឌ អ្នកជំនាញការមកពីអង្គការសង្គមស៊ីវិល និងមានគំនិតផ្តួចផ្តើម លើការកសាងសមត្ថភាពដែលនាំទៅរកភាពខ្លាំងនៃបំណិនគ្រប់គ្រង។

បញ្ហាប្រឈមជាបទពិសោធន៍តាមរយៈការអនុវត្តគម្រោងរួមមាន ៖

១. ការយកប្រយោជន៍ពីភាពបត់បែន ពង្រីកវិសាលភាពនៃសកម្មភាពមូលនិធិធ្វើជាទុនមុន នឹងមានការសម្រេចចិត្តអនុវត្តជាក់ស្តែង នូវអ្វីដែលជាមេរៀនពិសោធន៍។

២. យន្តការគ្រប់គ្រងនៅមានកម្រិត ដូចនេះត្រូវពង្រឹងតួនាទីថ្នាក់កណ្តាល ថ្នាក់ក្រោមជាតិ និងគ្រូបង្គោល។

៣. សាលារៀនដែលជួបបញ្ហាប្រឈមខ្លាំងត្រូវការធនធាន និងជំនួយបច្ចេកទេសច្រើនជាងគេ។

៤. ធនធានអាចមិនបានផ្តល់ទៅតាមតម្រូវការជាក់ស្តែង នៃសាលារៀននៅតំបន់ជួបការលំបាក។

៥. ត្រូវយកចិត្តទុកដាក់ខ្ពស់សីលធម៌ ប្រាក់ឧត្តម្ភ ឬលាភសក្ការៈ។

៦. ការពិនិត្យតាមដាន និងវាយតម្លៃ៖

ក. ធានានិរន្តភាពនៃការពិនិត្យតាមដាន និងវាយតម្លៃជាផ្លូវការតាមរយៈការរៀបចំសិក្ខាសាលា របាយការណ៍ និងការឆ្លុះបញ្ចាំងពីមេរៀនពិសោធន៍កន្លងមក។

ខ. ធ្វើអធិការកិច្ចរួមគ្នារវាងថ្នាក់ខេត្ត-រាជធានី និងក្រុង ស្រុក ខណ្ឌ ដោយកសាងក្រុមការងារជាក់លាក់ និងចែករំលែកបទពិសោធន៍ទទួលបានពីការធ្វើអធិការកិច្ច។

គ. រៀបចំរបាយការណ៍សាលារៀនដែលបង្ហាញនូវភាពជោគជ័យ និងប្រសិទ្ធភាពនៃការពិនិត្យតាមដាន និងអាចប្រើជាឧបករណ៍ជួយដល់ការរៀនសូត្រ និងកសាងសមត្ថភាព។

ឃ. ពិនិត្យតាមដាន ថ្នាក់រាជធានី ខេត្ត ដើម្បីពិនិត្យ និងវាយតម្លៃលើការប្រែប្រួលជាវិជ្ជមាន។

ង. វាយតម្លៃលទ្ធផលសិក្សារបស់សិស្ស ដែលជាផលសម្រេចឆ្លុះបញ្ចាំងពីការប្រែប្រួលជាវិជ្ជមានរបស់សាលារៀនដែលមានប្រសិទ្ធភាព[6]។

## ២.៥ សមាសភាគទាំង៤នៃការគ្រប់គ្រងតាមសាលារៀន (SBM)

ក្រសួងអប់រំ យុវជន និងកីឡា បាននិងកំពុងយកចិត្តទុកដាក់ក្នុងខ្ពស់ ក្នុងការអភិវឌ្ឍធនធានមនុស្សឆ្ពោះទៅរកសង្គមពុទ្ធិ ប្រកបដោយវិបុលភាព។ ដើម្បីសម្រេចគោលដៅនេះ នាយកសាលា និងគ្រូ

[6] ក្រសួងអប់រំ យុវជន និងកីឡា (សៀវភៅណែនាំការគ្រប់គ្រងតាមសាលារៀន ឆ្នាំ២០១៨)

បង្រៀនត្រូវមានតួនាទីយ៉ាងសំខាន់ ក្នុងការពង្រឹងគុណភាពអប់រំ។

សាលារៀន គឺជាអង្គភាពទទួលខុសត្រូវផ្ទាល់ក្នុងការអភិវឌ្ឍធនធានមនុស្សនៅថ្នាក់មូលដ្ឋាន។ ការគ្រប់គ្រងតាមសាលារៀន (SBM) បានក្លាយជាប្រធានបទដ៏ពេញនិយមក្នុងទស្សវត្សរ៍ចុងក្រោយនេះ។ ការធ្វើវិមជ្ឈការមានលក្ខណៈជាប្រព័ន្ធផ្អែកលើស្វ័យភាពសាលារៀន សំដៅជំរុញការអនុវត្តក្របខណ្ឌច្បាប់ គោលនយោបាយ សេចក្តីណែនាំ និងគោលការណ៍ឱ្យសម្រេចបានតាមចំណុច ដៅនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ ។

ឆ្លើយតបនឹងបរិបទខាងលើ ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំចងក្រងនូវសមាសភាគបួននៃការគ្រប់គ្រងតាមសាលារៀនមានដូចជា (១)ការគ្រប់គ្រងរដ្ឋបាលសាលារៀន (២)ការគ្រប់គ្រងការរៀន និងបង្រៀន (៣)ការគ្រង់គ្រងធនធានមនុស្ស (៤)ការគ្រប់គ្រងហិរញ្ញវត្ថុ ដែលជាមូលដ្ឋានសម្រាប់ជួយដល់នាយកសាលារៀន គ្រូបង្រៀន ក្នុងការអភិវឌ្ឍសាលារៀនដោយចលនា និងប្រើប្រាស់ធនធានមានស្រាប់ក្នុងមូលដ្ឋានប្រកបដោយភាពច្នៃប្រឌិត និងដោះស្រាយបញ្ហាដែលកើតមានឡើងក្នុង សហគមន៍ ដើម្បីជំរុញការសិក្សារបស់សិស្ស ឱ្យមានប្រសិទ្ធភាព និងគុណភាពសំដៅរួមចំណែកកែលម្អជីវភាពរស់នៅរបស់ប្រជាជនឱ្យកាន់តែប្រសើរឡើង ។

### ២.៥.១ ការគ្រប់គ្រងរដ្ឋបាលសាលារៀន

វិស័យអប់រំ ជាមូលដ្ឋានគ្រឹះនៃការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ ការអភិវឌ្ឍវិស័យអប់រំទាមទារឱ្យមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធដើម្បីពង្រឹងគុណភាពនិងប្រសិទ្ធផល។ គុណភាពអប់រំ គឺជាអាទិភាពមួយដែលត្រូវយកចិត្តទុកដាក់។ គុណភាពអប់រំអាស្រ័យលើគុណភាពរបស់នាយកសាលារៀន និងគុណភាពរបស់គ្រូបង្រៀន។

ការអភិវឌ្ឍសាលារៀនទាមទារឱ្យមានការបង្កើតនូវ រចនាសម្ព័ន្ធគ្រប់គ្រងមួយច្បាស់លាស់ ប្រកបដោយការទទួលខុសត្រូវ គណនេយ្យភាព តម្លាភាព ស្របតាមគោលការណ៍អភិបាលកិច្ចជាពិសេស ការគ្រប់គ្រងតាមបែបវិមជ្ឈការ និងវិសហមជ្ឈការ។

ការគ្រប់គ្រងរដ្ឋបាលសាលារៀនអនុវត្តសម្រាប់ជួយដល់ការដឹកនាំ និងគ្រប់គ្រងសាលារៀន សំដៅលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាអប់រំដោយមានការចូលរួមពីថ្នាក់មូលដ្ឋាន ឬសហគមន៍ ដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃការអភិវឌ្ឍមូលដ្ឋានផ្អែកលើចំណេះដឹង។

ការគ្រប់គ្រងរដ្ឋបាលសាលារៀនត្រូវបានបែងចែកជាបីដែលមានតួនាទីខុសៗគ្នាគឺ៖

- គណៈកម្មការអភិវឌ្ឍសាលារៀន ជាក្រុមការងារដែលជាអ្នកទទួលខុសត្រូវក្នុងការដោះស្រាយរាយការណ៍ តាមដានបូកសរុប ផ្តល់ព័តមានចងក្រងភស្តុតាងបានជាប្រចាំរាល់កិច្ចការ និងសកម្មភាពដែលកើតមានឡើងនៅក្នុងសាលារៀន និងនៅក្នុងមូលដ្ឋានដូចជា៖ (១)ការងារត្រៀមឆ្លើយតបគ្រោះមហន្តរាយ (២)ការងារគណនេយ្យភាពសង្គម (៣)ការងារឃោសនាអប់រំ និងបណ្តុះបណ្តាលដល់សហគមន៍ ពីការងារអប់រំសម្រាប់ទាំងអស់គ្នាពិសេសការងារអប់រំកុមារតូច (៤)ការងារជួយដល់កុមារ

ងាយរងគ្រោះមាន កុមារពិការ ជនជាតិភាគតិច និងកុមារក្នុងគ្រួសារជួបការលំបាក ពិសេសកុមារី (៥) ការងារលុបបំបាត់រាល់អំពើហឹង្សា លើផ្លូវកាយ ផ្លូវចិត្ត និងកេងប្រវ័ញ្ចគ្រប់រូបភាពដល់កុមារ (៦) ការងារលើកទឹកចិត្តដល់គ្រូបង្រៀនក្នុងការអនុវត្តតួនាទី និងភារកិច្ច(ម៉ោងសិក្សា) (៧)ការងារគ្រប់គ្រងស្ថិតិទិន្នន័យអប់រំ សុខភាព សេដ្ឋកិច្ច សង្គម (៨) ការងាររៀបចំមណ្ឌលអានសម្រាប់កុមារនៅតាមក្លឹបសិក្សា (៩) ការងារផ្តល់សេវាសុខភាពសុវត្ថិភាព និង(១០)ការងារសុវត្ថិភាពហេដ្ឋារចនាសម្ព័ន្ធ។

- គណៈកម្មការថ្នាក់រៀន ត្រូវស្វែងយល់ពីលទ្ធផលសិក្សារបស់សិស្ស និងការបង្រៀនរបស់គ្រូ តាមរយៈការសង្កេតថ្នាក់រៀន សួរព័ត៌មានពីសិស្ស និងការប្រជុំទៀតទាត់ជាមួយគ្រូ។ រីឯខ្លឹមសារដែលត្រូវស្វែងយល់សម្រាប់ដោះស្រាយបញ្ហារួមគ្នាជាមួយគ្រូរួមមាន ៖ (១)ការមករៀនទៀតទាត់របស់សិស្ស (២)ការមកបង្រៀនទៀតទាត់របស់គ្រូ (៣)ការផ្តល់ព័ត៌មានត្រឡប់ទៅសិស្ស (៤)ការផ្តល់ព័ត៌មានត្រឡប់ទៅឪពុកម្តាយ (៥)សម្ភារឧបទ្ទេស និងសម្ភារសិក្សា (៦)អនាម័យថ្នាក់រៀន (៧)ការធ្វើតេស្តសិស្សទៀតទាត់ និង (៨)លទ្ធផលសិក្សារបស់សិស្ស។

- កម្មវិធីក្រុមប្រឹក្សាកុមារសម្រាប់សាលារៀន គឺការផ្តើមឡើងពីការជួយឱ្យកុមារមាន៖ (១)សមត្ថភាពជួយខ្លួនឯងក្នុងការរៀនសូត្រ (២)សមត្ថភាពសម្របសម្រួលជួយដល់កុមារផ្សេងទៀតក្នុងថ្នាក់រៀន និងសាលារៀន (៣)សមត្ថភាពរាយការណ៍ពីបញ្ហាដែលកើតឡើងចំពោះកុមារក្នុងសាលារៀន និងសហគមន៍ និង (៤)សមត្ថភាពក្នុងការដោះស្រាយបញ្ហា តាមរយៈការចូលរួមប្រជុំជាផ្លូវការ និងមិនផ្លូវការជាមួយអ្នកពាក់ព័ន្ធក្នុងសាលារៀន ដើម្បីអាចធ្វើការតស៊ូមតិអំពីផលប្រយោជន៍របស់កុមារក្នុងការសិក្សារៀនសូត្រ និងការរស់នៅប្រចាំថ្ងៃ។

### ២.៥.២ ការគ្រប់គ្រងការរៀន និងការបង្រៀន

មធ្យោបាយដ៏មានប្រសិទ្ធភាពដែលអាចវាយតម្លៃគុណភាពអប់រំ ពិសេសគុណភាពដែលអាចទាក់ទងនិងលទ្ធផលសិក្សារបស់សិស្សនោះគឺ « តេស្តវង្វាយតម្លៃលទ្ធផលសិក្សា » ដែលជាយន្តការវិទ្យាសាស្ត្រមួយមានជំហ៊ានជាស៊េរីបន្តបន្ទាប់ និងមានបច្ចេកទេសខ្ពស់ក្នុងការអនុវត្តជំហ៊ាននីមួយៗ គឺជាចំណុចអាទិភាពមួយនៃកំណែទម្រង់ទាំង១៥ ចំណុចរបស់ ក្រសួងអប់រំ យុវជន និងកីឡា។

ការធ្វើតេស្តវង្វាយតម្លៃថ្នាក់ជាតិ តំបន់ និងអន្តរជាតិ ត្រូវបានទទួលស្គាល់ និងឱ្យតម្លៃថាមានតួនាទី និងភារកិច្ចយ៉ាងសំខាន់ក្នុងការចូលរួមចំណែកអភិវឌ្ឍធនធានមនុស្ស និងផ្តល់វិភាគទានដល់ អភិវឌ្ឍបុគ្គល គ្រួសារ សង្គមជាតិ និងសកលលោក។ ហេតុនេះដើម្បីធានាឱ្យយន្តការ និងគុណភាពនៃ ការអនុវត្តតេស្តវង្វាយតម្លៃលទ្ធផលសិក្សាកម្រិតសាលារៀនមានសង្គតិភាពជាមួយតេស្តវង្វាយតម្លៃ និងការប្រឡងនានា ចាំបាច់ត្រូវពង្រឹងសមត្ថភាពមន្ត្រីអនុវត្តពាក់ព័ន្ធទាំងអស់កម្រិតសាលារៀនពីការគ្រប់គ្រងការបង្កើតការធ្វើតេស្ត ឬការប្រឡងនានាជាប្រចាំឱ្យមានលក្ខណៈស្តង់ដារួមសម្រាប់កម្រិតសាលារៀន។

ការគ្រប់គ្រងការរៀន និងបង្រៀននៅសាលារៀនគឺសម្រាប់ជួយដល់គ្រូបង្រៀន ប្រធានក្រុមបច្ចេកទេស និងនាយកសាលារៀន ក្នុងការអនុវត្តតេស្តវង្វាយតម្លៃប្រចាំសប្តាហ៍ ប្រចាំខែ ដើមឆ្នាំ និងចុងឆ្នាំឱ្យមាន

លក្ខណៈស្តង់ដាស្របតាមកម្មវិធីសិក្សាដែល ក្រសួងអប់រំ យុវជន និងកីឡា បានកំណត់។ ព័ត៌មាន និងទិន្នន័យដែលទទួលបានពីតេស្តវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្សនឹងអាចជួយកែលម្អ និងលើកកម្ពស់គុណភាពរៀន និងបង្រៀនបានចំគោលដៅទាន់ពេលវេលា ដែលអាចជួយជំរុញឱ្យការបង្រៀនទទួលបាននូវប្រសិទ្ធភាពខ្ពស់។

ការគ្រប់គ្រងការរៀន និងការបង្រៀន គឺនាយកសាលារៀន និងគ្រូបង្រៀន ជាអ្នកទទួលខុសត្រូវក្នុងសកម្មភាពសិក្សារៀនសូត្រ និងលទ្ធផលសិក្សារបស់សិស្ស។ ដើម្បីឱ្យការសិក្សារបស់សិស្សទទួលបានលទ្ធផលល្អ នាយកសាលារៀន និងគ្រូបង្រៀនរៀបចំឱ្យមានយន្តការតាមដាន និងវាយតម្លៃកម្រិតសាលារៀនរួមមួយដែលមានៈ (១)គ្រូបង្រៀនជាអ្នកទទួលខុសត្រូវតាមដាន និងវាយតម្លៃលទ្ធផលសិក្សារបស់សិស្សក្នុងការបង្រៀនមេរៀននីមួយៗ និងការធ្វើតេស្តសិស្សប្រចាំសប្តាហ៍ (២)នាយកសាលាជាអ្នកទទួលខុសត្រូវតាមដាន វាយតម្លៃលទ្ធផលសិក្សារបស់សិស្ស ការបង្រៀនរបស់គ្រូ តាមរយៈការរៀបចំវិញ្ញាសាតេស្តសិស្ស ប្រចាំខែ ចុងឆ្នាំ ដើមឆ្នាំ និងវិញ្ញាសាប្រឡងឆមាសដោយមានការចូលរួមពីក្រុមបច្ចេកទេស គ្រូទទួលបន្ទុកថ្នាក់ (៣)នាយកសាលារៀនជាអ្នកចាត់ចែងនិងដឹកនាំការអនុវត្តតេស្តប្រចាំខែ ប្រឡងឆមាស ដល់សិស្សដោយបែងចែកគ្រូបង្រៀន និងក្រុមបច្ចេកទេសជាអនុរក្ស និងជាអ្នកត្រួតពិនិត្យក្នុងការប្រឡងប្រចាំខែ។

### ២.៥.៣ ការគ្រប់គ្រងធនធានមនុស្ស

ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំគោលនយោបាយស្តីពីធនធានមនុស្សក្នុងវិស័យអប់រំ ដែលមានលក្ខណៈទូលំទូលាយដើម្បីប្រែក្លាយធនធានមនុស្សកាន់តែមានសមត្ថភាពការងារ មានប្រសិទ្ធភាពមានភាពស័ក្តិសិទ្ធិ និងមានការជឿទុកចិត្តក្នុងការផ្តល់ និងគាំទ្រសេវាអប់រំ សំដៅរួមចំណែកអភិវឌ្ឍសមត្ថភាពបុគ្គល និងស្ថាប័នប្រកបដោយឧត្តមភាព។

គោលនយោបាយស្តីពីធនធានមនុស្សក្នុងវិស័យអប់រំ នឹងធនធានមនុស្សមានជំនាញវិជ្ជាជីវៈច្បាស់លាស់មានការទទួលខុសត្រូវខ្ពស់ មានភាពឆ្លើយតប និងត្រូវបានប្រើប្រាស់ទៅតាមតម្រូវការជាក់ស្តែងប្រកបដោយភាពស័ក្តិសិទ្ធិ និងសមធម៌។

គោលនយោបាយបានបង្ហាញពីខ្លឹមសារ យុទ្ធវិធី និងគោលការណ៍អនុវត្តប្រកបដោយប្រសិទ្ធភាពសម្រាប់ការប្រើប្រាស់និងការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យអប់រំ និងបានបង្ហាញផងដែរអំពីសារៈសំខាន់ក្នុងការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស ដែលជាកត្តាឆ្លើយតបទៅនឹងតម្រូវការផ្តល់សេវាអប់រំដែលបុគ្គលនិងគ្រប់អង្គភាពស្របតាមស្តង់ដារជាតិ តំបន់ និងអន្តរជាតិ[7]។

ការគ្រប់គ្រងធនធានមនុស្សសម្រាប់ការគ្រប់គ្រងតាមសាលារៀន SBM គឺធ្វើឡើងសម្រាប់ជួយគ្រូបង្រៀនឱ្យបានរៀនសូត្រជាប្រចាំ និងធ្វើការងារដោយការទទួលខុសត្រូវ។ ការបណ្តុះបណ្តាលគ្រូបង្រៀនបានផ្តល់ឱ្យគ្រូនូវរាល់ការរកឃើញពីរបៀបបង្រៀនថ្មីៗ និងបានផ្លាស់ប្តូរពិសោធន៍គ្នាទៅវិញទៅ

[7] MoEYs គោលនយោបាយស្តីពីធនធានមនុស្សក្នុងវិស័យអប់រំ ២០១២

មកដោយស្របតាមគោលនយោបាយអប់រំរាជរដ្ឋាភិបាល ដែលការបណ្តុះបណ្តាលគ្រូបង្រៀនដើម្បីធ្វើយ៉ាងណាជំរុញឱ្យលទ្ធផលសិក្សារបស់សិស្សមានប្រសិទ្ធភាពតាមរយៈការសិក្សាយ៉ាងសកម្មរបស់ សិស្សនៅសាលារៀន និងនៅផ្ទះ។

ដើម្បីលើកកម្ពស់គុណភាពអប់រំឱ្យបានកាន់តែប្រសើរឡើង យើងត្រូវបង្កើនសមត្ថភាពគ្រូបង្រៀនផ្តល់វិធីសាស្ត្របង្រៀនថ្មីៗ ពង្រឹងការគ្រប់គ្រងថ្នាក់រៀន និងការសហការជាមួយសិស្ស អាណាព្យាបាលសិស្ស ដើម្បីជួយសិស្សក្នុងការរៀនសូត្រឱ្យទទួលបានលទ្ធផលល្អប្រសើរ តាមរយៈគ្រូជួយគ្រូ នៅក្នុងសាលារៀន។ លើសពីនេះទៀតការបង្កើនសមត្ថភាពនាយកសាលារៀន និងក្រុមបច្ចេកទេសក្នុងការដឹកនាំ គ្រប់គ្រង ការបណ្តុះបណ្តាល ក្នុងថ្នាក់រៀនជាការងារដែលត្រូវតែយកចិត្តទុកដាក់ផងដែរ។

ក្រៅពីការបំប៉នសមត្ថភាពនៅក្នុងសាលារៀន ក្រោមការដឹកនាំរបស់នាយកសាលារៀន និងប្រធានក្រុមបច្ចេកទេសគ្រូបង្រៀនក៏អាចមានឱកាសក្នុងការចូលរួមរៀនសូត្រ ពីសំណាក់ការបំប៉ន សមត្ថភាពដែលរៀបចំឡើងដោយការិយាល័យអប់រំស្រុក មន្ទីរអប់រំ ក្រសួងអប់រំ សាលាគរុកោសល្យ អង្គការជាតិ និងអន្តរជាតិ និងស្ថាប័នពាក់ព័ន្ធផ្សេងទៀត។ ការបំប៉នសមត្ថភាពដែលរៀបចំឡើងពីខាងក្រៅក៏បានជួយបន្ថែមចំណេះដឹងដល់គ្រូបង្រៀនមួយចំណែកទៀតដែរ។ តែអ្វីដែលចាំបាច់ ការបំប៉នសមត្ថភាពខាងក្រៅបានផ្សារភ្ជាប់ទៅនឹងការបំប៉នសមត្ថភាពនៅខាងក្នុងសាលារៀន នោះធ្វើឱ្យលទ្ធផលនៃការបំប៉នសមត្ថភាពមានការរីកចំរើនជាប្រចាំជាមួយនឹងបញ្ញត្តិ និងគោលការអប់រំថ្មីៗអាចជួយដល់លទ្ធផលសិក្សារបស់សិស្សឱ្យទទួលបានចំណេះដឹងគ្រប់ជ្រុងជ្រោយ។

ដូច្នេះការខិតខំប្រឹងប្រែងឱ្យសាលារៀនមានសកម្មភាព ក្នុងការគ្រប់គ្រងធនធានមនុស្ស បំប៉នសមត្ថភាពជាប្រចាំតាមរយៈគ្រូជួយគ្រូ ជាពិសេសការប្រជុំឆ្លុះបញ្ចាំងផ្លាស់ប្តូរបទពិសោធន៍ និងសកម្មភាពថ្នាក់និទស្សន៍ នៅចុងខែជាងរៀងរាល់ខែ ក្រោមការគ្រប់គ្រងដឹកនាំ របស់ប្រធានក្រុមបច្ចេកទេស និងនាយកសាលារៀន នឹងជួយពង្រឹងសមត្ថភាពរបស់គ្រូបង្រៀនអំពីការរៀននិងបង្រៀនឱ្យមានការរីកចម្រើន និងបង្កើនភាពជិតស្និតសហការជួយគ្នាបានកាន់តែប្រសើរថែមទៀតក្នុងសាលារៀន។ ដើម្បីអាចធានាបានការបំប៉នសមត្ថភាពនៅសាលារៀនប្រព្រឹត្តទៅប្រកបដោយនិរន្តភាព ចាំបាច់សាលារៀនមានរៀបចំផែនការបំប៉នសមត្ថភាព កម្មវិធីបំប៉នសមត្ថភាព ខ្លឹមសារបំប៉នសមត្ថភាព និងរបាយការណ៍បំប៉នសមត្ថភាពជាប្រចាំក្នុងសាលារៀន[8]។

### ២.៥.៤ ការគ្រប់គ្រងហិរញ្ញវត្ថុ

វិស័យអប់រំជាឆ្អឹងខ្នងនៃការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ។ ដូច្នេះនាយកសាលារៀន ត្រូវចាត់ទុកជាអ្នកមានសក្តានុពលជាកូនសោគន្លឹះដ៏សំខាន់ក្នុងការបង្កើនគុណភាពអប់រំ និងជាអ្នកកំណត់នូវចក្ខុវិស័យរបស់សាលារៀនក្នុងន័យនេះនាយកសាលារៀនត្រូវមានកិច្ចសហការដ៏ជិតស្និទ្ធជាមួយមាតាបិតា អាណាព្យាបាលសិស្ស សហគមន៍ និងស្ថាប័នពាក់ព័ន្ធផ្សេងៗទៀតក្នុងការប្រើប្រាស់ថវិការ ឱ្យមានតម្លាភាព

[8] MoEYs ការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល (ការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀន ២០១៧)

សុចរិតភាព និងចំទិសដៅ តាមផែនការដែលនាយកសាលារៀនបានគ្រោងទុក ដើម្បីជួយអភិវឌ្ឍន៍ កែលម្អសោភ័ណភាពសាលា ការបង្រៀនរបស់គ្រូ និងការសិក្សារបស់សិស្សឱ្យទទួលបានលទ្ធផលល្អប្រសើរជាទីបំផុត និងដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់សិស្ស មាតាបិតាសិស្ស សហគមន៍ ស្របតាមគោលនយោបាយរបស់ក្រសួងអប់រំ យុវជន និងកីឡា ។

ការគ្រប់គ្រងហិរញ្ញវត្ថុរបស់សាលារៀន គឺឆ្លើយតបទៅនឹងការធ្វើកំណែទម្រង់ស៊ីជម្រៅរបស់ក្រសួងអប់រំ យុវជន និងកីឡា ។ ការគ្រប់គ្រងហិរញ្ញវត្ថុជាផ្នែកមួយសំខាន់ក្នុងការជួយគាំទ្រឱ្យសាលារៀនសម្រេចបាននូវផែនការអភិវឌ្ឍ និងធានាឱ្យបាននូវការចូលរៀនរបស់កុមារការកើនឡើង ជាពិសេស ការសិក្សាប្រកបដោយគុណភាព ដែលអាចឆ្លើយតបទៅនឹងតម្រូវការសេដ្ឋកិច្ចសង្គម និងការរីកចម្រើន យ៉ាងឆាប់រហ័សនៃប្រព័ន្ធបច្ចេកវិទ្យាទំនើប ។

ជាមួយគ្នានេះផងដែរ ដើម្បីធានាឱ្យមានដំណើរការនៃការគ្រប់គ្រងហិរញ្ញវត្ថុសាលារៀនប្រកបដោយប្រសិទ្ធភាព សាលារៀនត្រូវរៀបចំឱ្យមានគណៈកម្មការគ្រប់គ្រងក្នុងការអនុវត្តផែនការដោយមានការបែងចែកតួនាទី និងភារកិច្ចទទួលខុសត្រូវច្បាស់លាស់ក្នុងការប្រើប្រាស់ថវិការបស់សាលារៀន ការចូលរួមសម្រេចចិត្ត និងមានការត្រួតពិនិត្យប្រកបដោយគុណភាពពីអ្នកពាក់ព័ន្ធ ។ លើសពីនេះទៀតការរៀបចំរចនាសម្ព័ន្ធនេះ គឺដើម្បីពង្រឹងប្រព័ន្ធធ្វើការងាររួមគ្នា ក្នុងសាលារៀន និងសហគមន៍ ដែលអនុវត្តបានទាំងគុណភាព និងប្រសិទ្ធភាពស្របទៅតាមគោលដៅអភិវឌ្ឍប្រកបដោយចីរភាព ។

## ២.៦ ស្តង់ដាទាំង៩ស្តីពីប្រសិទ្ធភាពការគ្រប់គ្រងតាមសាលារៀន ៖

ក្រសួងអប់រំ យុវជន និងកីឡា ក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ បានរៀបចំផែនការយុទ្ធសាស្ត្រអប់រំឆ្នាំ ២០១៤ ដល់ឆ្នាំ២០១៨ តាមទម្រង់អនុវិស័យក្នុងគោលបំណងបន្សីគ្នារវាងថវិកា និងលទ្ធផលទាំងនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងថ្នាក់ផ្តល់សេវាសាធារណៈ ដែលជាដំណាក់ កាលទី៣ នៃកម្មវិធីកំណែទម្រង់ហរិញ្ញវត្ថុសាធារណៈ ។

កំណែទម្រង់នៃការធ្វើផែនការតាមអនុវិស័យនេះ គឺតម្រូវឱ្យនាយកដ្ឋានដែលពាក់ព័ន្ធទាំងអស់ធ្វើផែនការ អនុវត្តផែនការ ពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តផែនការជាមួយគ្នា ។ ការធ្វើកិច្ចការជាមួយគ្នានេះមានគោលដៅតែមួយ គឺការលើកកម្ពស់គុណភាពសេវាសាធារណៈឱ្យមានស្តង់ដាពេញ លេញតាមស្តង់ដាសាលារៀនមានប្រសិទ្ធភាព និងស្របទៅតាមគោនយោបាយសេវាសាធារណៈរបស់រាជរដ្ឋាភិបាល ។

ស្តង់ដាសាលារៀនមានប្រសិទ្ធភាពមានបែងចែកជាបីប្រភេទ និង៩ស្តង់ដា៖ (១) គោលនយោបាយសាលារៀនមានប្រសិទ្ធភាព ដែលស្របគ្នាជាមួយគោលបំណង គោលនយោបាយថ្នាក់ជាតិមានមួយស្តង់ដា (២) សាលារៀនប្រើប្រាស់ធាតុចូលដែលផ្តល់ពីថ្នាក់ជាតិតាមការណែនាំ និងបទបញ្ញាផ្សេងៗ

មានបួនស្តង់ដា និង (៣) ថ្នាក់ជាតិផលិត និងផ្តល់ធាតុចូលមានគុណភាពដល់សាលារៀន ជាមួយនឹងការពង្រឹងសមត្ថភាពស្ថាប័ន និងមន្ត្រីរាជការមានបួនស្តង់ដា[9] ។

### ២.៦.១ វត្ថុបំណងគោលនយោបាយសាលារៀន

គណៈគ្រប់គ្រងសាលារៀន គឺជាអ្នកមានតួនាទីយ៉ាងសំខាន់ជាទីបំផុត ក្នុងការដឹកនាំនិងគ្រប់គ្រងសាលារៀនឱ្យទទួលបានការអភិវឌ្ឍទាំងស្រុង សំដៅធានាឱ្យបានការចូលរៀនមានការកើនឡើង និងការសិក្សារបស់សិស្សប្រកបដោយគុណភាព ដែលអាចឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់សង្គម ស្របតាមគោលនយោបាយកំណែទម្រង់របស់ក្រសួងអប់រំ យុវជន និងកីឡា ។

គណៈគ្រប់គ្រងសាលារៀន គឺជាអ្នកដែលមានចក្ខុវិស័យ និងគោលដៅជាក់លាក់ក្នុងការដឹកនាំបុគ្គលិកទាំងអស់ក្នុងសាលារៀន ដើម្បីធ្វើការរួមគ្នាជាមួយមាតាបិតាសិស្ស សហគមន៍ និងស្ថាប័នពាក់ព័ន្ធដទៃទៀត ក្នុងការជួយដល់ការសិក្សារបស់សិស្សឱ្យទទួលបានលទ្ធផលប្រសើរជាទីបំផុត ដែលឆ្លើយតបទៅនឹងតម្រូវការរបស់សិស្ស គ្រួសារ និងសហគមន៍ ។

ដើម្បីអាចឱ្យសាលារៀនមានការអភិវឌ្ឍស្របទៅតាម ចក្ខុវិស័យ បេសកកម្ម និងគោលបំណងដូចបានរៀបរាប់ខាងលើ គណៈគ្រប់គ្រងសាលារៀនជាអ្នកមានគំនិតផ្តួចផ្តើមបង្កើតអោយមានគោលនយោបាយ និងនិតិវិធីសម្រាប់គ្រប់គ្រងដំណើរការសាលារៀន ដែលអាចធានាបានការអភិវឌ្ឍឆ្លើយតបទៅនឹងផែនការយុទ្ធសាស្ត្ររបស់ការិយាល័យអប់រំស្រុក មន្ទីរអប់រំខេត្ត និងក្រសួងអប់រំ យុវជន និងកីឡា ។

គោលនយោបាយសាលារៀននិងនិតិវិធីប្រចាំសាលាជាមធ្យោបាយមួយក្នុងការទាក់ទាញការចូលរួមពីសំណាក់អ្នកពាក់ព័ន្ធដើម្បីអភិវឌ្ឍន៍សាលារៀន តាមរយៈសកម្មភាពតម្លាភាព និងភាពស្មោះត្រង់[10] ។

### ២.៦.២ ការបង្រៀន និងបំណែងចែកកម្មវិធីបង្រៀន

នៅក្នុងប្រព័ន្ធមជ្ឈការ ការអភិវឌ្ឍពិនិត្យឡើងវិញការណែនាំ និងការជ្រើសរើសសម្ភារៈគឺជាកាតព្វកិច្ចការិយាល័យកណ្តាល ។ នៅក្នុងការគ្រប់គ្រងតាមសាលារៀន SBM ស្រុក និងសាលារៀនផ្តល់នូវ បរិបទចាំបាច់សម្រាប់ការរៀនសូត្រខណៈពេលដែលអ្នកចូលរួមអាចបង្កើតបាន អនុវត្តបាន និងមានប្រសិទ្ធភាពក្នុងការអនុវត្តវិធីសាស្ត្រថ្មីៗសម្រាប់កម្មវិធីសិក្សានិងការណែនាំ (Wholstetter, kirk, Robertson, Mohrman, 1997) ។ នៅពេលទទួលខុសត្រូវនៃកម្មវិធីសិក្សា និងការណែនាំគឺនៅកម្រិតសាលារៀន នាយកសាលា និងគ្រូបង្រៀននឹងត្រូវបានទទួលខុសត្រូវក្នុងការកំណត់ការផ្លាស់ប្តូរដើម្បីផ្តល់នូវកម្មវិធីសិក្សាដែលមានប្រសិទ្ធភាព ។ ដើម្បីរៀបចំកម្មវិធីសិក្សាប្រសិទ្ធភាពគ្រូបង្រៀន និងអ្នកគ្រប់គ្រងគួរតែពិចារណាអន្តរកម្មជាមួយសមត្ថភាពរបស់គ្រូបង្រៀនក្នុងការសម្របសម្រួលការអនុវត្តរបស់គ្រូបង្រៀន ។ វាក៏គួរជួយសិស្សឱ្យទទួលបានបទពិសោធន៍រៀនសូត្រដែលសមស្របនឹងតម្រូវការនិងលទ្ធផលរបស់ពួក

[9] ក្រសួងអប់រំ យុវជន និងកីឡា (ប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃផ្អែកលើលទ្ធផល អនុវិស័យមធ្យមសិក្សា ឆ្នាំ២០១៥)

[10] ការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផលឯកសារប្រតិបត្តិ គោលនយោបាយ និងនីតិវិធីគ្រប់គ្រងសាលារៀន ២០១៧

គេដែលរំពឹងទុក ។ លើសពីនេះកម្មវិធីសិក្សាគួរស្ថិតនៅក្រោមឧបសគ្គនៃលក្ខណៈដែលមានពីមុនដូចជា គោលដៅជាតិ គោលដៅសាលារៀន ការគ្រប់គ្រងខ្លឹមសារប្រធានបទបច្ចេកវិទ្យាអប់រំ និងធនធាន (Cheng Cheong, 1996) ។ ដូច្នេះការផ្លាស់ប្តូរកម្មវិធីសិក្សានិងការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀនគឺកត្តាសំខាន់ក្នុងការបង្កើនសកម្មភាពបង្រៀន និងរៀននៅតាមសាលារៀន ។

ដំណើរការបង្រៀន និងបំណែងចែកកម្មវិធីបង្រៀន ត្រូវធ្វើតាមលំដាប់លំដោយដែលក្នុងនោះមាន ៖ (១) ការរៀបចំគម្រោងលំនាំបង្រៀនមេរៀននីមួយៗ (២) ការសរសេរកិច្ចតែងការបង្រៀនមួយឬ ពីរម៉ោងសិក្សា (៣) ការដឹកនាំសកម្មភាពរៀន និងបង្រៀន និង (៤) ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សក្រោយពេលរៀនចប់មេរៀនមួយ ។

ដើម្បីរៀបចំគម្រោងលំនាំការបង្រៀន និងបំណែងចែកកម្មវិធីបង្រៀន មេរៀនមួយបានប្រកបដោយគុណភាព លុះត្រាតែគ្រូបង្រៀនបានស្វែងយល់ពីមុខងារ និងសារៈសំខាន់របស់ ៖ (១) សៀវភៅសិក្សាគោល (២) សៀវភៅស្តង់ដាអំណាន និង (៣) ឯកសារកម្មវិធីសិក្សាលម្អិតដើម្បីប្រើប្រាស់ក្នុងការកំណត់ខ្លឹមសារមេរៀន សម្រាប់សិស្សដែលត្រូវរៀន ដោយកំណត់សារៈសំខាន់ដែលមាននៅក្នុង លទ្ធផលសិក្សានិងក្នុងមេរៀននីមួយៗ ហើយឱ្យសិស្សធ្វើសកម្មភាពសិក្សាតាមលំដាប់លំដោយ សកម្មភាពរៀន និងបង្រៀនរបស់គ្រូ ។

លើសពីនេះ ដើម្បីរៀបចំគម្រោងលំនាំបង្រៀន មេរៀនមួយគ្រូបង្រៀនចាំបាច់ស្វែងយល់ ពីស្ថានភាពនិងបរិបទរស់នៅរបស់កុមារ ព្រមទាំងត្រូវដឹងពីសមត្ថភាពមានស្រាប់ និងសមត្ថភាពចាំបាច់ ដើម្បីសម្របសម្រួលការរៀបចំសកម្មភាព និង ខ្លឹមសារបង្រៀនឱ្យបានសមស្រប នឹងឆ្លើយតបទៅនឹងតម្រូវការរបស់សិស្ស[11] ។

### **២.៦.៣ មាតាបិតា និងសហគមន៍ជួយដល់ការរៀនសូត្រ**

ការបង្កើតគណៈកម្មការអភិវឌ្ឍថ្នាក់រៀន ជាមធ្យោបាយសម្រាប់ជួយពង្រឹងគុណភាព និងប្រសិទ្ធភាពលទ្ធផលសិក្សារបស់សិស្សឱ្យទទួលបានកាន់តែប្រសើរឡើងជាងមុន តាមរយៈតភ្ជាប់សកម្មភាពកម្រិត សាលារៀនរវាងគណៈកម្មការអភិវឌ្ឍសាលារៀនទៅជាមួយមាតាបិតា និងអាណាព្យាបាលសិស្សនៅកម្រិតថ្នាក់រៀន ។

កិច្ចការគណៈកម្មការអភិវឌ្ឍថ្នាក់រៀន គឺជាការបង្កើនសកម្មភាពទំនាក់ទំនងរវាងគ្រូបង្រៀនជាមួយមាតាបិតា និងអាណាព្យាបាលសិស្ស ដើម្បីឱ្យមាតាបិតា និងអាណាព្យាបាលសិស្ស បានដឹងពីស្ថានភាពរៀន និងបង្រៀននៅថ្នាក់រៀនដូចជា៖ ការមកបង្រៀនទៀតទាត់របស់គ្រូ ការប្រឹងប្រែងបង្រៀនរបស់គ្រូ ការរៀបចំតុបតែងថ្នាក់រៀន ការវាយតម្លៃការសិក្សារបស់សិស្ស ការផ្តល់ព័ត៌មាន ត្រឡប់អំពីលទ្ធផលសិក្សារបស់សិស្សទៅសិស្ស ទៅឪពុកម្តាយ ការមករៀនទៀងទាត់របស់កូនចៅ ការធ្វើកិច្ចការផ្ទះ

[11] ការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផលឯកសារប្រតិបត្តិ ការបង្រៀន និងបំណែងចែកកម្មវិធីសិក្សា ២០១៧

របស់កូនចៅ ការយកចិត្តទុកដាក់ក្នុងការសិក្សារបស់កូនចៅ ការជួយឱ្យកូនមានសម្ភារៈ សិក្សាគ្រប់គ្រាន់ បរិយាកាសសិក្សាក្នុងថ្នាក់រៀន និងអនាម័យរបស់ថ្នាក់រៀន ។ល។

ជាទូទៅទំនាក់ទំនងរវាងគ្រូ ជាមួយមាតាបិតា និងអាណាព្យាបាលសិស្សគឺមានសារៈសំខាន់ជាទីបំផុតដើម្បីអាចអោយភាគីទាំងអស់ សហការធ្វើការរួមគ្នាដើម្បីសម្រេចគោលដៅរួមក្នុងការជួយឱ្យកូនចៅទទួលបានលទ្ធផលសិក្សាកាន់តែល្អប្រសើរ ឆ្លើយតបទៅនឹងតម្រូវការចាក់ស្តែងរបស់មូលដ្ឋាន ។ ដើម្បីពង្រឹងទំនាក់ទំនងឱ្យបានល្អប្រសើរឡើង សាលារៀនត្រូវជួយសម្របសម្រួល ឱ្យថ្នាក់រៀននីមួយៗមានគណៈកម្មការអភិវឌ្ឍថ្នាក់រៀនដើម្បីអាចប្រមូលផ្តុំកម្លាំងឪពុកម្តាយសិស្ស ជួយដល់គ្រូក្នុងការបង្រៀន និងជួយសិស្សក្នុងការរៀន ។ ការចងក្រងប្រមូលផ្តុំកម្លាំងឪពុកម្តាយ អាណាព្យាបាល សិស្ស និងគ្រូបង្រៀនប្រចាំថ្នាក់ មិនត្រឹមតែបានបង្កើតទំនាក់ទំនងល្អរវាងគ្រូ និងឪពុកម្តាយប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអាចចលនាឱ្យឪពុកម្តាយមួយចំនួន ដែលមានលទ្ធភាពអាចជួយដល់គ្រូបង្រៀនជួបការលំបាក និងជាពិសេសជួយដល់ក្រុមកុមារជួបការលំបាកនៅក្នុងថ្នាក់ និងសាលារៀនផងដែរ ។

ការរៀបចំឱ្យមានការប្រមូលផ្តុំកម្លាំងមាតាបិតា និងអាណាព្យាបាលសិស្សនៅក្នុងក្របខណ្ឌអភិវឌ្ឍន៍ថ្នាក់រៀន ជាមធ្យោបាយជួយឱ្យគ្រូមានការលើកទឹកចិត្តក្នុងការអនុវត្តការងារបង្រៀន និងការគ្រប់គ្រងថ្នាក់ ហើយក៏អាចជាមធ្យោបាយបង្កើនទំនាក់ទំនងគ្នា តាមរយៈការផ្តល់ព័ត៌មានត្រឡប់ទៅ ឪពុកម្តាយវិញរាល់កិច្ចការ និងលទ្ធផលសិក្សារបស់សិស្សមួយចំនួន ពិសេសសិស្សជួបការលំបាកក្នុងការសិក្សា ។ លើសពីនេះទៅទៀតកម្មវិធីនេះបានលើកស្ទួយស្វ័យភាពនៃការទទួលខុសត្រូវរបស់គ្រូបង្រៀនក្នុងការបង្រៀន និងការសហការជាមួយឪពុកម្តាយដើម្បីជួយកូនបានរៀនសូត្រផងដែរ ។ ឧទាហរណ៍ការរៀបចំកម្មវិធីឬកាលវិភាគឱ្យមាតាបិតា និងអាណាព្យាបាលសិស្សបានមកអង្គុយមើលការបង្រៀនរបស់គ្រូឱ្យបានក្នុង១ឆ្នាំយ៉ាងតិច២ដង ។ ពេលមាតាបិតា និងអាណាព្យាបាលសិស្សបានមកសង្កេតថ្នាក់រៀន និងការបង្រៀនរបស់គ្រូ វាជាបច្ច័យមួយជួយឱ្យគ្រូខិតខំប្រឹងប្រែងបង្រៀន និងបានដឹងអំពី កង្វះខាតសម្ភារសិក្សា និងមធ្យោបាយផ្សេងៗគាំទ្រដល់ការសិក្សាសម្រាប់កូនរបស់ខ្លួនផងដែរ[12] ។

សហគមន៍នៅទីនេះជាមាតាបិតាសិស្ស រដ្ឋអំណាចមូលដ្ឋាន និងតំណាងសហគមន៍ដែលជាសមាជិកគណៈកម្មការគ្រប់គ្រងសាលារៀន ។ ការចូលរួមរបស់មាតាបិតា និងសហគមន៍ជួយដល់ការរៀនសូត្ររបស់សិស្សគឺមានដូចជា ៖

១. ការចូលរួមក្នុងការគ្រប់គ្រង ការអនុវត្តការងាររបស់មន្ត្រី និងការពិនិត្យតាមដានសាលារៀន

២. ការធ្វើផែនការ ការគ្រោងថវិកា និងការពិនិត្យថវិកាសាលារៀន

៣. ការចូលរួមក្នុងសកម្មភាពសាលារៀន

៤. គ្រប់គ្រងការសាងសង់សាលារៀន

៥. ជាសមាជិកគណៈកម្មការថ្នាក់រៀន

---

[12] ការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផលឯកសារប្រតិបត្តិ គណៈកម្មការអភិវឌ្ឍថ្នាក់រៀន ២០១៧

៦. ចូលរួមក្នុងការរៀបចំព្រឹត្តការណ៍ ឬពិធីផ្សេងៗនៅសាលារៀន

៧. ជាអ្នកជំនាញបង្ហាញប្រធានបទអ្វីមួយដល់សិស្ស

៨. ជួយរកមូលនិធិសាលារៀន

៩. សង្កេតសកម្មភាពបង្រៀនក្នុងថ្នាក់

១០. ជួយសិស្សអោយអាន និងសិក្សានៅផ្ទះទៀតទាត់

១១. ថែរក្សាហេដ្ឋារចនាសម្ព័ន្ធសាលារៀន

១២. ជួយផ្តល់ធាតុចូលដល់សាលារៀន

១៣. ពង្រឹងតម្លាភាពដល់ការចូលរួមរបស់សហគមន៍

ការចូលរួមរបស់មាតាបិតា និងសិស្សក្នុងការពិនិត្យតាមដានសាលារៀន និងថ្នាក់រៀនមានសារៈសំខាន់ណាស់ដើម្បីបំពេញចន្លោះខ្វះខាតនៃការពិនិត្យតាមដានរបស់នាយកសាលា និងគ្រូបង្រៀន ។

### ២.៦.៤ សិស្ស និងសេវាជួយសិស្ស

កម្មវិធីក្រុមប្រឹក្សាយុវជន និងកុមារ គឺរៀបចំឡើងសម្រាប់ជួយការងារក្នុងសាលារៀន និងផ្តល់ ឱកាសឱ្យកុមារបានសិក្សារៀនសូត្របន្ថែមពីការងារដែលកើតមានឡើង ក្នុងសាលារៀនជាក់ស្តែងមួយចំនួនទាក់ទងទៅនឹងសកម្មភាពហ្វឹកហាត់ដឹកនាំ និងគ្រប់គ្រង ដើម្បីអាចអភិវឌ្ឍបំណិនទទួលខុសត្រូវការត្រិះរិះពិចារណា ការដោះស្រាយបញ្ហា និងការប្រាស្រ័យទាក់ទងបន្ទាប់ពីការសិក្សាមុខវិជ្ជាក្នុងថ្នាក់រៀន ។ លើសពីនេះទៀតក្រុមប្រឹក្សាយុវជន និងកុមារជាផ្នែកនៃការពន្លឿនការងាររបស់សាលារៀនមួយចំនួនដូចជាការសិក្សា ការងារបណ្ណាល័យ ការងារសង្គ្រោះ ការងារជួយសង្គម ការងាររដ្ឋបាល ការងារហិរញ្ញវត្ថុ ការងារផ្សព្វផ្សាយ ការងារសិល្បៈកីឡា ការងារសុខភាព ការងារអនាម័យ បរិស្ថាន ការងារបំណិនជីវិត និងក្លឹបសិក្សាតាមផ្ទះ និងភូមិ ។

ការរៀបចំឱ្យមានកម្មវិធី ក្រុមប្រឹក្សាយុវជន និងកុមារនៅកម្រិតសាលារៀន គឺមានសារៈសំខាន់ជាទីបំផុតក្នុងការសម្របសម្រួលជួយឱ្យសកម្មភាពក្រុមប្រឹក្សាយុវជន និងកុមារ នៅកម្រិតសាលារៀនមានលក្ខណៈជាក់ស្តែងដែលសមស្របទៅនឹងស្ថានភាពរបស់មូលដ្ឋាន និងអាចអនុវត្តបានប្រកបដោយ គុណភាព និង ប្រសិទ្ធភាព ។

ការរៀបចំកម្មវិធីក្រុមប្រឹក្សាយុវជន និងកុមារ នៅកម្រិតសាលារៀន គឺជាគំនិតផ្តួចផ្តើមប្រកបដោយម្ចាស់ការរបស់នាយកសាលារៀនក្នុងការចលនាឱ្យមានការចូលរួមពីសំណាក់អ្នកពាក់ព័ន្ធទាំងឡាយ ក្នុងសាលារៀន និងសហគមន៍ ជាពិសេសទៅទៀត គឺការចលនាឱ្យសិស្សានុសិស្សក្នុងសាលារៀនទាំង អស់បានចូលរួមក្នុងសកម្មភាពក្រុមប្រឹក្សាយុវជន ដែលនឹងនាំមកនូវផលប្រយោជន៍ ដ៏ធំធេងសម្រាប់យុវជនផ្ទាល់ ក្នុងការអភិវឌ្ឍសមត្ថភាពជាកូនល្អ សិស្សល្អ និងមិត្តល្អព្រមទាំងក្លាយជាពលរដ្ឋល្អ ។

ការរៀបចំកម្មវិធីក្រុមប្រឹក្សាយុវជន និងកុមារ នៅកម្រិតសាលារៀន គឺជាការបំលែងគោលបំណង គោលការណ៍ និងខ្លឹមសារសំខាន់ៗដែលមានស្រាប់ក្នុងគោលនយោបាយ សេចក្ដីណែនាំ និងនៅក្នុងឯកសារសំខាន់ៗអំពីសិទ្ធិកុមារ ដែលបានផ្សព្វផ្សាយ និងដាក់ឱ្យប្រើប្រាស់កន្លងមករបស់ក្រសួងអប់រំ យុវជន និងកីឡា ឱ្យក្លាយទៅជាឯកសារសម្រាប់ប្រតិបត្តិជាក់ស្ដែងបាននៅក្នុងសាលារៀន ។

ដូច្នេះសកម្មភាពប្រតិបត្តិទាំងឡាយ នៃការងារក្រុមប្រឹក្សាយុវជន និងកុមារ នៅកម្រិតសាលារៀន គឺជាមធ្យោបាយសម្រាប់ជួយដល់ការបណ្ដុះបណ្ដាលយុវជន បន្ថែមទៀតលើការសិក្សាសម្រាប់មុខវិជ្ជារបស់ក្រសួងអប់រំ យុវជន និងកីឡា ឱ្យមានការអភិវឌ្ឍសមត្ថភាពជាអ្នកដឹកនាំ និងជាអ្នកគ្រប់គ្រងអំពី កិច្ចការអប់រំ សេដ្ឋកិច្ច និងសង្គមក្នុងកម្រិតសាលារៀន និងក្នុងសហគមន៍តាមរយៈការហ្វឹកហាត់ការសម្រេចចិត្ត ការដោះស្រាយបញ្ហា ការចូលរួមសកម្មភាពសង្គម និងការតស៊ូមតិសម្រាប់ជាប្រយោជន៍ ដល់កុមារទាំងក្នុង និងក្រៅសាលារៀន ។

សកម្មភាពប្រតិបត្តិនៃកម្មវិធីក្រុមប្រឹក្សាយុវជន និងកុមារសម្រាប់សាលារៀន គឺការផ្ដើមឡើងពីការជួយឱ្យកុមារមាន ៖ (១) សមត្ថភាពជួយខ្លួនឯងក្នុងការរៀនសូត្រ (២) សមត្ថភាពសម្របសម្រួលជួយដល់កុមារផ្សេងទៀតក្នុងថ្នាក់រៀន និងសាលារៀន (៣) សមត្ថភាពរាយការណ៍ពីបញ្ហាដែលកើតឡើងចំពោះកុមារក្នុងសាលារៀន និងសហគមន៍ (៤) សមត្ថភាពក្នុងការដោះស្រាយបញ្ហាតាមរយៈការចូលរួមប្រជុំជាផ្លូវការ និងមិនផ្លូវការជាមួយអ្នកពាក់ព័ន្ធក្នុងសាលារៀន ដើម្បីអាចធ្វើការតស៊ូមតិអំពីផលប្រយោជន៍កុមារក្នុងការសិក្សារៀនសូត្រ និងការរស់នៅប្រចាំថ្ងៃ[13] ។

ភារកិច្ចក្រុមប្រឹក្សាយុវជន និងកុមារថ្នាក់រៀន និងសាលារៀនមានដូចជា៖

១. ជួយខ្លួនឯងក្នុងថ្នាក់រៀន ។
២. ជួយដល់សិស្សផ្សេងទៀតនៅក្នុងសាលារៀន ។
៣. ជួយដល់សិស្សផ្សេងទៀតនៅក្នុង និងក្រៅសាលារៀន ។
៤. រាយការណ៍ ពីបញ្ហាដែលកើតឡើងចំពោះកុមារនៅសាលារៀន ។
៥. ដោះស្រាយបញ្ហាដែលកើតមានឡើងចំពោះកុមារនៅសាលារៀន ។

### ២.៦.៥ ការដឹកនាំ និងគ្រប់គ្រង

ការងារគ្រប់គ្រងអាចសំដៅលើសកម្មភាពខុសគ្នាជាច្រើន ឧទាហរណ៍ រាជរដ្ឋាភិបាលដឹកនាំប្រទេស និងស្ត្រីមេផ្ទះដឹកនាំគ្រួសារ គឺជាប្រភេទនៃការគ្រប់គ្រងពីរខុសគ្នា អ្នកទាំងពីរចាត់ថាអ្នកគ្រប់ គ្រងដូចគ្នា ។ ការងារវិធីរបៀបប្រព័ន្ធ និងជំនាញដែលចាំបាច់វាខុសគ្នាមែនប៉ុន្តែការដឹកនាំទាំងពីរ គឺជាការគ្រប់គ្រងដូចគ្នា (Yulk, 1989) ។ ក្នុងគម្លាតដ៏ធំរវាងអ្នកគ្រប់គ្រងទាំងពីរ មានអង្គភាព ឬស្ថាប័ន ផ្សេងៗគ្នាជាច្រើនទៀតដែលតែងតែតម្រូវឱ្យមានការងារផ្ទាល់ខ្លួន ។ ប្រភេទនៃការគ្រប់គ្រងដែលចាំបាច់ សម្រាប់អង្គភាព ឬស្ថាប័ននីមួយៗ គឺអាស្រ័យទៅតាមគោលបំណង ទំហំ តម្លៃសីលធម៌របស់អង្គភាព ឬស្ថាប័

[13] ការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផលឯកសារប្រតិបត្តិ ក្រុមប្រឹក្សាយុវជ និងកុមារ ២០១៧

ននោះ ( Hollander, & Offermann, 1990) ។ ប្រសិនបើយើងមកមើលឧទាហរណ៍ខាងលើយើង ឃើញថាបើរាជរដ្ឋាភិបាលប្រឹងប្រែងដឹកនាំប្រទេស ដូចស្ត្រីមេផ្ទះដឹកនាំគ្រួសារ ឬផ្ទុយមកវិញនោះវាជាការមួយមិនល្អឡើយ ព្រោះគេម្នាក់ៗចាំបាច់ត្រូវបំពេញការងារទៅតាមប្រព័ន្ធ និងធនធានដែលសមស្រប តាមទ្រង់ទ្រាយអង្គភាព ឬស្ថាប័នដែលកំពុងព្យាយាមគ្រប់គ្រងនោះ ។ ការស្វែងយល់ពីប្រភេទអង្គភាព ឬស្ថាប័នដែលខ្លួនកំពុងធ្វើការ និងការស្វែងយល់អំពីវិធីខ្លះ និងបែបបទនៃការគ្រប់ គ្រងដូចម្តេចខ្លះ ដែលគេត្រូវការ គឺជាការទទួលខុសត្រូវមួយក្នុងចំណោមយន្តការទទួលខុសត្រូវសំខាន់ៗរបស់អ្នកគ្រប់ គ្រង (Ekvall, & Arvonnen, 1991) ។

ក្នុងករណីដែលអង្គភាព ឬស្ថាប័នដែលមានទំហំធំឡើងអង្គភាព ឬស្ថាប័នត្រូវតែបែងចែកប្រព័ន្ធ និងរចនាសម្ព័ន្ធគ្រប់គ្រង ដើម្បីចែករំលែកការងារ និងភារកិច្ចទទួលខុសត្រូវ ។ នៅក្នុងអង្គភាព ឬស្ថាប័នមួយអាចមានពេលខ្លះត្រូវមានប្រភេទគ្រប់គ្រងផ្សេងៗ ទៅតាមថ្នាក់ខុសៗគ្នាដូចជាការគ្រប់គ្រងថ្នាក់ដំបូង ការគ្រប់គ្រងថ្នាក់កណ្តាល និងការគ្រប់គ្រងថ្នាក់ខ្ពស់ (Keller, 2006) ។

សម្រាប់ការគ្រប់គ្រង គ្មានរូបមន្តងាយស្រួលណាមួយដែលក្រោយពីការរៀនចេះទៅអាចជំរុញឱ្យអ្នកគ្រប់គ្រងធ្វើអ្វីត្រូវជានិច្ច ឬធ្វើការសម្រេច និងគ្រប់គ្រងត្រូវរហូតទេ ។ សិល្បៈនៃការងារគ្រប់គ្រងទាមទារឱ្យអ្នកគ្រប់គ្រងមានជំនាញច្រើន ហើយនឹងជំនាញណាដែលគួរគប្បីយកមកប្រើក្នុងកាលៈទេសៈសមស្របណាមួយ ។ អ្នកគ្រប់គ្រងត្រូវស្វែងយល់ពីស្ថានភាពក្នុង និងបរិយាកាសនៅជុំវិញអង្គភាព ឬស្ថាប័ននោះព្រមទាំងវិធី និងបច្ចេកទេសដើម្បីឆ្លើយតបទៅនឹងស្ថាបភាពទាំងនោះ និងទៅតាមពេលវេលាសមស្របទៀតផង ( Spillane, Halverson , & Diamond, 2004) ។

ការងារគ្រប់គ្រងអាចកំណត់ថា ជាការដាក់ចេញនូវគោលដៅរួមរបស់អង្គភាព ឬស្ថាប័នហើយបន្ទាប់មកធ្វើការសម្រេចថា តើត្រូវប្រើបុគ្គលិក និងធនធានយ៉ាងដូចម្តេច ដើម្បីឈានទៅសម្រេចគោលដៅនោះ ។ ចំណុចនេះមិនត្រឹមតែទាមទារនូវជំនាញសំខាន់ខាងលើទេ ថែមទាំងទាមទារនូវជំនាញ សំខាន់ៗផ្សេងៗទៀតដូចជា សមត្ថភាពទំនាក់ទំនងល្អ ការយល់ និងការដោះស្រាយបញ្ហា ការដឹងថា តើត្រូវប្រើប្រាស់ធនធានបានដូចម្តេច ដើម្បីឱ្យមានប្រសិទ្ធភាពបំផុត (Maxwell, 2007) ។

សរុបមកការងារគ្រប់គ្រងនៃអង្គភាព ឬស្ថាប័នមួយជាដំណើរការប្រើប្រាស់ ដើម្បីដឹកនាំការងាររបស់ខ្លួន និងដើម្បីធ្វើឱ្យប្រាកដថា បុគ្គលិក និងប្រភពធនធានផ្សេងៗទៀតរបស់ខ្លួនត្រូវបានប្រើប្រាស់តាមរបៀបត្រឹមត្រូវមានប្រសិទ្ធភាព និងប្រកបដោយសន្សំសំចៃឆ្ពោះទៅសម្រេចអោយបាននូវគោលដៅរបស់ខ្លួន ។

**២.៦.៦ ធនធានមនុស្ស ៖**

ក្រសួងអប់រំ យុវជន និងកីឡាបានខិតខំប្រឹងប្រែងជាបន្តបន្ទាប់ ក្នុងការបណ្តុះបណ្តាលគ្រូបង្រៀនអំពីវិធីសាស្ត្របង្រៀន ការគ្រប់គ្រងថ្នាក់រៀន និងការសហការជាមួយសិស្ស និងអាណាព្យាបាលសិស្សផ្ទាល់ដើម្បីជួយសិស្សក្នុងការរៀនសូត្រ ឱ្យទទួលបានលទ្ធផលប្រសើរ ។

កម្មវិធីអភិវឌ្ឍសមត្ថភាពគ្រូបង្រៀន ដែលធ្លាប់បានកន្លងមក ទទួលបានជោគជ័យគួរជាទីពេញចិត្ត ជាពិសេសគ្រូបង្រៀន ប្រធានក្រុមបច្ចេកទេស ក្រោមការដឹកនាំរបស់នាយកសាលារៀន ។ ការបំប៉នសមត្ថភាពនៅក្នុងសាលារៀន គឺជាយុទ្ធសាស្ត្រមួយ ក្នុងការលើកកំពស់ការទទួលខុសត្រូវ និងម្ចាស់ការរបស់គ្រូបង្រៀន ប្រធានក្រុមបច្ចេកទេស និងនាយកសាលារៀន ក្នុងការរៀនសូត្រពីគ្នាជាប្រចាំ រាល់ការលំបាក និងបទពិសោធន៍ដែលកើតឡើងជាប្រចាំ ទាក់ទងនឹងការងាររៀន និងបង្រៀនសិស្ស ។

ក្រៅពីការបំប៉នសមត្ថភាពនៅក្នុងសាលារៀន ក្រោមការដឹកនាំរបស់នាយកសាលារៀន និងប្រធានក្រុមបច្ចេកទេស គ្រូបង្រៀនក៏អាចមានឱកាសក្នុងការចូលរួមរៀនសូត្រ ពីសំណាក់ការបំប៉នសមត្ថភាពដែលរៀបចំឡើងដោយការិយាល័យអប់រំស្រុក មន្ទីរអប់រំ ក្រសួងអប់រំ សាលាគរុកោសល្យ អង្គការជាតិ និងអន្តរជាតិ និងស្ថាប័នពាក់ព័ន្ធផ្សេងទៀត ។ ការបំប៉នសមត្ថភាពដែលរៀបចំឡើងពីខាងក្រៅ ក៏បានជួយបន្ថែមចំណេះដឹងដល់គ្រូបង្រៀន មួយចំណែកទៀតដែរ ។ តែអ្វីដែលចាំបាច់ ការបំប៉នសមត្ថភាពនៅខាងក្រៅ បានផ្សារភ្ជាប់ទៅនឹងការបំប៉នសមត្ថភាពនៅខាងក្នុងសាលារៀន នោះធ្វើឱ្យលទ្ធផលនៃការបំប៉នសមត្ថភាព មានការរីកចំរើនជាប្រចាំ ជាមួយនឹងបញ្ញត្តិ និងគោលការណ៍អប់រំថ្មីៗ អាចជួយដល់លទ្ធផលសិក្សារបស់សិស្សឱ្យទទួលបានចំណេះដឹងគ្រប់ជ្រុងជ្រោយ ។

ដូច្នេះការខិតខំប្រឹងប្រែងឱ្យសាលារៀនមានសកម្មភាពបំប៉នសមត្ថភាពជាប្រចាំតាមរយៈគ្រូ ជួយគ្រូ ជាពិសេសការប្រជុំឆ្លុះបញ្ចាំង ផ្លាស់ប្ដូរបទពិសោធន៍ និសកម្មភាពថ្នាក់និទស្សន៍ នៅថ្ងៃរៀងរាល់ចុងខែ ក្រោមការគ្រប់គ្រងដឹកនាំ របស់ប្រធានក្រុមបច្ចេកទេស និងនាយកសាលារៀន នឹងជួយពង្រឹង សមត្ថភាពរបស់គ្រូបង្រៀនអំពីការរៀន និងបង្រៀន ឱ្យមានការរីកចម្រើន និងបង្កើនភាពជិតស្និតសហការជួយគ្នាបានកាន់តែប្រសើរថែមទៀតក្នុងសាលារៀន ។ ដើម្បីអាចធានាបានការបំប៉នសមត្ថភាពនៅសាលារៀនប្រព្រឹត្តទៅប្រកបដោយនិរន្តភាពចាំបាច់សាលារៀនមានរៀបចំផែនការបំប៉នសមត្ថភាព កម្មវិធីបំប៉នសមត្ថភាព ខ្លឹមសារបំប៉នសមត្ថភាព និងរបាយការណ៍សមត្ថភាពជាប្រចាំក្នុងសាលារៀន។

ការរៀបចំឱ្យមានកម្មវិធីអភិវឌ្ឍសមត្ថភាពគ្រូបង្រៀន សម្រាប់សាលរៀនមានប្រយោជន៍ក្នុងការជួយគ្រូឱ្យបានរៀនសូត្រជាប្រចាំ ក្នុងពេលបំពេញការងារ ដែលជាការទទួលខុសត្រូវ និងជាការរៀបចំឡើងដោយភាពម្ចាស់ការរបស់នាយកសាលារៀន និងប្រធានក្រុមបច្ចេកទេសរបស់សាលារៀន ។

សកម្មភាពដែលអាចជួយឱ្យគ្រូបង្រៀនបានរៀនសូត្រជាប្រចាំ គឺការជួយគ្នាទៅវិញទៅមករបស់គ្រូតាមរយៈការរៀនសូត្រពីគ្នាទៅវិញទៅមកជាប្រចាំ ទាក់ទងទៅនឹងខ្លឹមសារ នៃការអនុវត្តវិធីសាស្ត្របង្រៀន ការពិនិត្យតាមដានលទ្ធផលសិក្សារបស់សិស្ស និងការបង្កើតកម្មវិធីផ្សេងៗទៀត ដែលអាចឱ្យសិស្សបន្តរៀនសូត្របាននៅសាលា នៅផ្ទះ នៅភូមិ នៅសហគមន៍ និងនៅកន្លែងផ្សេងទៀត ។

សកម្មភាពអភិវឌ្ឍសមត្ថភាពគ្រូបង្រៀន តាមរយៈសកម្មភាពធ្វើការងារប្រចាំថ្ងៃក្នុងសាលារៀន ក៏ជាមធ្យោបាយដ៏សំខាន់មួយក្នុងការជួយឱ្យគ្រូបង្រៀនបានទំនាក់ទំនងគ្នា និងបង្កើតបាននូវសាមគ្គីភាពល្អ

នឹងគ្នា ក្នុងអង្គភាពសាលារៀនដែលជាគំរូល្អសម្រាប់សិស្ស និងសហគមន៍ លើការជួយសិស្សរៀនយឺត និងសិស្សជួបការលំបាកក្នុងការសិក្សា ។

លើសពីនេះទៅទៀត ទំនាក់ទំនងផ្ទៃក្នុងល្អរវាងគ្រូ និងគ្រូនៅសាលារៀន ក៏ជាបច្ច័យមួយជួយទាក់ទាញដល់សហគមន៍ តាមរយៈការចលនាធនធាន ក្នុងមូលដ្ឋានរួមមានមនុស្ស សម្ភារៈ និងថវិកាសម្រាប់ជួយដល់ការងាររៀន និងបង្រៀន ។ ការសិក្សាបន្ថែមរបស់សិស្ស នៅផ្ទះក៏ជាកិច្ចការដែលឳពុកម្តាយ និងសហគមន៍អាចធ្វើទៅបានដើម្បីបន្តជួយកូនឱ្យបានរៀនសូត្របន្ថែម តាមរយៈក្លឹបសិក្សានៅតាមផ្ទះខ្លួនឯង នៅផ្ទះអ្នកជិតខាង នៅក្នុងសហគមន៍ និងសកម្មភាពចលនាប្រឡងប្រណាំង ក្នុងការប្រកួតប្រជែង ឬការហ្វឹកហាត់ (ភាសាខ្មែរ គណិតវិទ្យា បំណិតជីវិត កំណាព្យ គំនូរ.....) នៃការរៀនផ្សេងទៀតដែលអាចធ្វើទៅបាននៅក្នុងសាលារៀន និងក្នុងសហគមន៍ ។

ដូច្នេះកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀន ក្នុងសាលារៀន គឺជាចលនាធនធានគ្រូ និងបុគ្គលិកនៅក្នុងសាលាឱ្យប្រឹងប្រែងរួមគ្នា និងរៀនសូត្រពីគ្នាទៅវិញទៅមក ក្នុងការជួយសាលារៀន និងសហការគ្នាចលនាធនធានក្នុងសហគមន៍ និងអាចជួយដល់ការបង្កើនលទ្ធផលសិក្សារបស់សិស្ស ទៅតាមកម្រិត នៃស្តង់ដាកម្មវិធីសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡា ។

យោងតាម **Neal (1991, p23)** « ការគ្រប់គ្រងតាមសាលារៀន SBM ធ្វើការសន្មត់ថាធនធានត្រូវបានប្រើយ៉ាងល្អបំផុតនៅកម្រិតដែលពួកគេត្រូវបានប្រើប្រាស់ គណនេយ្យភាពត្រូវបានភ្ជាប់ទៅនឹងការប្រើប្រាស់ធនធានទាំងនោះ » ។ ដូច្នេះនាយកសាលានិងអ្នកពាក់ព័ន្ធត្រូវតែធានាអោយមានការបែងចែកនិងការប្រើប្រាស់ធនធានអប់រំបន្តគោលដៅ ដោះស្រាយបញ្ហានិងធ្វើការសម្រេចចិត្តដោយខ្លួនឯងលក្ខណៈ របស់សាលារៀន និងតម្រូវការដើម្បីកែលម្អ សាលារៀនរបស់ពួកគេ ។

ទិដ្ឋភាពដ៏សំខាន់មួយនៃធនធានមនុស្សរបស់សាលារៀនគឺបុគ្គលិករបស់ខ្លួន ។ សាលារៀនត្រូវការអភិវឌ្ឍជំនាញវិជ្ជាជីវៈដល់បុគ្គលិករបស់ខ្លួនបើសិនជាគេចង់ឱ្យពួកគេអនុវត្តន៍ប្រកបដោយប្រសិទ្ធភាព **(Cheng,1996)** ។

### ២.៦.៧ សៀវភៅសិក្សាគោល និងសម្ភារៈបង្រៀន និងរៀន

ការអប់រំនៅប្រទេសកម្ពុជាមានការខ្វះខាតគ្រូបង្រៀនដែលទទួលការបណ្តុះបណ្តាលគ្រប់គ្រាន់លើវិធីសាស្ត្របង្រៀនថ្មីដែលសង្កត់ធ្ងន់លើការរៀនបែបសកម្មៗ គ្រូបង្រៀនច្រើនតែមានទំនោរផ្តោតការសង្កត់ធ្ងន់លើការទន្ទេញចាំមាត់ ហើយជាលទ្ធផលសិស្សានុសិស្សច្រើនតែគ្មានសមត្ថភាពអាចផ្សារភ្ជាប់អ្វីដែលខ្លួនបានសិក្សាទៅនឹងការដោះស្រាយបញ្ហាប្រចាំថ្ងៃរបស់ខ្លួនបានឡើយ ។ កុមារប្រហែលជាដឹងអំពីព័ត៌មានផ្សេងៗ ប៉ុន្តែជារឿយៗពួកគេមិនយល់អំពីព័ត៌មានទាំងអស់នោះ ឬមិនដឹងអំពីរបៀបប្រើប្រាស់ព័ត៌មានទាំងអស់នោះយ៉ាងដូចម្តេចនោះទេ ។ ការផ្លាស់ប្តូរស្ថានភាពនេះគឺជាបញ្ហាប្រឈមរយៈពេលវែងដែលទាមទារការកែលម្អឡើងវិញនូវកម្មវិធីសិក្សា ការបណ្តុះបណ្តាលគ្រូបង្រៀន និងបុគ្គលិកនៅក្នុង ស្ថាប័នបណ្តុះបណ្តាល និងវិក្រឹតការនាពេលបច្ចុប្បន្ន ។

អន្តរាគមន៍មួយដែលអាចនាំមកនូវការផ្លាស់ប្តូរដ៏ធំធេងគួរឱ្យកត់សម្គាល់ដោយប្រើប្រាស់ពេលវេលាខ្លីសមគួរនោះ គឺសាលារៀនត្រូវមានសៀវភៅសិក្សាគោលដែលលើកកម្ពស់វិធីសាស្ត្របង្រៀន និងរៀនថ្មីៗប្រសិនអាចមានសៀវភៅសិក្សាបែបនេះយ៉ាងទូលំទូលាយនោះ សៀវភៅទាំងនេះនឹងអាចជួយសម្រួលដល់គ្រូបង្រៀន តាមរយៈការផ្តល់ឧទាហរណ៍ស្តីពីវិធីសាស្ត្របង្រៀនថ្មីព្រមទាំងអនុញ្ញាតអោយសិស្សអាចធ្វើអន្តរកម្មជាព័ត៌មានបានបើទោះបីជាគុណភាពនៃការបង្រៀននៅមានកម្រិតក៏ដោយ ។

បច្ចុប្បន្ននេះសៀវភៅសិក្សាគោលសម្រាប់សិស្ស និងសៀវភៅសិក្សាគោលសម្រាប់គ្រូ គឺជាមធ្យោបាយដ៏ចម្បងសម្រាប់គាំទ្រដល់ការបង្រៀន និងរៀននៅតាមសាលារៀនក្នុងប្រទេសកម្ពុជា ។ ការផ្តល់សៀវភៅសិក្សាគោលជាការគាំទ្រចំពោះគោលដៅទូទៅរបស់ការអប់រំ ដើម្បីលើកកម្ពស់គុណភាពនៃការអប់រំកម្រិតមូលដ្ឋាន និងមធ្យមសិក្សាតាមរយៈការផ្តល់សៀវភៅសិក្សាគោលសម្រាប់សិស្ស និងសម្រាប់គ្រូសៀវភៅអំណានបន្ថែម និងសម្ភារៈឧបទ្ទេស ។ល។ ដែលគាំទ្រដល់កម្មវិធីសិក្សា ។ វត្ថុបំណងនៃការផ្តល់សៀវភៅសិក្សាគោលរួមមាន (១) លទ្ធភាពទទួលបានសិស្សានុសិស្សទាំងអស់នៅគ្រប់កម្រិតសិក្សាទាំងកម្រិតមូលដ្ឋាន និងកម្រិតមធ្យមសិក្សាមានលទ្ធភាពទទួលបានសៀវភៅសិក្សាគោលគ្រប់គ្រាន់ ឬមានលទ្ធភាពអាចទិញសៀវភៅសិក្សាផ្សេងទៀតដែលត្រូវបានអនុម័តឱ្យប្រើដោយក្រសួងអប់រំ ។ (២) គុណភាព សៀវភៅសិក្សាគោលដែលត្រូវបានអនុម័តឱ្យប្រើត្រូវមានគុណភាពខ្ពស់ និងគាំទ្រដល់កម្មវិធីសិក្សាសម្រាប់មុខវិជ្ជានីមួយៗនិងគ្រប់កម្រិតថ្នាក់ ។ (៣) ការគាំទ្ររាល់សៀវភៅសិក្សាគោលទាំង អស់ត្រូវមានការគាំទ្រពីសៀវភៅសិក្សាគោលសម្រាប់គ្រូ និងសម្ភារៈឧបទ្ទេសបន្ថែមសម្រាប់ការរៀន និង ការបង្រៀនឱ្យបានច្រើនបំផុតតាមដែលអាចធ្វើបានតាមលទ្ធភាពហិរញ្ញវត្ថុដែលមាន ។

គ្រូបង្រៀនភាគច្រើនមិនមានគុណវុឌ្ឍិគ្រប់គ្រាន់ក្នុងការផ្លាស់ប្តូរការអនុវត្តនៅក្នុងថ្នាក់រៀនពីការសង្កត់ធ្ងន់លើការបង្រៀន និងរៀនដោយវិធីសាស្ត្រទន្ទេញចាំមាត់ (គ្រូមជ្ឈមណ្ឌល) ជំនួសដោយការបង្រៀន និងរៀនដោយវិធីសាស្ត្របែបសកម្ម (សិស្សមជ្ឈមណ្ឌល) ។ ដូចនេះតម្រូវឱ្យការគាំទ្រ និងបំប៉នសមត្ថភាពដល់គ្រូបង្រៀនដើម្បីឱ្យពួកគាត់អាចមានសមត្ថភាពអនុវត្តលើវិធីសាស្ត្របែបសកម្ម (សិស្សមជ្ឈមណ្ឌល) នៅក្នុងថ្នាក់រៀន ។ សៀវភៅសិក្សាសម្រាប់គ្រូគឺជាមគ្គុទ្ទេសក៍ណែនាំអំពីវិធីសាស្ត្របង្រៀននិងរៀនបែបថ្មី (បែបសកម្ម) មានសារៈសំខាន់ណាស់ក្នុងការគាំទ្រដល់គ្រូបង្រៀនដូចដែលបានលើកឡើង ។ ការ គាំទ្របន្ថែមត្រូវផ្តល់ឱ្យតាមរយៈយន្តការបណ្តុះបណ្តាលក្នុងកំឡុងពេលកំពុងបម្រើការងារ (វិក្រឹតការ) ។

កម្មវិធីវិក្រឹតការនឹងជួយដល់គ្រូបង្រៀនក្នុងការបង្កើតសម្ភារឧបទ្ទេសបានដោយខ្លួនឯង ដូចជាសៀវភៅកិច្ចតែងការបង្រៀនជាដើម ។ ការផ្លាស់ប្តូរអាកប្បកិរិយារបស់គ្រូបង្រៀន គឺជាការងារមួយដ៏លំបាកហេតុនេះហើយត្រូវការនូវការគាំទ្រដ៏ធំធេងដើម្បីធានាឱ្យបានថា គ្រូបង្រៀនមានសម្ភារឧបទ្ទេសល្អៗ និងគ្រប់គ្រាន់ដែលនឹងជួយពួកគាត់ក្នុងការអនុវត្តវិធីសាស្ត្របង្រៀន និងរៀនបែបសកម្ម ។

ការផ្តល់សៀវភៅសិក្សាគោលសម្រាប់សិស្ស និងសៀវភៅសិក្សាគោលសម្រាប់គ្រូ គឺជាអាទិភាពបំផុតសម្រាប់ការបង្រៀន និងរៀនប៉ុន្តែសម្ភារឧបទ្ទេសជាពិសេសគឺបន្ថែមអំណាន គឺមានសារៈសំខាន់ណាស់ក្នុងការជួយជម្រុញអោយកុមារមានទម្លាប់ក្នុងការអាន ។

គោលដៅរយៈពេលវែងសម្រាប់សាលាទាំងអស់នៅក្នុងប្រទេសកម្ពុជាគឺការបង្កើតបណ្ណាល័យមួយប្រកបដោយស្តង់ដាដែលបំពាក់ទៅដោយសៀវភៅសិក្សា និងឯកសារគ្រប់គ្រាន់ដើម្បីជម្រុញអោយមានទម្លាប់នៃការអាន និងការសិក្សាស្រាវជ្រាវដែលជាជំនាញដ៏ចាំបាច់មួយសម្រាប់ការរៀនអស់មួយជីវិត ។

បច្ចុប្បន្នអត្រានៃការបាត់បង់សៀវភៅសិក្សាមានកម្រិតខ្ពស់ព្រោះសមត្ថភាពការគ្រប់គ្រង និងថែរក្សាសៀវភៅរបស់មន្ត្រីគ្រប់គ្រងសៀវភៅសិក្សាគោលនៅមានកម្រិត រួមនឹងសាលារៀនមួយចំនួន គ្មានបណ្ណាល័យ ។ ដើម្បីបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងសៀវភៅសិក្សាគោលសាលារៀនចាំបាច់ ត្រូវមាន បណ្ណាល័យប្រកបដោយស្តង់ដា (មានបរិក្ខាររក្សាទុកសៀវភៅ ទូរដាក់ឯកសារ....) និងបំប៉នសមត្ថភាពមន្ត្រីគ្រប់គ្រងសៀវភៅសិក្សា នាយកសាលារៀនស្តីអំពីការគ្រប់គ្រង និងប្រើប្រាស់សៀវភៅសិក្សាគោល។ ការគ្រប់គ្រង នឹងប្រើប្រាស់សៀវភៅសិក្សាគោលបានល្អមានសារៈសំខាន់ណាស់ ដើម្បីរួមចំណែកកាត់បន្ថយការបាត់បង់សៀវភៅសិក្សា និងជួយសម្រេចបានគោលដៅក្នុងការផ្តល់សៀវភៅសិក្សាគោលតាម អត្រាសៀវភៅមួយក្បាលសម្រាប់សិស្សមួយម្នាក់គ្រប់មុខវិជ្ជាដល់សិស្សគ្រប់ៗរូប ។ ការកាត់បន្ថយការបាត់បង់សៀវភៅសិក្សាគោលមានន័យថាយើងអាចផ្ទេរធនធានសម្រាប់យកទៅអភិវឌ្ឍបណ្ណាល័យ [14]។

### ២.៦.៨ ហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថានសាលារៀន

នៅក្នុងកំឡុងពេលមួយទស្សវត្សរ៍ចុងក្រោយនេះ យើងសង្កេតឃើញថាក្រសួងអប់រំ យុវជន និងកីឡាព្រមទាំងដៃគូរអភិវឌ្ឍន៍មួយចំនួន បានបន្តបង្កើនការជួយដល់វិស័យអប់រំទាំងផ្នែកហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងការបណ្តុះបណ្តាលសមត្ថភាពគ្រូ អ្នកដឹកនាំគ្រប់គ្រងសាលារៀន និងអ្នកពាក់ព័ន្ធក្នុងសហគមន៍ដើម្បីបង្កើនសកម្មភាពអន្តរាគមន៍នៅសាលារៀនអោយឆ្លើយតបទៅនឹងចំណុចដៅ ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០១៤-២០១៨ សំដៅលើកកម្ពស់ (១) ការងារដឹកនាំគ្រប់គ្រងសាលារៀន (២) ការដឹកនាំសកម្មភាពរៀន និងបង្រៀន (៣) ការពង្រឹងគុណភាពលទ្ធភាពសិក្សារបស់សិស្ស (៤) ស្វ័យវាយតម្លៃកែលម្អសាលារៀន ។

ហេដ្ឋារចនាសម្ព័ន្ធសាលារៀននិងបរិស្ថានសាលារៀន គឺសំដៅលើអគារសិក្សាដែលមានដូចជា ៖ អគារបន្ទប់រៀន អគារទីចាត់ការសាលារៀន អគារបណ្ណាល័យ មណ្ឌលធនធានឬរោងជាង រីឯសង្ហារឹមមានដូចជា ក្តារខៀន តុ កៅអីរបស់សិស្ស និងគ្រូទទួលបន្ទុកថ្នាក់ កង្ហារ ព្រមទាំងបរិក្ខាអប់រំមានដូចជា កុំព្យូទ័រ ម៉ាស៊ីនបញ្ចាំង ម៉ាស៊ីនថតចម្លង ម៉ាញ៉េ ទូរទស្សន៍ ។ ចំពោះហេដ្ឋារចនាសម្ព័ន្ធអនាម័យសាលារៀនមានដូចជា កន្លែងលាងដៃ ធុងចម្រោះទឹក អណ្តូងទឹកឬប្រព័ន្ធទឹកស្អាត បង្គន់អនាម័យ ឡដុតសំរាម ចំណែកង

[14] MoEYs (គោលនយោបាយស្តីពីសៀវភៅសិក្សា និងមគ្គុទេសក៍សម្រាប់ការអភិវឌ្ឍសៀវភៅសិក្សាគោល ២០១២)

ហេដ្ឋារចនាសម្ព័ន្ធសុវត្ថិភាពសាលារៀនរួមមាន របងសាលារៀនកន្លែងទុកដាក់កង់ម៉ូតូ របងព័ទ្ធធ្វើគម្រប និងដាក់ស្លាកសញ្ញាសម្គាល់នៅកន្លែងដែលពុំមានសុវត្ថិភាព និងហេដ្ឋារចនាសម្ព័ន្ធសម្រាប់សកម្មភាពបំណិនជីវិត ដើមឈើ និងសួនលម្អក្នុងសាលារៀនរួមមាន សួនកូនព្រៃធម្មជាតិ « រុក្ខជាតិឱសថ រុក្ខជាតិសម្រាប់បរិភោគ រុក្ខជាតិសម្រាប់លម្អ..... » សួនរុក្ខជាតិទឹក គោក អាកាស « រុក្ខជាតិឱសថ រុក្ខជាតិសម្រាប់បរិភោគ រុក្ខជាតិសម្រាប់លម្អ.....» សួនបន្លែគ្រួសារ សួនផ្កា ដំណាំ និងដើមឈើហូបផ្លែនិងឈើមានតម្លៃ សួនកុមារ « សម្រាប់កុមារលេង » ។ សាលារៀននីមួយៗនឹងត្រូវយកចិត្តទុកដាក់រៀបចំបង្កើតថែទាំ និងជួសជុលរាល់ហេដ្ឋារចនាសម្ព័ន្ធរបស់សាលារៀនដែលមានស្រាប់ និងបន្តការកសាងអគារសិក្សាបន្ថែមទៀតដើម្បីស្របតាមតម្រូវការ និងកំណើនរបស់សិស្ស ។

### ២.៦.៩ ហិរញ្ញប្បទាន និងការគ្រប់គ្រងហិរញ្ញវត្ថុ

ដើម្បីឆ្លើយតបទៅនឹងការធ្វើកំណែទម្រង់ស៊ីជម្រៅ របស់ក្រសួងអប់រំ យុវជន និងកីឡា ការគ្រប់គ្រងថវិកាជាផ្នែកមួយយ៉ាងសំខាន់ក្នុងការជួយគាំទ្រឱ្យសាលារៀនសម្រេចទទួលបានជោគជ័យ ក្នុងភារកិច្ចប្រមូលកុមារចូលរៀន និងបង្កើនគុណភាពលទ្ធផលសិក្សារបស់សិស្ស ។

ដើម្បីធានាឱ្យមានដំណើរការនៃការគ្រប់គ្រងថវិកាសាលារៀនប្រកបដោយតម្លាភាព និងប្រសិទ្ធភាពសាលារៀនត្រូវរៀបចំឱ្យមានគណៈកម្មការគ្រប់គ្រងថវិកា ដោយបែងចែកតួនាទី និងភារកិច្ចទទួលខុសត្រូវ ក្នុងការប្រើ ទទួល ទុកដាក់ ចំណាយ និងផ្សព្វផ្សាយពីថវិការបស់សាលារៀន ជាមួយការចូលរួមសម្រេចចិត្ត និងការត្រួតពិនិត្យប្រកបដោយគុណភាពពីអ្នកពាក់ព័ន្ធ ។

ដូច្នេះនាយកសាលាត្រូវដឹកនាំរៀបចំ ចងក្រង និងផ្សព្វផ្សាយ គោលការណ៍ និងសេចក្តីណែនាំស្តីពីការគ្រប់គ្រងថវិកាសាលារៀន ដោយមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធ ប្រកបដោយតម្លាភាព និងគណនេយ្យភាព ។

ការរៀបចំឱ្យសាលារៀន អោយមានគោលការណ៍គ្រប់គ្រងថវិកា គឺជាប្រការដ៏ចាំបាច់បំផុតដើម្បីប្រមូលផ្តុំកម្លាំងក្នុងការគ្រប់គ្រងថវិកា ដែលបង្កើនអោយមានការចូលរួមទទួលខុសត្រូវ កសាងទំនុកចិត្ត និងសម្រេចផែនការអភិវឌ្ឍសាលារៀនប្រកបដោយតម្លាភាព ។

ជាធម្មតានៅក្នុងសាលារៀន ការគ្រប់គ្រងថវិកាចាំបាច់ទាមទារ អោយមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធសំខាន់ៗ មានដូចជា គណៈកម្មការអភិវឌ្ឍសាលារៀន គណៈគ្រប់គ្រងសាលារៀន គណៈកម្មការគ្រប់គ្រង និងប្រើប្រាស់ថវិកា និងអ្នកពាក់ព័ន្ធមួយចំនួនទៀតដែលចាំបាច់ ចូលរួមដឹងឮពីចំណូល ការទុកដាក់ និងការចំណាយទាំងឡាយដែលសាលារៀនមាន ទៅតាមកាលកំណត់ណាមួយដែលបានព្រមព្រៀងគ្នា ។ នេះគឺជាការបង្ហាញឱ្យឃើញពីការចែករំលែកការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធទាំងអស់ក្នុងការជួយជ្រោមជ្រែងសាលារៀនអោយមានការរីកចម្រើននិងបង្កើននូវគុណភាពអប់រំផងដែរ ។

ការបង្កឱកាសឱ្យមានការចូលរួមពីសមាសភាពផ្សេងៗ ដូចបានរៀបរាប់ខាងលើ គឺជាមូលដ្ឋានសំខាន់ដែលធ្វើឱ្យមានតម្លាភាព និងមានទំនុកចិត្តពីគ្រប់អ្នកពាក់ព័ន្ធទាំងអស់ លើការគ្រប់គ្រងថវិកា

សាលារៀន ជាពិសេសឪពុកម្តាយ អាណាព្យាបាលសិស្ស អាជ្ញាធរដែនដី និងភាគីទាំងឡាយណាដែលធ្វើការជាមួយសាលារៀន ។ លើសពីនេះទៅទៀតការរៀបចំឱ្យមានយន្តការគ្រប់គ្រងថវិកាសាលារៀនក៏ជាចំណែកមួយក្នុងការលើកស្ទួយឱ្យមានការទទួលខុសត្រូវ និងភាពជាម្ចាស់ការពីគ្រប់អ្នកពាក់ព័ន្ធដែលទាក់ទងទៅនឹងការងារអភិវឌ្ឍសាលារៀនដូចជា៖ ការជួយដល់សិស្សជួបការលំបាក ការជួយគ្រូជួបការលំបាក និងសកម្មភាពផ្សេងៗទៀតក្នុងការអភិវឌ្ឍសាលារៀន ។

ការរៀបចំឱ្យមានគោលការណ៍ថវិកាសាលារៀន គឺជាមូលដ្ឋានសំខាន់សម្រាប់រួមចំណែកក្នុងការរៀបចំថវិការអភិវឌ្ឍសាលារៀន និងជួយគៀរគរថវិកាផ្សេងទៀត ក្រៅពីថវិកាដែលសាលារៀនមានស្រាប់ ។ ដោយសារសាលារៀនមានគោលការណ៍គ្រប់គ្រងថវិកានេះហើយ ដែលធ្វើឱ្យក្រុមប្រឹក្សាឃុំ បានដឹងពីការចូលរួមចំណែកថវិកាសម្រាប់ការងារអប់រំក្នុងផែនការវិនិយោគឃុំ ។ ចំណែកអ្នកពាក់ព័ន្ធផ្សេងៗដូចជាឪពុកម្តាយ អាណាព្យាបាលសិស្សដែលមានជីវភាពធូរធារ ក៏អាចមានលទ្ធភាពក្នុងការជួយទៅដល់ការអភិវឌ្ឍសាលារៀន ជាពិសេសគឺគុណភាពនៃការរៀនសូត្ររបស់កុមារទាំងអស់ រួមមានកុមារជួបការលំបាក កុមារពិការ កុមារក្រីក្រ និងកុមារជនជាតិដើមភាគតិច ។

# ជំពូកទី៣
# វិធីសាស្ត្រស្រាវជ្រាវ

# ជំពូកទី៣
# វិធីសាស្ត្រនៃការស្រាវជ្រាវ

## ៣.១ ព័ត៌មានទូទៅនៃគម្រោងស្រាវជ្រាវ

ការស្រាវជ្រាវនេះ ត្រូវបានរៀបចំធ្វើឡើងដោយប្រើទិន្នន័យបរិមាណវិស័យ និងគុណវិស័យដែលបានយកមកវិភាគ ដើម្បីស្វែងយល់ពីប្រសិទ្ធភាពនៃការអនុវត្តការគ្រប់គ្រងតាមសាលារៀននៅមធ្យមសិក្សាបឋមភូមិនៅតាមគ្រឹះស្ថានសិក្សាដែលជាគោលដៅនៃការស្រាវជ្រាវលើប្រធានបទនេះ ។

## ៣.២ ទីកន្លែងសិក្សាស្រាវជ្រាវ

ការសិក្សានេះជ្រើសរើសយករាជធានីភ្នំពេញជាទីតាំងសម្រាប់ធ្វើការប្រមូលទិន្នន័យ ។ ដូចដែលបានរៀបរាប់ក្នុងជំពូកទី១ខាងលើ ការស្រាវជ្រាវនេះមានវត្ថុបំណងសំខាន់ៗចំនួនពីរគឺ ៖

(១) សិក្សាពីប្រសិទ្ធភាពការអនុវត្តការគ្រប់គ្រងតាមសាលារៀនលើមធ្យមសិក្សាបឋមភូមិ ។

ដោយផ្អែកទៅលើកត្តា ភេទ កម្រិតនៃការអប់រំ ប្រភេទសមាជិក កម្រិតវិជ្ជាជីវៈ និងបទពិសោធន៍ ។ ដើម្បីសម្រេចបាននូវវត្ថុបំណងខាងលើនេះ វិធីសាស្ត្រស្រាវជ្រាវបែបបរិមាណវិស័យ និងគុណវិស័យព្រមទាំងបូកផ្សំជាមួយនឹងព័ត៌មានពីការអង្កេតផ្ទាល់របស់អ្នកស្រាវជ្រាវ ទៅលើស្ថានភាពជាក់ស្តែងរបស់វិទ្យាល័យនីមួយៗដែលបានជ្រើសរើសទាំងនោះ ។

## ៣.៣ ការជ្រើសរើសសំណាក

ភាគសំណាកសម្រាប់ការស្រាវជ្រាវនេះរួមមាននាយកសាលា ០៧ នាក់ លោកគ្រូ-អ្នកគ្រូ ៥៧ នាក់ សិស្សានុសិស្ស ១៥០នាក់ សហគមន៍ និងគណៈកម្មការគ្រប់គ្រងសាលារៀន ២១នាក់ ដែលបានជ្រើសរើសចេញពី វិទ្យាល័យចំនួន ០៧ ក្នុងខណ្ឌចំនួន៦ នៅក្នុងរាជធានីភ្នំពេញតែប៉ុណ្ណោះ ។ សូមបញ្ជាក់ផងដែរ រាជធានីភ្នំពេញមានខណ្ឌចំនួន១៤ និងមានវិទ្យាល័យចំនួន៣៧ ដែលក្នុងនោះវិទ្យាល័យមានការអនុវត្តការគ្រប់គ្រងតាមសាលារៀនមានចំនួន៧សាលា ។ ក្នុងនេះផងដែរយើងបានជ្រើសរើសដែលអនុវត្តការគ្រប់គ្រងតាមសាលារៀនទាំង៧ដែលស្មើ១០០% នៃវិទ្យាល័យដែលមានការអនុវត្តការគ្រប់គ្រងតាមសាលាទាំងអស់ក្នុងរាជធានីភ្នំពេញ ។ មូលហេតុដែលអ្នកសិក្សាស្រាវជ្រាវរើសយកវិទ្យាល័យទាំង៧គឺដើម្បីយកមកធ្វើការប្រៀបធៀបគ្នាលើផ្នែកមួយចំនួនលើប្រសិទ្ធភាពនៃការអនុវត្តការគ្រប់គ្រងតាមសាលារៀន ធៀបនឹងស្តង់ដាសាលារៀនមានប្រសិទ្ធភាព ។ រីឯសំណាកដែលត្រូវជ្រើសរើសមកបំពេញកម្រងសំណួរ និងសម្ភាស គឺយើងធ្វើការជ្រើសរើសតាមទំហំ និងស្ថានភាពសាលារៀនចំពោះ គ្រូ និងសិស្ស ។ ចំណែកនាយកសាលា (១នាក់ក្នុងមួយសាលារៀន) សហគមន៍ និងគណៈកម្មការគ្រប់គ្រងសាលារៀន (៣នាក់ក្នុងមួយសាលា) យើងបានធ្វើការណាត់ជួបភាគសំណាកទាំងអស់ជាមុនទៅតាមពេលវេលាដែលបានកំណត់ ។

## ៣.៤ ឧបករណ៍ស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះត្រូវបានរៀបចំជាលក្ខណៈបរិមាណវិស័យ និងគុណវិស័យដែលមានការចូលរួមពីភាគីពាក់ព័ន្ធដូចជា នាយក គ្រូ សិស្ស សហគមន៍ និងគណៈកម្មការគ្រប់គ្រងសាលារៀន ។ ចំពោះឧបករណ៍ស្រាវជ្រាវ អ្នកសិក្សាស្រាវជ្រាវ បានរៀបចំបង្កើតកម្រងសំណួរដែលជា លក្ខណៈ កម្រិតចម្លើយ និងសំណួរទម្រង់បើកសម្រាប់នាយក លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស សហគមន៍និង គណៈកម្មាការគ្រប់គ្រងសាលារៀន ។ កម្រងសំណួរមានបួនប្រភេទត្រូវបានបង្កើតឡើងដើម្បីប្រមូលទិន្នន័យរួមមាន ៖

កម្រងសំណួរសម្រាប់នាយកសាលា សម្រាប់លោកគ្រូ-អ្នកគ្រូ សម្រាប់សិស្សានុសិស្ស និងសម្រាប់សហគមន៍និងគណៈកម្មាការគ្រប់គ្រងសាលារៀន ។ ក្នុងការសិក្សាស្រាវជ្រាវនេះយើងប្រើប្រាស់កម្រងសំណួរចំនួន០៧ច្បាប់ សម្រាប់នាយក ៥៧ច្បាប់ សម្រាប់គ្រូបង្រៀន ១៥០ច្បាប់សម្រាប់សិស្ស ២១ច្បាប់ សម្រាប់សហគមន៍ និងគណៈកម្មាការគ្រប់គ្រងសាលារៀន សរុបទាំងអស់មាន ២៣៥ច្បាប់ ។ ក្នុងការបង្កើតកម្រងសំណួរនេះយើងខ្ញុំបានរៀបចំតាក់តែងខ្លឹមសារកម្រងសំណួរ ស្របនឹងឧបករណ៍វាយតម្លៃការអនុវត្តសាលារៀនផ្អែកតាមស្តង់ដាសាលារៀនមានប្រសិទ្ធភាព ។

## ៣.៥. កម្រងសំណួរ និងគោលបំណងនៃកម្រងសំណួរ

កម្រងសំណួរសម្រាប់នាយកសាលា សម្រាប់លោកគ្រូ-អ្នកគ្រូ សម្រាប់សិស្សានុសិស្ស និងសម្រាប់សហគមន៍និងគណៈកម្មាការគ្រប់គ្រងសាលារៀន បានធ្វើការដកស្រង់ចេញពីឧបករណ៍វាយតម្លៃការអនុវត្តសាលារៀនផ្អែកតាមស្តង់ដាសាលាមានប្រសិទ្ធភាព ។

### ៣.៥.១ កម្រងសំណួរសម្រាប់នាយក

កម្រងសំណួរសម្រាប់នាយក បែងចែកចេញជាពីរគឺ កម្រងសំណួរទម្រង់បិទ និងកម្រងសំណួរសម្រាប់សម្ភាស ៖

ក. កម្រងសំណួរទម្រង់បិទបែងចែកជាពីរផ្នែកគឺ៖

- ផ្នែកទី១ ព័ត៌មានផ្ទាល់ខ្លួន ក្នុងផ្នែកនេះមាន៥សំណួរ ។ អ្នកស្រាវជ្រាវចង់ដឹងអំពីភេទ កម្រិតវប្បធម៌ ប្រភេទសមាជិក អំពីកម្រិតវិជ្ជាជីវៈ និងបទ ពិសោធន៍ការងារអ្នកបំពេញកម្រងសំណួរ ។
- ផ្នែកទី២ ប្រសិទ្ធភាពនៃការអនុវត្តការគ្រប់គ្រងតាមសាលារៀន ក្នុងផ្នែកនេះអ្នកស្រាវជ្រាវចង់ស្វែងរកឱ្យឃើញពីចំណុចមួយចំនួននៃការអនុវត្តការគ្រប់គ្រងតាមសាលារៀនដែលបានអនុវត្តថាតើមានប្រសិទ្ធភាពដល់កម្រិតណាទាក់ទងនឹង ៖

(១) វត្ថុបំណងគោលនយោបាយសាលារៀន

(២) ការដឹកនាំ និងការគ្រប់គ្រងសាលារៀន

(៣) ធនធានមនុស្ស

(៤) សៀវភៅសិក្សាគោល និងសម្ភារៈរៀន និងបង្រៀន

(៥) ហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថានសាលារៀន

(៦) ហិរញ្ញប្បទាន និងការគ្រប់គ្រងហិរញ្ញវត្ថុ

ខ. កម្រងសំណួរសម្រាប់សម្ភាស គឺចង់វាស់ស្ទង់មតិរបស់លោកនាយកពីការអនុវត្តការគ្រប់គ្រងតាមសាលារៀន ធៀបទៅនឹងស្តង់ដាសាលាមានប្រសិទ្ធភាព ។

### ៣.៥.២ កម្រងសំណួរសម្រាប់គ្រូ

កម្រងសំណួរសម្រាប់គ្រូ បែងចែកចេញជាពីរគឺ កម្រងសំណួរទម្រង់បិទ និងកម្រងសំណួរសម្រាប់សម្ភាស ៖

ក. កម្រងសំណួរទម្រង់បិទបែងចែកជាពីរផ្នែកគឺ៖

- ផ្នែកទី១ ព័ត៌មានផ្ទាល់ខ្លួន ក្នុងផ្នែកនេះមាន៥សំណួរ ។ អ្នកស្រាវជ្រាវចង់ដឹងអំពីភេទ កម្រិតវប្បធម៌ ប្រភេទសមាជិក អំពីកម្រិតវិជ្ជាជីវៈ និងបទពិសោធន៍ការងារអ្នកបំពេញកម្រងសំណួរ ។

- ផ្នែកទី២ ប្រសិទ្ធភាពនៃការអនុវត្តការគ្រប់គ្រងតាមសាលារៀន ក្នុងផ្នែកនេះអ្នកស្រាវជ្រាវចង់ស្វែងរកឱ្យឃើញពីចំណុចមួយចំនួននៃការអនុវត្តការគ្រប់គ្រងតាមសាលារៀនដែលបានអនុវត្តថាតើមានប្រសិទ្ធភាពដល់កម្រិតណាទាក់ទងនឹង ការបង្រៀន និងការរៀន ។

ខ. កម្រងសំណួរសម្រាប់សម្ភាស គឺចង់វាស់ស្ទង់មតិរបស់លោកនាយកពីការអនុវត្តការគ្រប់គ្រងតាមសាលារៀន ធៀបទៅនឹងស្តង់ដារសាលាមានប្រសិទ្ធភាព ។

### ៣.៥.៣ កម្រងសំណួរសម្រាប់សិស្ស

កម្រងសំណួរសម្រាប់សិស្ស បែងចែកចេញជាពីរគឺ កម្រងសំណួរទម្រង់បិទ និង កម្រងសំណួរសម្រាប់សម្ភាស ៖

ក. កម្រងសំណួរទម្រង់បិទចែកជាពីរផ្នែកគឺ៖

- ផ្នែកទី១ ព័ត៌មានផ្ទាល់ខ្លួន ក្នុងផ្នែកនេះមាន៥សំណួរ ។ អ្នកស្រាវជ្រាវចង់ដឹងអំពីភេទ កម្រិតវប្បធម៌ ។

- ផ្នែកទី២ ប្រសិទ្ធភាពនៃការអនុវត្តការគ្រប់គ្រងតាមសាលារៀនក្នុងផ្នែក នេះអ្នកស្រាវជ្រាវចង់ស្វែងរកឱ្យឃើញពីចំណុចមួយចំនួននៃការអនុវត្តការគ្រប់គ្រងតាមសាលារៀនដែលបានអនុវត្តថាតើមានប្រសិទ្ធភាពដល់កម្រិតណាទាក់ទងនឹង សិស្ស និងសេវាជួយសិស្ស ។

ខ. កម្រងសំណួរសម្រាប់សម្ភាស គឺចង់វាស់ស្ទង់មតិរបស់លោកនាយកពីការអនុវត្តការគ្រប់គ្រងតាមសាលារៀន ធៀបទៅនឹងស្តង់ដារសាលាមានប្រសិទ្ធភាព ។

### ៣.៥.៤ កម្រងសំណួរសម្រាប់សហគមន៍ និងគណៈកម្មការគ្រប់គ្រងសាលារៀន

កម្រងសំណួរសម្រាប់សហគមន៍ និងគណៈកម្មការគ្រប់គ្រងសាលារៀនត្រូវបែងចែកចេញជាពីរគឺ កម្រងសំណួរទម្រង់បិទ និង កម្រងសំណួរសម្រាប់សម្ភាស ៖

ក. កម្រងសំណួរទម្រង់បិទចែកជាពីរផ្នែកគឺៈ

- ផ្នែកទី១ ព័ត៌មានផ្ទាល់ខ្លួន ក្នុងផ្នែកនេះមាន៥សំណួរ ។ អ្នកស្រាវជ្រាវចង់ដឹងអំពីភេទ កម្រិតវប្បធម៌ ប្រភេទសមាជិក អំពីកម្រិតវិជ្ជាជីវៈ និងបទពិសោធន៍ការងារអ្នកបំពេញកម្រងសំណួរ ។

- ផ្នែកទី២ ប្រសិទ្ធភាពនៃការអនុវត្តការគ្រប់គ្រងតាមសាលារៀនក្នុងផ្នែក នេះអ្នកស្រាវជ្រាវចង់ស្វែងរកឱ្យឃើញពីចំណុចមួយចំនួននៃការអនុវត្តការគ្រប់គ្រងតាមសាលារៀនដែលបានអនុវត្តថាតើមានប្រសិទ្ធភាពដល់កម្រិតណាទាក់ទងនឹង មាតាបិតា និងសហគមន៍ជួយការសិក្សាសិស្ស ។

ខ. កម្រងសំណួរសម្រាប់សម្ភាស គឺចង់វាស់ស្ទង់មតិរបស់លោកនាយកពីការអនុវត្តការគ្រប់គ្រងតាមសាលារៀន ធៀបទៅនឹងស្តង់ដារសាលាមានប្រសិទ្ធភាព ។

## ៣.៦ ដំណើរការប្រមូលទិន្នន័យ

មុនពេលផ្តល់កម្រងសំណួរនេះដល់អ្នកចូលរួមផ្តល់ព័ត៌មាន ជាដំបូងអ្នកស្រាវជ្រាវបានធ្វើលិខិតស្នើសុំចុះប្រមូលទិន្នន័យពីវិទ្យាស្ថានជាតិអប់រំ បន្ទាប់មកយកទៅប្រគល់ជូនមន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ ដើម្បីសុំលិខិតអនុញ្ញាតចុះប្រមូលទិន្នន័យស្រាវជ្រាវ បន្ទាប់ពីបានលិខិតអនុញ្ញាតពីលោកប្រធានមន្ទីរអប់រំ យុវជន និងកីឡា រួចមកអ្នកស្រាវជ្រាវក៏បានយកលិខិតស្នើសុំនោះទៅប្រគល់ជូនលោកនាយកសាលារៀន និងដើម្បីសុំការអនុញ្ញាតក្នុងការចុះប្រមូលទិន្នន័យព្រមទាំងសម្ភាសលើសំណាក ដែលមាននាយក គ្រូ សិស្ស សហគមន៍ និងគណៈកម្មការគ្រប់គ្រងសាលារៀន ។ បន្ទាប់មកទៀតអ្នកស្រាវជ្រាវក៏បានផ្តល់កម្រង សំណួរដល់ នាយក គ្រូ សិស្ស សហគមន៍ និងគណៈកម្មការគ្រប់គ្រងសាលារៀន ដើម្បីបំពេញ និងធ្វើការសម្ភាស ។

## ៣.៧ ការវិភាគទិន្នន័យ

ការវិភាគទិន្នន័យដែលទទួលបាន តាមរយៈការបំពេញកម្រងសំណួរ អ្នកស្រាវជ្រាវប្រើប្រាស់កម្មវិធី SPSS ដើម្បីបញ្ចូល និងវិភាគទិន្នន័យ និងប្រើកម្មវិធី Ms. Excel ដើម្បីបង្ហាញតារាង និងតារាងក្រាហ្វិកក្នុងការវិភាគបែបបរិមាណវិស័យដែលបង្ហាញពីកម្រិតចម្លើយនៃ សកម្មភាពនានាដែលពាក់ព័ន្ធនឹងប្រសិទ្ធភាពនៃការអនុវត្តការគ្រប់គ្រងតាមសាលារៀន ។ ចំណែកសំណួរបើកវិញជាសំណួរបែបគុណវិស័យ យើងខ្ញុំវិភាគដោយប្រើប្រាស់កម្មវិធី SPSS និង Ms. Word ។ ដូច្នេះនៅក្នុងការវិភាគចម្លើយ ចំពោះរាល់សំណួរទាំងអស់ ត្រូវបានធ្វើការវិភាគ គឺអាស្រ័យទៅលើប្រភេទនៃសំណួរ ថាតើវាជាប្រភេទសំណួរបើក ឬសំណួរបិទ ។

## ៣.៨ ក្រមសីលធម៌នៃការស្រាវជ្រាវ

ចំពោះការសិក្សាស្រាវជ្រាវនេះ ដើម្បីរក្សាបាននូវក្រមសីលធម៌ យើងបានរៀបចំលិខិត ដើម្បីសុំការអនុញ្ញាតពីថ្នាក់ដឹកនាំនៃមន្ទីរអប់រំ យុវជន និងកីឡា ដើម្បីបានផ្តល់ដំណឹងបន្តទៅ ដល់មូលដ្ឋានក្នុង ការសុំជួបសម្ភាសជាមួយ នាយក គ្រូ សិស្ស សហគមន៍ និងគណៈកម្មការគ្រប់គ្រងសាលារៀន ។ នៅគ្រប់ការជួបសម្ភាសជាមួយ នាយក គ្រូ សិស្ស សហគមន៍ និងគណៈកម្មការគ្រប់គ្រងសាលារៀន យើងតែងតែ

ជម្រាប ពួកគាត់អំពីក្រមសីលធម៌របស់អ្នកសិក្សាស្រាវជ្រាវដែលរក្សានូវការសម្ងាត់ នូវរាល់ចម្លើយ របស់នាយក គ្រូ ដែលមិនបានបង្ហាញពីឈ្មោះរបស់អ្នកចូលរួមឆ្លើយពិតប្រាកដនោះទេ ដើម្បីទាមទារឱ្យបានចម្លើយដែលពិតប្រាកដ ។

# ជំពូកទី៤

# លទ្ធផលនៃការសិក្សាស្រាវជ្រាវ

# និងការពិភាក្សា

# ជំពូកទី៤

# លទ្ធផលនៃការស្រាវជ្រាវ និងការពិភាក្សា

នៅក្នុងជំពូកនេះ អ្នកសិក្សាស្រាវជ្រាវ នឹងបង្ហាញនូវលទ្ធផលដែលប្រមូលបានទៅតាម ខ្លឹមសារនៃកម្រងសំណួរម្តងមួយៗ តាមរយៈតារាង និងក្រាហ្វិក ហើយនិងធ្វើការបកស្រាយ ធៀបនឹងខ្លឹមសារនៃពិន្ទុស្តង់ដាទាំង៩សាលាមានប្រសិទ្ធភាព ។

## ៤.១ លទ្ធនៃការសិក្សាស្រាវជ្រាវ

### ៤.១.១ អ្នកចូលរួមក្នុងការផ្តល់ព័ត៌មានក្នុងការស្រាវជ្រាវ

ក្រោយពេលបូកសរុបទិន្នន័យវិទ្យាល័យ ដែលប្រមូលបានពីការបំពេញកម្រងសំណួរ និងឆ្លើយសំណួរសម្ភាសរួចមក អ្នកសិក្សាស្រាវជ្រាវរកឃើញថា អ្នកចូលរួមឆ្លើយក្នុងការផ្តល់ព័ត៌មាន សរុបមានចំនួន ២៣៥នាក់ ស្រី ១២១នាក់ ដែលក្នុងនោះ នាយកសាលា ៧នាក់ ស្រី០នាក់ គ្រូបង្រៀន ៥៧ នាក់ ស្រី ៣១នាក់ សិស្ស ១៥០នាក់ ស្រី ៨២នាក់ សហគមន៍ និងគណៈកម្មការគ្រប់គ្រងសាលារៀន ២១នាក់ ស្រី ០៨នាក់ (តារាងទី១) ។

*តារាងទី១ ៖ ចំនួនអ្នកចូលរួមផ្តល់ព័ត៌មានសម្រាប់ការសិក្សាស្រាវជ្រាវ*

| អ្នកចូលរួមឆ្លើយសំណួរ | ប្រុស | ស្រី | សរុប |
|---|---|---|---|
| នាយកសាលា | ៧នាក់ | ០នាក់ | ៧នាក់ |
| គ្រូបង្រៀន | ២៦នាក់ | ៣១នាក់ | ៥៧នាក់ |
| សិស្ស | ១២១នាក់ | ៣៩នាក់ | ១៥០នាក់ |
| សហគមន៍ និងគណៈកម្មការគ្រប់គ្រងសាលារៀន | ១២នាក់ | ៨នាក់ | ២១នាក់ |
| សរុប | ១៦៦នាក់ | ៧៨នាក់ | ២៣៥នាក់ |

*តារាងទី២ ៖ កម្រិតវប្បធម៌ នាយក និងគ្រូបង្រៀន*

| កម្រិតវប្បធម៌ | នាយក | | គ្រូបង្រៀន | | សរុប |
|---|---|---|---|---|---|
| | ប្រុស | ស្រី | ប្រុស | ស្រី | |
| ទាបជាងបរិញ្ញាប័ត្រ | ០ | ០ | ៤ | ៧ | ១១ |
| បរិញ្ញាប័ត្រ | ២ | ០ | ២២ | ២៤ | ៤៨ |
| អនុបណ្ឌិត | ៥ | ០ | ០ | ០ | ០ |
| បណ្ឌិត | ០ | ០ | ០ | ០ | ០ |

តាមតារាងទី២ ៖ នាយកសាលាដែលបានចូលរួមឆ្លើយសំណួរមានចំនួនសរុប (៧នាក់)ក្នុងនេះនាយកសាលាដែលមានកម្រិតវប្បធម៌ថ្នាក់អនុបណ្ឌិតមានចំនួន(៥នាក់) និងនាយកសាលា២នាក់ទៀតមានកម្រិតវប្បធម៌ត្រឹមថ្នាក់បរិញ្ញាប័ត្រ ។ ចំណែកឯគ្រូបង្រៀនវិញចូលរួម សុរបមានចំនួន ៥៧នាក់ ស្រី៣១នាក់ ។ លោកគ្រូអ្នកគ្រូដែលមានកម្រិតវប្បធម៌ថ្នាក់បរិញ្ញាប័ត្រមានចំនួន ៤៨នាក់ ស្រី ២៤នាក់

និងលោកគ្រូអ្នកគ្រូដែលមានកម្រិតសិក្សាទាបជាងបរិញ្ញាប័ត្រគឺមានចំនួន ១១នាក់ ស្រី ៧នាក់ ។ យើងសង្កេតឃើញថាចំនួនគ្រូបង្រៀនដែលមាន
កម្រិតសញ្ញាប័ត្របរិញ្ញាប័ត្រមានចំនួនច្រើនជាងគ្រូដែលមានកម្រិតវប្បធម៌ទាបជាងបរិញ្ញាប័ត្រ ។

***តារាងទី៣ ៖ កម្រិតវិជ្ជាជីវៈ នាយក និងគ្រូបង្រៀន នាក់***

| កម្រិតវិជ្ជាជីវៈ | នាយក | | គ្រូបង្រៀន | | សរុប |
|---|---|---|---|---|---|
| | ប្រុស | ស្រី | ប្រុស | ស្រី | |
| បឋមសិក្សា | ០ | ០ | ០ | ២ | ២ |
| កម្រិតមូលដ្ឋាន | ០ | ០ | ២៦ | ២៨ | ៥៤ |
| កម្រិតឧត្តម | ៧ | ០ | ០ | ១ | ៨ |

តាមតារាងទី៣៖ នាយកវិទ្យាល័យទាំងអស់ សុទ្ធសឹងជាគ្រូបង្រៀនកម្រិតឧត្តម១០០% និងមិនមាននាយកណាម្នាក់ជាគ្រូកម្រិតមូលដ្ឋាន ឬបឋមសិក្សានោះទេ ។ ចំពោះគ្រូបង្រៀនផ្នែកបឋមភូមិវិញ យើងឃើញថាមានគ្រូចំនួនតែ១.៨%ដែលមានកម្រិតវិជ្ជាជីវៈជាគ្រូកម្រិតឧត្តមសិក្សា ចំណែកឯគ្រូបង្រៀន ៩៤.៧% មានកម្រិតវិជ្ជាជីវៈជាគ្រូកម្រិតមូលដ្ឋាន ក្នុងនោះផងដែរ ក៏នៅមានគ្រូ ៣.៥% ជាគ្រូកម្រិតបឋមសិក្សា ។ នេះបញ្ជាក់បានថាគ្រូបង្រៀននៅកម្រិតមធ្យម សិក្សាបឋមភូមិនៅមិនទាន់មានគុណវុឌ្ឍិគ្រប់គ្រាន់ដើម្បីឆ្លើយតបទៅនឹងគោលនយោបាយស្ដី ពីធនធានមនុស្សក្នុងវិស័យអប់រំ (ឆ្នាំ២០១២) ។

***ដ្យាក្រាមទី១ ៖ អតីតភាពការងារមុខតំណែងរបស់ នាយក និងគ្រូបង្រៀន (%)***




តាមដ្យាក្រាមទី១ បង្ហាញថាអ្នកដែលបានចូលរួមឆ្លើយសំណួរ មានគ្រូចំនួន៧.០០% ស្មើ៤នាក់ មានអតីតភាពការងារក្នុងមុខតំណែងរបស់ខ្លួនទាបជាង៣ឆ្នាំ ។ នាយកសាលាចំនួន ១៤.៣០%ស្មើ ១ នាក់ គ្រូបង្រៀនចំនួន១០.៥០% ស្មើ៦នាក់ មានអតីតាពការងារក្នុងមុខ តំណែងរបស់ខ្លួនចន្លោះពី៣ឆ្នាំទៅ៥ឆ្នាំ ។ នាយកសាលាចំនួន៨៥.៧០% ស្មើ៦នាក់ គ្រូបង្រៀនចំនួន ៨២.៥០% ស្មើ៤៧នាក់ មានអតីតភាពការងារក្នុងមុខតំណែងរបស់ខ្លួនលើសពី ១០ឆ្នាំ ។ នេះបង្ហាញថានាយក និងគ្រូបង្រៀនដែលបានចូលរួមឆ្លើយសំណួរភាគច្រើន មាន
អតីតភាពការងារលើសពី១០ឆ្នាំ ។

***ដ្យាក្រាមទី២ ៖ ចំនួនសិស្សតាមកម្រិតថ្នាក់ (នាក់)***



តាមដ្យាក្រាមទី២ សិស្សដែលបានចូលរួមបំពេញកម្រងសំណួរមានថ្នាក់ទី៧ ចំនួន៥២នាក់ ស្រី៣០ នាក់ ថ្នាក់ទី៨មាន ៥៣នាក់ ស្រី ៣៣នាក់ និងថ្នាក់ទី៩មាន ៤៥នាក់ ស្រី ១៩នាក់ ។ យើងសង្កេតឃើញ ថា សិស្សស្រីដែលបានចូលរួមឆ្លើយសំណួរមានចំនួនច្រើនជាងសិស្សប្រុស ។

## ៤.១.២ ប្រសិទ្ធភាពនៃការអនុវត្តការគ្រប់គ្រងតាមសាលារៀន ( SMB )

### ៤.១.២.១ វត្ថុបំណងគោលនយោបាយសាលារៀន

*ដ្យាក្រាមទី៣ ៖ ការចូលរៀនតាមថ្នាក់ ត្រួតថ្នាក់ បោះបង់ ឡើងថ្នាក់*




តាមរយៈដ្យាក្រាមទី៣ ៖ យើងសង្កេតឃើញថាពិន្ទុលើចំណុចអត្រាចូលរៀន និងអត្រាឡើងថ្នាក់ របស់សិស្សា នាយកសាលាគោលដៅទាំងប្រាំពីរបានវាយតម្លៃពិន្ទុ៣ គឺមានន័យថានាយកវាយតម្លៃខ្ពស់ លើចំណុចទាំងពីរនេះ ខណៈពេលដែលអត្រាត្រួតថ្នាក់និងអត្រាបោះបង់មាន តម្លៃមធ្យមស្មើ១ គឺមានន័យ ថាការយល់ឃើញរបស់នាយកលើចំណុចទាំងនេះមានកម្រិតទាប ។ ហើយពិន្ទុសរុបចំណុចរួមគឺស្មើនឹង ២ គឺឆ្លុះបញ្ចាំងឱ្យឃើញយ៉ាងច្បាស់ថាអត្រាសិស្សចូលរៀន

អត្រាសិស្សត្រួតថ្នាក់ អត្រាបោះបង់ អត្រាឡើងថ្នាក់ របស់សាលាគោលដៅទាំងប្រាំពីរក្នុងរាជធានីភ្នំពេញ បំពេញបាននូវស្តង់ដាអប្បបរមាធៀបនឹងពិន្ទុស្តង់ដាសាលាមានប្រសិទ្ធភាព ។ បើទោះបីយ៉ាងណាក៏ ដោយឃើញថាការអនុវត្តរបស់សាលាគោលដៅទាំងប្រាំពីរនៅត្រង់ចំណុចនេះគឺនៅមានបញ្ហាប្រឈម មួយចំនួននៅឡើយចំពោះសាលាគោលដៅមួយចំនួនក្នុងរាជធានីភ្នំពេញទៅលើបញ្ហាសិស្សត្រួតថ្នាក់ និង ការបោះបង់ការសិក្សារបស់សិស្សមានកម្រិតនៅឡើយ ។ តាម រយៈការសម្ភាសពីនាយក គ្រូ

សិស្សានុសិស្ស និងសហគមន៍នៅសាលាគោលដៅទាំងប្រាំពីរបានបញ្ជាក់ថាសាលារបស់ពួកគាត់នៅមានសិស្សត្រួតថ្នាក់ដោយសារកត្តាមួយចំនួនដូចជាការមិនយកចិត្តទុកដាក់របស់សិស្សក្នុងការសិក្សា សិស្សមិនមានមូលដ្ឋានគ្រឹះលើមុខវិជ្ជាមួយចំនួនពីថ្នាក់ក្រោម ជាពិសេសលើមុខវិជ្ជាគណិតវិទ្យា និងអំណាន ។ រីឯបញ្ហាសិស្សបោះបង់ការសិក្សានៅតាមសាលារៀនគឺបណ្តាលមកពីមូលហេតុដូចជាបញ្ហាជីវភាពគ្រួសារក្រីក្រ ការបំលាស់ទីតាំងរស់នៅទៅតាមឪពុកម្តាយ ចូលធ្វើការរោងចក្រ រឺធ្វើការផ្សេងៗដើម្បីរកចំណូលជួយដោះស្រាយជីវភាពក្នុងគ្រួសារ នេះបើតាមការបញ្ជាក់ពីនាយក គ្រូ សិស្សានុសិស្ស និងសហគម៍នៃសាលាគោលដៅទាំងប្រាំពីរក្នុងរាជធានីភ្នំពេញ ។

***ដ្យាក្រាមទី៤ ៖ លទ្ធផលតេស្តមុខវិជ្ជាគោល (គណិត ខ្មែរ ភាសាបរទេស)***




តាមដ្យាក្រាមទី៤ ៖ បង្ហាញពីលទ្ធផលតេស្តមុខវិជ្ជា (ភាសាខ្មែរ គណិតវិទ្យា ភាសាបរទេស) សម្រាប់សិស្សមធ្យមសិក្សាបឋមភូមិនៃសាលាគោលដៅទាំង៧ក្នុងរាជធានីភ្នំពេញ ។ សម្រាប់លទ្ធផលតេស្តលើមុខវិជ្ជាភាសាខ្មែរ គណិតវិទ្យា និងភាសាបរទេសគឺការវាយតម្លៃរបស់សិស្សគឺមានកម្រិតពិន្ទុស្មើ ២ នេះបង្ហាញឱ្យឃើញថាសមត្ថភាពសិស្សលើមុខវិជ្ជាភាសាខ្មែរ
គណិតវិទ្យា និងភាសាបរទេសគឺការសិក្សារបស់សិស្សស្ថិតក្នុងកម្រិតមធ្យម ។ តម្លៃពិន្ទុសរុបរួមលើការធ្វើតេស្តមុខវិជ្ជាទាំង៣ គឺស្មើនឹង ២ បង្ហាញឱ្យឃើញថាការសិក្សារបស់សិស្សលើមុខវិជ្ជាទាំងបីគឺនៅមានកម្រិតមធ្យមនៅឡើយ ។ បញ្ហាប្រឈម ដែលបណ្តាលអោយការសិក្សាលើមុខវិជ្ជាទាំងបីស្ថិតនៅក្នុងកម្រិតមធ្យមបែបនេះបើតាមការផ្តល់ព័តមាន ពីការគូស និងការសម្ភាសន៍ផ្ទាល់មាត់គឺបណ្តាលមកពីកត្តាដូចជា ៖ សិស្សមួយចំនួននៅមានសមត្ថភាព ទាបនៅអំណាន ការគណនាលើមុខវិជ្ជាគណិតវិទ្យានៅមានកម្រិតទាប និងការសិក្សាភាសាបរទេសសិស្សមួយចំនួនទើបតែរៀនភាសាបរទេសថ្នាក់ដំបូង ។ គ្រូបង្រៀននៅមិនទាន់មាន ការប្រើប្រាស់សម្ភារៈ ឧបទ្ទេសសមស្របដើម្បីជួយជំរុញការបង្រៀនអោយសិស្សកាន់តែឆាប់ យល់នៅក្នុងម៉ោងបង្រៀន ។

***ដ្យាក្រាមទី៥ ៖ លទ្ធផលតេស្តមុខវិជ្ជាគោល (មុខវិជ្ជាវិទ្យាសាស្រ្ត និងវិទ្យាសាស្រ្តសង្គម ប្រវត្តិវិទ្យា)***



តាមដ្យាក្រាមទី៥ ៖ បង្ហាញពីលទ្ធផលតេស្តមុខវិជ្ជាគោល (មុខវិជ្ជាវិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រសង្គម ប្រវត្តិវិទ្យា) សម្រាប់សិស្សមធ្យមសិក្សាបឋមភូមិនៃសាលាគោលដៅទាំង៧ក្នុងរាជធានីភ្នំពេញ ។ សម្រាប់ការវាយតម្លៃលទ្ធផលតេស្តលើមុខវិជ្ជារូបវិទ្យា គីមីវិទ្យា ជីវវិទ្យា ប្រវត្តិវិទ្យា និងផែនដីវិទ្យា សិស្សទទួលបានពិន្ទុពីការវាយតម្លៃស្មើនឹង២ គឺមានន័យថាសិស្សមានសមត្ថភាពក្នុងកម្រិតមធ្យមសម្រាប់មុខវិជ្ជាទាំងបួន ។ រីឯការវាយតម្លៃពិន្ទុតេស្តលើមុខវិជ្ជា ICT វិញឃើញថាពិន្ទុនៃការវាយតម្លៃស្មើនឹង១ ដូច្នេះគឺមានន័យថាកម្រិតនៃការសិក្សារបស់សិស្សមានកម្រិត ទាប ។ តម្លៃពិន្ទុសរុបរួមលើការធ្វើតេស្តមុខវិជ្ជាទាំង៦ គឺស្មើនឹង១ បង្ហាញឱ្យឃើញថាការសិក្សាសិស្សលើមុខវិជ្ជាទាំងប្រាំមួយគឺមានស្ថិតក្នុងកម្រិត ទាបនៅឡើយដោយសារតែសាលារៀនមួយចំនួននៅមិនទាន់បានអនុវត្តមុខវិជ្ជា ICT នៅឡើយមូលហេតុមកពីសាលាមានកង្វះខាត កុំព្យូទ័រសម្រាប់អោយសិស្សប្រើប្រាស់ក្នុងការអនុវត្ត កុំព្យូទ័រមានភាពខូចខាតភាគច្រើន និង សាលាមួយចំនួនទៀតពុំមានគ្រូឯកទេសផ្នែកព័តមានវិទ្យា នេះបើតាមការផ្តល់បទសម្ភាសន៍ ពីនាយកសាលារៀន គ្រូបង្រៀន សិស្ស និងសហគមន៍ ព្រមទាំងការសង្កេតដោយផ្ទាល់ផងដែរ ។

***ដ្យាក្រាមទី៦ ៖ លទ្ធផលតេស្តល្បឿនអំណានសិស្ស និងសិស្សជាប់សញ្ញាបត្រថ្នាក់ទី៩***




តាមដ្យាក្រាមទី៦ ៖ បង្ហាញពីលទ្ធផលតេស្តល្បឿនអំណានសិស្ស និងសិស្សជាប់សញ្ញាបត្រថ្នាក់ទី៩ សម្រាប់មធ្យមសិក្សាបឋមភូមិនៃសាលាគោលដៅក្នុងរាជធានីភ្នំពេញ ។ សម្រាប់លទ្ធផលតេស្តល្បឿនអំណានរបស់សិស្សថ្នាក់ទី៩ លើមុខវិជ្ជាភាសាខ្មែរយើងឃើញថាសិស្សទទួលបានពិន្ទុ២ ដែលមានន័យថាសិស្សថ្នាក់ទី៩មានសមត្ថភាពកម្រិតមធ្យមលើសមត្ថភាពអំណាន ក្នុងរយៈពេលមួយនាទីអាចអានភាសាខ្មែរលើសពី២០០ពាក្យ ។រីឯសិស្ស ថ្នាក់ទី៩ដែលបានជាប់សញ្ញាបត្រវិញគឺមធ្យមភាគគឺស្មើ ២ មានន័យថាសិស្សថ្នាក់ទី៩នៃសាលាគោលដៅទាំង៧ក្នុងរាជធានីភ្នំពេញបានជាប់សញ្ញាបត្រមធ្យមសិក្សាបឋមភូមិក្នុងកម្រិតមធ្យម ។ ដូចនេះតាមរយៈ ដ្យាក្រាមដែលបង្ហាញខាងលើអាចបញ្ជាក់បានថា

សាលារៀនបានអនុវត្តបានយ៉ាងល្អលើលទ្ធផលអំណានរបស់សិស្ស និងសិស្សថ្នាក់ទី៩បានប្រលងជាប់សញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិបានល្អស្របតាមស្តង់ដាសាលាមានប្រសិទ្ធភាព ។

***តារាងទី៤ ៖ វត្ថុបំណងគោលនយោបាយសាលារៀន***

<table>
<tr><th>ល.រ</th><th colspan="2">ខ្លឹមសារ</th><th>១</th><th>២</th><th>៣</th></tr>
<tr><td rowspan="4">១</td><td rowspan="4">ចូលរៀន ត្រួតថ្នាក់ បោះបង់និងឡើងថ្នាក់ (ចំនួនសិស្ស)</td><td>ចូលរៀន</td><td></td><td></td><td>3</td></tr>
<tr><td>ត្រួតថ្នាក់</td><td>1</td><td></td><td></td></tr>
<tr><td>បោះបង់</td><td>1</td><td></td><td></td></tr>
<tr><td>ឡើងថ្នាក់</td><td></td><td></td><td>3</td></tr>
<tr><td rowspan="3">២</td><td rowspan="3">ភាគរយសិស្សសម្រេចផលសិក្សាចុងឆ្នាំសិក្សាជាពិន្ទុច្រើនជាង៦០%នៃពិន្ទុ សរុបលើមុខវិជ្ជាគោលនីមួយៗ</td><td>ភាសាខ្មែរ</td><td></td><td>2</td><td></td></tr>
<tr><td>គណិតវិទ្យា</td><td></td><td>2</td><td></td></tr>
<tr><td>ភាសាបរទេស</td><td></td><td>2</td><td></td></tr>
<tr><td rowspan="6">៣</td><td rowspan="6">ភាគរយសិស្សសម្រេចផលសិក្សាក្នុងឆ្នាំសិក្សាជាពិន្ទុច្រើនជាង៦០%នៃពិន្ទុសរុបលើមុខវិជ្ជាគោលនីមួយៗ(លើមុខវិជ្ជាវិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រសង្គម ប្រវត្តិវិទ្យា)</td><td>រូបវិទ្យា</td><td></td><td>2</td><td></td></tr>
<tr><td>គីមីវិទ្យា</td><td></td><td>2</td><td></td></tr>
<tr><td>ជីវវិទ្យា</td><td></td><td>2</td><td></td></tr>
<tr><td>ផែនដីវិទ្យា</td><td></td><td>2</td><td></td></tr>
<tr><td>ប្រវត្តិវិទ្យា</td><td></td><td>2</td><td></td></tr>
<tr><td>ICT</td><td>1</td><td></td><td></td></tr>
<tr><td>៤</td><td colspan="2">ភាគរយសិស្សថ្នាក់ទី៩សម្រេចបានល្បឿន អានភាសាខ្មែរក្នុង ១នាទីយល់ភាសា</td><td></td><td>2</td><td></td></tr>
<tr><td>៥</td><td colspan="2">ភាគរយសិស្សថ្នាក់ទី៩ប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាបឋមភូមិ</td><td></td><td>2</td><td></td></tr>
<tr><td colspan="3">សរុប</td><td colspan="3">29</td></tr>
<tr><td colspan="6">ពិន្ទុស្តង់ដាអប្បរមាគឺ ៦៥% មានន័យថាស្តង់ដានេះត្រូវមានពិន្ទុយ៉ាងតិច២៧ ដើម្បីបំពេញបាននូវស្តង់ដាអប្បរមា ។</td></tr>
</table>

តាមតារាងទី៤ ៖ បានបង្ហាញអោយឃើញថាប្រសិទ្ធភាពនៃការអនុវត្តលើវត្ថុបំណងគោលនយោបាយសាលារៀននៅតាមសាលារៀនគោលដៅទាំង៧ក្នុងរាជធានីភ្នំពេញគឺមានកម្រិតមធ្យម នៅឡើយ ។ មូលហេតុដែលអាចអោយយើងសន្និដ្ឋានបែបនេះបានដោយសារតែពិន្ទុសរុបនៃ ស្តង់ដាទី១ក្នុងការអនុវត្តការគ្រប់គ្រងតាមសាលារៀននៃសាលាគោលដៅទាំងប្រាំពីរក្នុងរាជធានីភ្នំពេញស្មើនឹង២៩ពិន្ទុ បើធៀបនឹងស្តង់ដាពិន្ទុអប្បបរមាសាលាមានប្រសិទ្ធភាពយើងឃើញថាសាលារៀនទាំងប្រាំពីរនៅក្នុងរាជធានីភ្នំពេញ បានបំពេញបាននូវស្តង់ដាសម្រាប់ការអនុវត្តលើវត្ថុបំណងគោលនយោបាយសាលារៀនត្រឹមកម្រិតមធ្យម ។ នៅក្នុងនេះផងដែរយើងឃើញថាសាលាគោលដៅមួយចំនួនមានបញ្ហាប្រឈមដែលកើតមានឡើងចំពោះការអនុវត្តវត្ថុបំណងគោលនយោបាយសាលារៀនដូចជា៖ សាលា

រៀនមួយចំនួនក្នុងសាលាគោលដៅទាំងប្រាំពីរគឺនៅមានបញ្ហាសិស្សត្រួតថ្នាក់ និងសិស្សបោះបង់នៅឡើយ ។ មួយវិញទៀតតាមរយៈការបំពេញកម្រងសំណួររបស់លោកនាយកសាលារៀនគោលដៅទាំងប្រាំពីរ យើងឃើញថាលទ្ធផលតេស្តសិស្សនៅមធ្យមសិក្សាបឋមភូមិលើមុខវិជ្ជាគោលវិទ្យាសាស្ត្រពិត និងវិទ្យាសាស្ត្រសង្គមយើងឃើញថានៅមានកម្រិតមធ្យមនៅឡើយ មូលហេតុគឺមកពីសិស្សមួយចំនួននៅមានកម្រិតទាបចំពោះអំណាន និងគណិតវិទ្យា ។ ម៉្យាងវិញទៀតចំពោះការបង្រៀនរបស់លោកគ្រូអ្នកគ្រូមិនបានប្រើប្រាស់សម្ភារៈឧបទ្ទេសជាជំនួយ ដល់ការបង្រៀនអោយសិស្សកាន់ តែចាប់អារម្មណ៍ និងងាយយល់ ។ រីឯបញ្ហាដែលប្រឈម មួយវិញទៀតនោះគឺការអនុវត្តម៉ោងសិក្សាមុខវិជ្ជា ICT នៅកម្រិតមធ្យមសិក្សាបឋមភូមិសម្រាប់សាលាគោលដៅមួយចំនួនគឺមិនទាន់មានដំណើរការនៅឡើយទេ ដោយសារតែសាលាមានការខ្វះខាតកុំព្យូទ័រសម្រាប់អោយសិស្សប្រើប្រាស់ និងសាលាមួយចំនួនទៀតមានកុំព្យូទ័រប៉ុន្តែភាគច្រើនខូច និងពុំមានការជួសជុលព្រមទាំងខ្វះគ្រូឯកទេសកុំព្យូទ័រផងដែរ ។

### ៤.១.២.២ ការបង្រៀន និងការរៀន

*ដ្យាក្រាមទី៧ ៖ បំណែងចែកកម្មវិធីសិក្សាតាមមុខវិជ្ជា និងតាមកម្រិតថ្នាក់*




តាមរយៈដ្យាក្រាមទី៧ខាងលើ យើងសង្កេតឃើញថាពិន្ទុនៃការវាយតម្លៃលើចំណុចបំណែងចែកកម្មវិធីសិក្សាស្មើ២ គឺមានន័យថាគ្រូបង្រៀននៅតាមមធ្យមសិក្សាបឋមភូមិក្នុងសាលាគោលដៅទាំងប្រាំពីរបានធ្វើបំណែងចែកកម្មវិធីសិក្សាកម្រិតមធ្យម ។ ចំពោះកិច្ចតែងការបង្រៀនវិញឃើញថាពិន្ទុនៃការវាយតម្លៃស្មើ ២ បានឆ្លុះបញ្ចាំអោយឃើញថាការប្រើប្រាស់ កិច្ចតែងការបង្រៀនរបស់គ្រូបង្រៀននៅមធ្យមសិក្សាបឋមភូមិនៅតាមសាលាគោលដៅទាំងប្រាំពីរក្នុងរាជធានីភ្នំពេញគឺនៅមានកម្រិតនៅឡើយ ដោយលោកគ្រូអ្នកគ្រូមួយចំនួនតូចនៅមិនទាន់បានធ្វើនិងប្រើប្រាស់កិច្ចតែងការបង្រៀនក្នុងម៉ោងបង្រៀននៅឡើយ ។

*ដ្យាក្រាមទី៨ ៖ តេស្តអំណា នថ្នាក់ទី៩ ពិន្ទុតេស្តមុខវិជ្ជាគោលថ្នាក់ទី៧ ៨ និង៩ដែលជាប់*



ដ្យាក្រាមទី៨ នេះបង្ហាញតេស្តល្បឿនអំណានថ្នាក់ទី៩ និងពិន្ទុតេស្តសិស្សថ្នាក់ទី៧ ទី៨ និងថ្នាក់ទី៩ ដែលជាប់លើមុខវិជ្ជាគោល ។ ចំណុចដែលគួរកត់សម្គាល់ពិន្ទុលើការវាយតម្លៃគឺត្រឹមតែ១ តែប៉ុណ្ណោះសម្រាប់តេស្តល្បឿនអំណានរបស់សិស្សថ្នាក់ទី៩ នេះបង្ហាញឱ្យឃើញថាសិស្សថ្នាក់ទី៩ មិនទាន់មានសមត្ថភាពគ្រប់គ្រាន់ក្នុងអំណាននោះទេ ។ តាមរយៈការសម្ភាសន៍ពីលោកគ្រូអ្នកគ្រូ នាយក បានបង្ហាញឱ្យឃើញថាសិស្សានុសិស្សថ្នាក់ទី៩ខ្សោយផ្នែកអំណានបែបនេះ បណ្តាលមកពីមូលហេតុមួយចំនួនដូចជា សិស្សមិនសូវបានចូលរួមញឹកញ៉ាប់ក្នុងការអានសៀវភៅ ដោយហេតុថាខ្វះការលើកទឹកចិត្តជំរុញសិស្សចូលអានសៀវភៅក្នុងបណ្ណាល័យ និងការតាមដានរបស់មាតាបិតាក្នុងការជំរុញកូនឱ្យអានសៀវភៅ រឺឯកសារផ្សេងៗនៅផ្ទះ ។ ចំណែកឯពិន្ទុតេស្តសិស្សថ្នាក់ទី៧ ទី៨ និងថ្នាក់ទី៩ ដែលជាប់លើមុខវិជ្ជាគោលគឺការវាយតម្លៃពិន្ទុស្មើ២ដែលមានន័យថាពិន្ទុតេស្តលើមុខវិជ្ជាគោលដែលសិស្សទាំងបីកម្រិតទទួលបានគឺនៅមានកម្រិតមធ្យមនៅឡើយ ។ ដោយមូលហេតុមួយចំនួនដែលនាំអោយពិន្ទុតេស្តលើមុខវិជ្ជាគោលថ្នាក់ទីទាំងបីកម្រិតនៅមានកម្រិតមធ្យមដោយសារតែសិស្សមួយចំនួនធំគឺនៅមានភាពខ្សោយលើមុខវិជ្ជាគោលផ្នែកវិទ្យាសាស្ត្រដូចជា រូបវិទ្យា គីមីវិទ្យា គណិតវិទ្យា និងជីវវិទ្យា ។ ម៉្យាងវិញទៀតការបង្រៀនលើមុខវិជ្ជាវិទ្យាសាស្ត្រពីសំណាក់លោកគ្រូអ្នកគ្រូ ខ្វះការពិសោធន៍សម្រាប់សិស្សដើម្បីទាក់ទាញសិស្សក្នុងការចូលរួមរៀន ។

*ដ្យាក្រាមទី៩ ៖ សិស្សថ្នាក់ទី៩ប្រឡងជាប់ឆមាស និងប្រជុំរវាងគ្រូបង្រៀន និង មាតាបិតាសិស្សរៀនយឺត*




នៅក្នុងក្រាបទី៨ នេះគឺពិពណ៌ពីសិស្សថ្នាក់ទី៩ដែលបានប្រឡងជាប់ឆមាស និង ការប្រជុំ រវាងគ្រូបង្រៀន និងមាតាបិតាសិស្សរៀនយឺត ។ តាមរយៈការចូលរួមឆ្លើយរបស់គ្រូបង្រៀននៅមធ្យមសិក្សាបឋមភូមិនៃសាលាគោលដៅទាំងប្រាំពីរគឺបានបង្ហាញថាសិស្សថ្នាក់ទី៩ដែលបាន ប្រឡងជាប់ឆមាសមានពិន្ទុស្មើ២ គឺមានន័យថាការសិក្សារបស់សិស្សថ្នាក់ទី៩មានការយកចិត្តទុក ដាក់ក្នុងការសិក្សា ក៏ដូចជា

លោកគ្រូអ្នកគ្រូយកចិត្តទុកដាក់ក្នុងការបង្ហាត់បង្រៀនសិស្សឱ្យទទួលបាននូវចំណេះដឹងលើគ្រប់មុខវិជ្ជា ដែលក្នុងនេះគឺលទ្ធផលបានបង្ហាញថាលទ្ធផលប្រឡងឆមាសសិស្សថ្នាក់ទី៩គឺជាប់ក្នុងកម្រិតមធ្យម ។ មួយវិញទៀតការប្រជុំរវាងគ្រូបង្រៀន និងមាតាបិតាសិស្សរៀនយឺតគឺមានពិន្ទុ១ មានន័យថាការជំនួបប្រជុំរវាងគ្រូបង្រៀន និងមាតាបិតាសិស្សរៀនយឺតគឺនៅមានកម្រិតទាបនៅឡើយ ។ តាមរយៈការចូលរួមឆ្លើយបានបង្ហាញឱ្យឃើញច្បាស់ថាការប្រជុំរវាងគ្រូបង្រៀន និងមាតាបិតាសិស្សរៀនយឺតគឺមិនសូវមានសកម្មភាពទៀតទាត់នោះទេយ៉ាងណាមិញបើតាមការសម្ភាសបានបង្ហាញដូចគ្នានេះដែរថា សាលាមួយចំនួននៅក្នុងចំណោមសាលាគោលដៅទាំងប្រាំពីរនៅរាជធានីភ្នំពេញគឺមិនបានធ្វើការទំនាក់ទំនងជាមួយមាតាបិតាសិស្សដែលរៀនយឺត និងពុំបានផ្តល់ព័ត៌មានដល់គណៈកម្មការគ្រប់គ្រងសាលារៀនដើម្បីកំណត់មុខសញ្ញាសិស្សរៀនយឺតនោះទេ ។

***ដ្យាក្រាមទី៩ ៖ កង្វះចំនួនម៉ោងបង្រៀនជាមធ្យម ថ្នាក់ទី៧ ៨ ៩***




តាមដ្យាក្រាមទី៩ បានបង្ហាញពីកង្វះចំនួនម៉ោងបង្រៀនជាមធ្យមសម្រាប់ថ្នាក់ទី៧ ទី៨ និងថ្នាក់ទី៩ ។ តាមរយៈចម្លើយរបស់គ្រូបង្រៀននៅមធ្យមសិក្សាបឋមភូមិក្នុងសាលាគោលដៅទាំងប្រាំពីរបានបង្ហាញឱ្យឃើញថា កង្វះម៉ោងបង្រៀនគ្រូបង្រៀនសម្រាប់សិស្សក្នុងម៉ោងសិក្សាគឺនៅមានបញ្ហាតិចតួចនៅឡើយដោយនៅក្នុងនេះមានកង្វះខាតម៉ោងបង្រៀន សម្រាប់សិស្សថ្នាក់ទី៧ ទី៨ និងថ្នាក់ទី៩ មានពិន្ទុស្មើ ១ មានន័យថាកង្វះម៉ោងបង្រៀននៅក្នុងកម្រិត ថ្នាក់ទាំងពីរគឺស្ថិតនៅកម្រិតទាប ដោយសារតែលោកគ្រូអ្នកគ្រូបានអនុវត្តការបង្រៀនទៅតាមកាលវិភាគ និងគោរពម៉ោងចេញចូលបានច្បាស់លាស់សម្រាប់ការអនុវត្តម៉ោងបង្រៀន ។

***ដ្យាក្រាមទី១០ ៖ ចំនួនសិស្សអវត្តមាននៅមធ្យមសិក្សាបឋមភូមិ***



ដ្យាក្រាមទី១០ បង្ហាញពីចំនួនសិស្សអវត្តមាននៅមធ្យមសិក្សាបឋមភូមិនៃសាលា គោលដៅទាំងប្រាំពីរ ។ យោងតាមចម្លើយរបស់លោកគ្រូអ្នកគ្រូដែលបានផ្តល់បានបង្ហាញឱ្យឃើញថាសិស្សដែលមានអវត្តមានចំនួនតិចជាង៥ដង អវត្តមានចាប់ពី៥ទៅ១០ដង និងអវត្ត មានលើសពី១០ដង គឺមានការវាយតម្លៃពិន្ទុស្មើនឹង២ នេះបញ្ជាក់ថាចំនួនអវត្តមានរបស់សិស្សគឺនៅមានកម្រិតមធ្យមនៅឡើយ ។ បើតាមដ្យាក្រាមដែលបង្ហាញខាងលើនេះអាចបញ្ជាក់បានថាសាលារៀននៅមានបញ្ហាសិស្សគេចថ្នាក់រៀនក្នុងម៉ោងសិក្សានៅឡើយក្នុងនេះគឺមានន័យថាសាលារៀននៅមិនទាន់បានធ្វើការកំណត់បញ្ហាព្រមទាំងមុខសញ្ញាដែលបណ្តាលអោយសិស្សឈប់ច្រើនក្នុងម៉ោងសិក្សា និងស្វែងរកដំណោះស្រាយ ក៏ដូចជាទប់ស្កាត់ការឈប់របស់សិស្សក្នុងម៉ោងសិក្សាព្រមទាំងជំរុញអោយសហគមន៍មាតាបិតាសិស្សចូលរួមក្នុងការជំរុញកូនអោយមកសិក្សាវិញអោយស្របតាមស្តង់ដាសាលាមានប្រសិទ្ធភាពនៅឡើយ ។

***ដ្យាក្រាមទី១១ ៖ ចំនួនសិស្សបានទទួលបានលំហាត់ឬកិច្ចការផ្ទះលើមុខវិជ្ជាគោល***




ដ្យាក្រាមទី១១ បង្ហាញពីចំនួនសិស្សដែលទទួលបានលំហាត់ ឬកិច្ចការផ្ទះលើមុខវិជ្ជាគោល ។ យោងតាមចម្លើយរបស់លោកគ្រូអ្នកគ្រូដែលបានផ្តល់បានបង្ហាញឱ្យឃើញថាសិស្សថ្នាក់ទី៧ ថ្នាក់ទី៨ និង ថ្នាក់ទី៩ ទទួលបានលំហាត់ឬកិច្ចការផ្ទះនៅមានកម្រិតមធ្យមនៅឡើយដោយពិន្ទុដែលបានមកពីវាយតម្លៃស្មើ២ពិន្ទុ ដូច្នេះអាចឆ្លុះបញ្ចាំងយ៉ាងច្បាស់ថាការទទួលបានលំហាត់ឬកិច្ចការផ្ទះរបស់សិស្សពីលោកគ្រូអ្នកគ្រូគឺនៅមានកម្រិតមធ្យមនៅឡើយបើប្រៀបធៀបស្តង់សាលាប្រសិទ្ធភាព ។

***ដ្យាក្រាមទី១២ ៖ ចំនួនសិស្សបានទទួលបានកិច្ចការផ្ទះជាគម្រោងលើមុខវិជ្ជាគោល***



ដ្យាក្រាមទី១២ បង្ហាញពីចំនួនសិស្សបានទទួលកិច្ចការផ្ទះជាគម្រោងលើមុខវិជ្ជាគោល ។ ទទួលកិច្ចការផ្ទះជាគម្រោងលើមុខវិជ្ជាគោលសម្រាប់ថ្នាក់ទី៧ ថ្នាក់ទី៨ និងថ្នាក់ទី៩ គឺមានពិន្ទុស្មើនិង២ គឺមានន័យថាការទទួលបានកិច្ចការផ្ទះជាគម្រោងរបស់សិស្សទាំងបីកម្រិតថ្នាក់បិតក្នុងកម្រិតមធ្យម ។

***ដ្យាក្រាមទី១៣ ៖ គ្រូទទួលបានការបំប៉ន គ្រូបំពេញរដ្ឋបាលថ្នាក់ គ្រូបើកថ្នាក់យឺត និងមុខវិជ្ជាអប់រំកាយ កីឡា***




ដ្យាក្រាមទី១៣ បង្ហាញពីគ្រូទទួលបានការបំប៉ន គ្រូបំពេញរដ្ឋបាលថ្នាក់ គ្រូបើកថ្នាក់យឺត និងមុខវិជ្ជាអប់រំកាយ កីឡា ។ យោងតាមចម្លើយរបស់លោកគ្រូអ្នកគ្រូដែលបានផ្តល់បានបង្ហាញឱ្យឃើញថា លោកគ្រូអ្នកគ្រូមធ្យមសិក្សាបឋមភូមិនៅក្នុងសាលាគោលដៅទាំងប្រាំពីរនៅក្នុងរាជធានីភ្នំពេញទទួលបានការបំប៉នក្នុងកម្រិតទាបដោយមើលលើការវាយតម្លៃពិន្ទុគឺស្មើនឹង១ ។ រីឯលោកគ្រូអ្នកគ្រូដែលបានបំពេញរដ្ឋបាលគ្រូបានគ្រប់គ្រាន់គឺទទួលបានការវង្វាយតម្លៃពិន្ទុ ស្មើ២ មានន័យថាការបំពេញរដ្ឋបាលគ្រូបង្រៀនរបស់លោកគ្រូអ្នកគ្រូមធ្យមសិក្សាបឋមភូមិ សាលាគោលដៅទាំងប្រាំពីរក៏បានបំពេញក្នុងកម្រិតមធ្យមផងដែរ ។ ចំពោះលោកគ្រូអ្នកគ្រូ ដែលបើកថ្នាក់រៀនយឺតយ៉ាវវិញយើងឃើញថានៅមានចំនួនមធ្យមផងដែរសម្រាប់ការបើកថ្នាក់រៀនមូលហេតុដែលអាចសន្និដ្ឋានបែបនេះដោយយោងតាមការវាយតម្លៃលើពិន្ទុដែលបានបង្ហាញគឺស្មើនិង២ ។ ចំណែកការបង្ហាត់មុខវិជ្ជាអប់រំកាយនិងកីឡាសម្រាប់សាលាគោលដៅទាំងប្រាំពីរវិញគឺមានដំណើរការទាបនៅឡើយដោយពិន្ទុពីការវាយតម្លៃស្មើនឹង១ អាចបញ្ជាក់បានថាការអនុវត្តកម្មវិធីអប់រំកាយ និងកីឡានៅផ្នែកមធ្យមសិក្សាបឋមភូមិសម្រាប់សាលាគោលដៅទាំងប្រាំពីរគឺនៅមានកម្រិតទាបនៅឡើយ ។

***តារាងទី៥ ៖ ការបង្រៀន និងរៀន***

| ល.រ | ខ្លឹមសារ | ១ | ២ | ៣ |
|---|---|---|---|---|
| ១ | មានបំណែងចែកកម្មវិធីសិក្សាតាមមុខវិជ្ជា (ឆ្នាំ) | | 2 | |
| ២ | ចំនួនកិច្ចតែងការបង្រៀនបានរៀបចំតាមមុខវិជ្ជាគោល | | 2 | |

| | | | | |
|---|---|---|---|---|
| | (ភាសាខ្មែរ គណិតវិទ្យា វិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រសង្គម/ប្រវត្តិវិទ្យា)ថ្នាក់ទី៧ទៅតាមក្រុមគោលដៅ(ឆ្នាំ) | | | |
| ៣ | ចំនួនសិស្សថ្នាក់ទី៩មានពិន្ទុតេស្តជាប់ស្តង់ដាល្បឿនអំណាននិងយល់ខ្លឹមសារ(២០០ពាក្យក្នុង មួយនាទី)(ត្រូតពិនិត្យតាមដាននៅចុងឆមាសទី១និងទី២) | 1 | | |
| ៤ | ចំនួនសិស្សថ្នាក់ទី៧មានពិន្ទុតេស្តជាប់លើមុខវិជ្ជាគោលធៀបជាមួយក្រុមគោលដៅគ្រោងទុក (ត្រូវពិនិត្យតាមដានចុងឆមាសទី១ និងទី២) | | 2 | |
| ៥ | ចំនួនសិស្សថ្នាក់ទី៨មានពិន្ទុតេស្តជាប់លើមុខវិជ្ជាគោលធៀបជាមួយក្រុមគោលដៅគ្រោងទុក(ត្រូវពិនិត្យតាមដាននៅចុងឆមាសទី១និងទី២) | | 2 | |
| ៦ | ចំនួនសិស្សថ្នាក់ទី៩មានពិន្ទុតេស្តជាប់លើមុខវិជ្ជាគោលធៀបជាមួយក្រុមគោលដៅគ្រោងទុក (ត្រូវពិនិត្យតាមដាននៅចុងឆមាសទី១ និងទី២) | | 2 | |
| ៧ | ភាគរយសិស្សថ្នាក់ទី៩ប្រឡងជាប់ការប្រឡងឆមាស (ត្រូវត្រួតពិនិត្យតាមដាននៅចុងឆមាសទី១ និងទី២) | | 2 | |
| ៨ | ភាគរយសិស្សប្រឡងឡើងថ្នាក់សម្រាប់សិស្សធ្លាក់មធ្យមភាគ (ប្រចាំឆ្នាំ ឬក្រៅចំណាត់ថ្នាក់) | 1 | | |
| ៩ | ចំនួនថ្នាក់មានការប្រជុំរវាងគ្រូបង្រៀន មាតាបិតា និងសិស្សរៀនយឺត (សិស្សត្រូវថ្នាក់ពីឆ្នាំមុនសិស្សដែលមានពិន្ទុទាបជាង៦០%ពីចុង ឆ្នាំសិក្សាមុន និងនៅបំណាច់ខែទី១) ធៀបជា មួយក្រុមគោលដៅ | 1 | | |
| ១០ | កង្វះចំនួនម៉ោងបង្រៀនជាមធ្យមនៃថ្នាក់ទី៧ (ត្រូវពិនិត្យតាមដាននៅចុងឆមាសទី១ និងទី២) | 1 | | |
| ១១ | កង្វះចំនួនម៉ោងបង្រៀនជាមធ្យមនៃថ្នាក់ទី៨ (ត្រូវពិនិត្យតាមដាននៅចុងឆមាសទី១ និងទី២) | 1 | | |
| ១២ | កង្វះចំនួនម៉ោងបង្រៀនជាមធ្យមនៃថ្នាក់ទី៩ (ត្រូវពិនិត្យតាមដាននៅចុងឆមាសទី១ និងទី២) | 1 | | |
| ១៣ | ភាគរយសិស្សអវត្តមានតិចជាង៥ដង | | 2 | |
| ១៤ | ភាគរយសិស្សអវត្តមានពី៥ទៅ១០ដង | 1 | | |
| ១៥ | ភាគរយសិស្សអវត្តមានច្រើនជាង១០ដង | 1 | | |
| ១៦ | ភាគរយសិស្សថ្នាក់ទី៧បានទទួលលំហាត់ឬកិច្ចការផ្ទះដាក់ឱ្យតាមមុខវិជ្ជាគោល(ភាសាខ្មែរ គណិតវិទ្យា និងវិទ្យាសាស្ត្រ) ធៀបក្រុមគោលដៅគ្រោងទុក | | 2 | |

| | | | | |
|---|---|---|---|---|
| ១៧ | ភាគរយសិស្សថ្នាក់ទី៨បានទទួលលំហាត់ឬកិច្ចការផ្ទះ ដាក់ឱ្យតាមមុខវិជ្ជាគោល(ភាសាខ្មែរ គណិតវិទ្យា និង វិទ្យាសាស្ត្រ) ធៀបក្រុមគោលដៅគ្រោងទុក | | 2 | |
| ១៨ | ភាគរយសិស្សថ្នាក់ទី៩បានទទួលលំហាត់ឬកិច្ចការផ្ទះ ដាក់ឱ្យតាមមុខវិជ្ជាគោល(ភាសាខ្មែរ គណិតវិទ្យា និង វិទ្យាសាស្ត្រ) ធៀបក្រុមគោលដៅគ្រោងទុក | | 2 | |
| ១៩ | ភាគរយសិស្សថ្នាក់ទី៧បានទទួលកិច្ចការផ្ទះគម្រោងដាក់ ឱ្យតាមមុខវិជ្ជាគោល (ភាសាខ្មែរ គណិតវិទ្យា និងវិទ្យាសាស្ត្រ) ធៀបគោលដៅគ្រោង | | 2 | |
| ២០ | ភាគរយសិស្សថ្នាក់ទី៨បានទទួលកិច្ចការផ្ទះគម្រោងដាក់ ឱ្យតាមមុខវិជ្ជាគោល (ភាសាខ្មែរ គណិតវិទ្យា និងវិទ្យា សាស្ត្រ) ធៀបក្រុមគោលដៅគ្រោងទុក | 1 | | |
| ២១ | ភាគរយសិស្សថ្នាក់ទី៩បានទទួលកិច្ចការផ្ទះគម្រោងដាក់ ឱ្យតាមមុខវិជ្ជាគោល (ភាសាខ្មែរ គណិតវិទ្យា និងវិទ្យា សាស្ត្រ) ធៀបក្រុម គោលដៅគ្រោងទុក | | 2 | |
| ២២ | ចំនួនគ្រូបង្រៀនក្រោមគោលដៅបានទទួលការបំប៉ននិង ការជួយបង្រៀននៅនឹងកន្លែង | 1 | | |
| ២៣ | ចំនួនថ្នាក់រៀនបានបំពេញរដ្ឋបាលថ្នាក់តាមការ ណែនាំ របស់ក្រសួងធៀបជាមួយក្រុមគោលដៅ | | 2 | |
| ២៤ | ភាគរយគ្រូបង្រៀនបើកថ្នាក់យឺតនិងបិទថ្នាក់មុនម៉ោង បានថយចុះធៀបជាមួយក្រុមគោលដៅ | | 2 | |
| ២៥ | ចំនួនមុខវិជ្ជាអប់រំកាយ កីឡា និងសិល្បៈបាន បង្រៀនតាមក្រុមគោលដៅគ្រោង(សរុប១៤មុខវិជ្ជា) | 1 | | |
| សុរប | | 39 | | |
| ពិន្ទុស្តង់ដាអប្បរមាគឺ ៦៥% មានន័យថាស្តង់ដានេះត្រូវមានពិន្ទុយ៉ាងតិច៥១ ដើម្បីបំពេញបាននូវស្តង់ដាអប្បរមា ។ | | | | |

តាមតារាងទី៥ បង្ហាញពីប្រសិទ្ធភាពការបង្រៀន និងរៀនរបស់លោកគ្រូអ្នកគ្រូមធ្យមសិក្សាបឋមភូមិសាលាគោលដៅទាំងប្រាំពីរដែលបានអនុវត្តការគ្រប់គ្រងតាមសាលារៀន ។ យោងតាមចម្លើយរបស់លោកគ្រូអ្នកគ្រូដែលបានផ្តល់បានបង្ហាញអោយឃើញថាការអនុវត្តការបង្រៀន និងរៀនគឺនៅមានកម្រិតទាបនៅឡើយដោយពិន្ទុសរុបពីការវាយតម្លៃស្មើនឹង៣៩ បើប្រៀបធៀបទៅនឹងស្តង់ដាសាលាមាន ប្រសិទ្ធភាពយើងឃើញថាពិន្ទុនេះពុំបានស្មើ ៦៥% រឺស្មើនិង៥១ពិន្ទុនោះទេ នេះបញ្ជាក់បានថា ការអនុវត្តស្តង់ដាទី២ ប្រសិទ្ធភាពការបង្រៀន និងរៀន នៅតាមសាលាគោលដៅទាំងប្រាំពីរក្នុងរាជធានីភ្នំពេញពុំទាន់បានបំពេញស្តង់ដានៅឡើយទេ ។ តាមរយៈការស្រាវជ្រាវ ដោយការចូលរួមផ្តល់ចម្លើយការសម្ភាសន៍ និងការពិនិត្យអង្កេតធ្វើអោយអ្នកស្រាវជ្រាវអាចរកឃើញបញ្ហាប្រឈមដែលកើតមានក្នុងការអនុវត្តការលើបង្រៀន និងរៀនគឺមាន ៖ កង្វះម៉ោងបង្រៀនសម្រាប់ថ្នាក់ទី៩មានកម្រិតមធ្យមដែលជាបញ្ហាធ្វើឱ្យជះឥទ្ធិពលលើលទ្ធផលសិក្សារបស់សិស្ស និងលទ្ធផលប្រលងរបស់សិស្សថ្នាក់ទី៩ ។ ចំណែកចំនួនសិស្សអវត្តមានចាប់ពី៥ដងរហូតដល់ច្រើនជាង១០នៅមានកម្រិតមធ្យមសិក្សាបឋមភូមិសម្រាប់សាលាគោលដៅទាំងប្រាំពីរមានន័យថាសិស្សអវត្តមានក្នុងម៉ោងសិក្សាច្រើន ដូច្នេះសាលាគួរមានវិធានការទប់ស្កាត់ និងស្វែងរកមូលហេតុដែលបណ្តាលអោយសិស្សគេចម៉ោងសិក្សាថាតើបណ្តាលមកពីកត្តាអ្វី ព្រមទាំងរកដំណោះស្រាយក្នុងការទប់ស្កាត់ការឈប់របស់សិស្សក្នុងម៉ោងសិក្សា ។ មួយវិញទៀតនោះគឺបញ្ហាដែលជាបញ្ហាប្រឈមក្នុងការបង្រៀន និងរៀនដែរនោះគឺការបើកថ្នាក់រៀនយឺតរបស់លោកគ្រូអ្នកគ្រូមធ្យមសិក្សាបឋមភូមិសាលាគោលដៅទាំងប្រាំពីរគឺស្ថិតនៅក្នុងកម្រិតទាបដែលនេះជាបញ្ហាមួយចោទសម្រាប់ដំណើរការបង្រៀន និងរៀន ដោយការបើកថ្នាក់រៀនមានសភាពយឺតយ៉ាវ ។

### ៤.១.២.៣ មាតាបិតា និងសហគមន៍ជួយការសិក្សាសិស្ស

*តារាងទី៦ ៖ មាតាបិតា និងសហគមន៍ជួយការសិក្សាសិស្ស*

| ល.រ | ខ្លឹមសារ | ១ | ២ | ៣ |
|---|---|---|---|---|
| ១ | ភាគរយថ្នាក់រៀនបានប្រជុំប្រឹក្សាយោបល់រវាងគ្រូបង្រៀន មាតាបិតា និងសិស្ស (នៅដើមឆ្នាំសិក្សានិងតាមត្រីមាស) | | 2 | |
| ២ | ចំនួនប្រជុំគណៈកម្មការគ្រប់គ្រងសាលារៀនតាមការណែនាំ (ពេលបើកបវេសនកាល ចុងឆមាសទី១ និងទី២) | 1 | | |
| ៣ | ភាគរយសិស្សមករៀនយឺត | 1 | | |
| ៤ | ភាគរយសិស្សបានធ្វើកិច្ចការផ្ទះឬកិច្ចកាគម្រោង | | 2 | |
| | សរុប | 6 | | |

| |
|---|
| ពិន្ទុស្តង់ដាអប្បរមាគឺ ៦៥% មានន័យថាស្តង់ដានេះត្រូវមានពិន្ទុយ៉ាងតិច៨ ដើម្បីបំពេញបាននូវស្តង់ដាអប្បរមា ។ |

តារាងទី៦ បង្ហាញពីមាតាបិតា និងសហគមន៍ជួយការសិក្សារបស់សិស្ស ។ តាមរយៈការផ្តល់យោបល់ពីគណៈកម្មការគ្រប់គ្រងសាលារៀន និងមាតាបិតាសិស្សាសាលាគោលដៅទាំងប្រាំពីរក្នុងរាជធានីបានបង្ហាញឱ្យឃើញថា ការចូលរួមរបស់មាតាបិតា និងសហគមន៍ ក្នុងការជួយការសិក្សារបស់សិស្សគឺនៅមានកម្រិតទាប ដោយមើលឃើញថាពិន្ទុបានពីការវាយតម្លៃស្មើ៦ បើធ្វើការប្រៀបធៀបទៅនឹងពិន្ទុស្តង់ដាសាលាមានប្រសិទ្ធភាពឃើញថាពុំបានស្មើចំនួនអប្បបរមាដែលបានកំណត់ស្មើ៦៥% រឺ៨ពិន្ទុនោះទេ ដូច្នេះអាចបញ្ជាក់បានថាការអនុវត្តរបស់សាលារៀនលើស្តង់ដាទី៣នេះពុំទាន់បានបំពេញស្តង់ដានៅឡើយទេ ។ តាមរយៈការសម្ភាស៍ និងការចូលរួមឆ្លើយពីសំណាក បានធ្វើអោយអ្នកស្រាវជ្រាវ រកឃើញនូវបញ្ហាប្រឈមមួយចំនួនដែលកើតមានឡើងដូចជា ការប្រជុំគណៈកម្មការគ្រប់គ្រងសាលារៀនគឺមានចំនួនតិច ដែលសាលាមួយចំនួននៃ
សាលាគោលដៅគឺបានធ្វើការប្រជុំគណៈកម្មការគ្រប់គ្រងសាលា រៀនបានត្រឹមតែ១ដងប៉ុណ្ណោះក្នុងមួយឆ្នាំសិក្សា រីឯសាលាមួយចំនួនទៀតអាចមានពីរ ទៅបី ដងក្នុងមួយឆ្នាំសិក្សា ។

### ៤.១.២.៤ សិស្ស និងសេវាជួយសិស្ស

***តារាងទី៧ ៖ សិស្ស និងសេវាជួយសិស្ស***

| ល.រ | ខ្លឹមសារ | ១ | ២ | ៣ |
|---|---|---|---|---|
| ១ | ភាគរយសិស្សប្រើបណ្ណាល័យ (ពិនិត្យតាមដានរាល់ត្រីមាស) | 1 | | |
| ២ | ភាគរយសិស្សប្រើបន្ទប់ពិសោធន៍ | 1 | | |
| ៣ | ភាគរយសិស្សប្រើកុំព្យូទ័រ | 1 | | |
| ៤ | ភាគរយថ្នាក់មានដំណើរការ (តាមការណែនាំរបស់ក្រសួង) ក្លឹបសិស្សាសិស្ស | 1 | | |
| ៥ | ភាគរយសិស្សខ្សោយគំហើញនិងខ្សោយស្តាប់បានទទួលការគាំទ្រដើម្បីរៀនបានប្រសើរ | | 2 | |
| ៦ | ភាគរយសិស្សអាហារូបករណ៍បោះបង់ការសិក្សា | 1 | | |
| ៧ | ចំនួនទស្សនកិច្ចសិក្សារបស់គ្រូបង្រៀន | | 2 | |
| សរុប | | 9 | | |
| ពិន្ទុស្តង់ដាអប្បរមាគឺ ៦៥% មានន័យថាស្តង់ដានេះត្រូវមានពិន្ទុយ៉ាងតិច១៤ ដើម្បីបំពេញបាននូវស្តង់ដាអប្បរមា ។ | | | | |

តាមតារាងទី៧បង្ហាញពីសេវាសិស្សជួយសិស្សនៅមធ្យមសិក្សាបឋមភូមិសាលាគោលដៅទាំងប្រាំពីរក្នុងរាជធានីភ្នំពេញ ។ តាមរយៈការផ្តល់យោបល់ពីសិស្សានុសិស្សបានបង្ហាញឱ្យឃើញថានៅមធ្យមសិក្សាបឋមភូមិសាលាគោលដៅទាំងប្រាំពីរមានកម្មវិធីសិស្ស និងសេវាជួយសិស្សអនុវត្តក្នុងកម្រិតទាបនៅឡើយធៀបទៅនឹងស្តង់ដាសាលាមានប្រសិទ្ធភាព ដោយពិន្ទុបានមកពីការវាយតម្លៃរួមសម្រាប់ស្តង់ដាទី៤នេះគឺបានត្រឹមតែ៩ពិន្ទុគឺ មានន័យថាមិនបានអនុវត្តបានដល់ពិន្ទុអប្បបរមាដែលស្មើ ៦៥% រឺ១៤ពិន្ទុនៅក្នុងស្តង់ដាទី៤នៃសាលាមានប្រសិទ្ធភាពនោះទេ ។ នេះអាចបញ្ជាក់បានថាការអនុវត្តស្តង់ដាទី៤ សិស្ស និងសេវាជួយសិស្សសម្រាប់សាលាគោលដៅទាំងប្រាំពីរក្នុងរាជធានីភ្នំពេញពុំទាន់បានបំពេញស្តង់ដានោះទេ ។ ចំពោះបញ្ហាប្រឈមដែលអ្នកស្រាវជ្រាវបានរកឃើញបន្ទាប់ពីការចូលរួមឆ្លើយ ការសម្ភាសន៍ និងការអង្កេតមានដូចជាការចូលបណ្ណាល័យរបស់សិស្សានុសិស្សគឺនៅមានកម្រិតទាប ដោយសាលាពុំមួយមានបណ្ណាល័យប៉ុន្តែពុំមានដំណើរការ សាលាខ្លះទៀតបណ្ណាល័យ មានដំណើរការប៉ុន្តែពុំមានសៀវភៅគ្រប់គ្រាន់សម្រាប់តម្រូវការរបស់សិស្សក្នុងការអាន រឺ ស្រាវ ជ្រាវនិងពុំមានបណ្ណារ័ក្សគ្រប់គ្រងត្រឹមត្រូវ ។ ការប្រើប្រាស់បន្ទប់ពិសោធន៍របស់សិស្ស នៅតាមសាលាក៏នៅមានកម្រិតទាបដែរ ដោយមើលឃើញថាសាលាមួយចំនួនធំមានតែបន្ទប់ពិសោធន៍ប៉ុន្តែពុំមានសូវមានដំណើរការកម្មវិធីពិសោធន៍ មួយវិញទៀតសាលាក៏នៅ មានការខ្វះខាតសម្ភារៈពិសោធន៍លើផ្នែកវិទ្យាសាស្រ្តមួយចំនួនធំផងដែរ ។ សម្រាប់ការប្រើប្រាស់ បន្ទប់ កុំព្យូទ័រនៅតាមសាលារៀនគោលដៅវិញឃើញថានៅមានកម្រិតទាបដោយសារតែសាលា មួយចំនួនមានការខ្វះខាតកុំព្យូទ័រសម្រាប់បំរើបម្រាស់ក្នុងការបង្រៀន និងរៀន មួយវិញទៀតគឺកុំព្យូទ័រសាលាមួយចំនួនមានសភាពចាស់ និងមានការខូចខាតដោយគ្មានការជួសជុល រីឯសាលាមួយចំនួនទៀតពុំមានគ្រូឯកទេសផ្នែកព័ត៌មានវិទ្យាដែលធ្វើអោយដំណើរការម៉ោងសិក្សាកុំព្យូទ័រពុំមានដំណើរការ ។

### ៤.១.២.៥ ការដឹកនាំ និងការគ្រប់គ្រងសាលារៀន

*តារាងទី៨ ៖ ការដឹកនាំ និងការគ្រប់គ្រងសាលារៀន*

| ល.រ | ខ្លឹមសារ | ១ | ២ | ៣ |
|---|---|---|---|---|
| ១ | ចំនួនសូចនាកររដ្ឋបាលសាលារៀនបានបំពេញ ការណែនាំក្រសួង (សរុប១០សូចនាករ) | | 2 | |
| ២ | ការអនុវត្តផែនការអធិការកិច្ចរបស់នាយក/នាយិកា ឬនាយករង/នាយិការង | | 2 | |
| ៣ | ចំនួនការប្រជុំបច្ចេកទេសប្រចាំខែតាម ការណែនាំរបស់ក្រសួង (សរុប៧ដងក្នុង១ឆ្នាំ) | | | 3 |
| ៤ | ចំនួនដងបំប៉ននិងដឹកដៃធ្វើការងារនៅនឹងកន្លែងដល់នាយក និងគណៈកម្មការគ្រង់គ្រងសាលារៀនដោយមន្ត្រីក្រសួង ដើម្បីកែលម្អសូចនាករគ្រប់គ្រងសាលារៀន | | 2 | |

| | | | | |
|---|---|---|---|---|
| ៥ | ចំនួនគ្រូបង្រៀនបានបំពេញការងារប្រសើរជាងមុនតាមរយៈវាយតម្លៃការអនុវត្តការងារប្រចាំឆ្នាំ | | 2 | |
| ៦ | បន្ថយភាពមិនប្រក្រតីសាលា(សរុប៩ភាពមិនប្រក្រតី) | | 2 | |
| ៧ | ចំនួនដងពិនិត្យតាមដាននិងគាំទ្រពីស្រុក មន្ទីរ &ក្រសួង | | 2 | |
| សរុប | | 15 | | |
| ពិន្ទុស្តង់ដាអប្បរមាគឺ ៦៥% មានន័យថាស្តង់ដានេះត្រូវមានពិន្ទុយ៉ាងតិច១៤ ដើម្បីបំពេញបាននូវស្តង់ដាអប្បរមា ។ | | | | |

តារាងទី៨ បង្ហាញពីការដឹកនាំ និងគ្រប់គ្រងរបស់នាយកនៅមធ្យមសិក្សាបឋមភូមិសម្រាប់សាលាគោលដៅទាំងប្រាំពីរក្នុងរាជធានីភ្នំពេញ ។ តាមរយៈការផ្តល់យោបល់ពីនាយក សហគមន៍សិស្ស និងការពិនិត្យលើរបាយការណ៍ផ្សេងៗលើសាលាគោលដៅទាំងប្រាំពីរក្នុងរាជធានីបានបង្ហាញឱ្យឃើញថាការដឹកនាំ និងគ្រប់គ្រង របស់នាយកនៅមធ្យមសិក្សាបឋមភូមិសាលាគោលដៅទាំងប្រាំពីរគឺមានកម្រិតមធ្យម ។ បើធ្វើការប្រៀបធៀបពិន្ទុស្តង់ដានៃការអនុវត្តរបស់សាលាគោលដៅទាំងប្រាំពីរក្នុងរាជធានីភ្នំពេញទៅនឹងស្តង់ដាពិន្ទុសាលាមានប្រសិទ្ធភាពយើងឃើញថាការអនុវត្តរបស់សាលាគោលដៅទាំងប្រាំពីរក្នុងរាជធានីភ្នំពេញលើស្តង់ដាទី៥នេះគឺសាលាគោលដៅទាំងប្រាំពីរក្នុងរាជធានីភ្នំពេញបានបំពេញបាននូវស្តង់ដាសាលាមានប្រសិទ្ធភាពដោយមានពិន្ទុសរុបស្មើ១៥ ។ ឆ្លងតាមរយៈការផ្តល់បទសម្ភាសន៍ការចូលរួមគូសលើកិច្ចការស្រាវជ្រាវ ព្រមទាំងការសង្កេតលើរបាយការណ៍មួយចំនួនដោយផ្ទាល់អ្នកស្រាវជ្រាវបានរកឃើញនូវបញ្ហាប្រឈមមួយលើការដឹកនាំ និងគ្រប់គ្រងតាមសាលាគោលដៅទាំងប្រាំពីរក្នុងរាជធានី ភ្នំពេញដែលមានដូចជា ៖ សាលារៀនគោលដៅមួយចំនួនធំនៅមិនទាន់បានអនុវត្តផែនការអធិការកិច្ចរបស់នាយកបានល្អនៅឡើយនោះទេ ដោយសាលា មួយចំនួនបានអនុវត្តតែ២ដងក្នុងមួយឆ្នាំសិក្សា ឯសាលាមួយចំនួនទៀតមិនបានអនុវត្តទាល់ តែសោះក្នុងការចុះអធិការកិច្ចអចិន្ត្រៃយ៍ពីគណៈនាយកលើការបង្រៀន និងរៀនរបស់លោកគ្រូអ្នកគ្រូ ។ មួយវិញទៀតនោះចំពោះការកាត់បន្ថយភាពមិនប្រក្រតីនៅក្នុងសាលារៀនវិញឃើញថានៅមិនទាន់បានកាត់បន្ថយអស់នៅឡើយទេចំពោះភាពមិនប្រក្រតីសម្រាប់សាលារៀនមួយចំនួនតូចនៅក្នុងចំណោមសាលាគោលដៅទាំងប្រាំពីរគឺនៅមានបញ្ហាប្រមូលថវិកាពីសិស្សសម្រាប់ការប្រឡងប្រចាំខែ និងមានលក់មេរៀនដល់សិស្សសម្រាប់មុខវិជ្ជាមួយចំនួន ។

### ៤.១.២.៦ ធនធានមនុស្ស

***តារាងទី៩ ៖ ធនធានមនុស្ស***

| ល.រ | ខ្លឹមសារ | ១ | ២ | ៣ |
|---|---|---|---|---|
| ១ | គុណវុឌ្ឍិគ្រូបង្រៀនធៀបជាមួយផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន | | 2 | |
| ២ | ចំនួនគ្រូខ្វះមុខវិជ្ជាភាសាខ្មែរ គណិតវិទ្យា | 1 | | |

| | | | | |
|---|---|---|---|---|
| | វិទ្យាសាស្ត្រនិងវិទ្យាសាស្ត្រសង្គម(ប្រវត្តិវិទ្យា) ចុះថយធៀបជាមួយបទដ្ឋាន | | | |
| ៣ | គុណវុឌ្ឍិនាយកឬនាយិកាសាលារៀនធៀប ជាមួយផែនការក្រសួង | | 2 | |
| សរុប | | 5 | | |
| ពិន្ទុស្តង់ដាអប្បរមាគឺ ៦៥% មានន័យថាស្តង់ដានេះត្រូវមានពិន្ទុយ៉ាងតិច៦ ដើម្បីបំពេញបាននូវស្តង់ដាអប្បរមា ។ | | | | |

សម្រាប់តារាងទី៩នេះបានបង្ហាញឱ្យឃើញថាការអនុវត្តស្តង់ដាទី៦ស្តីពីធនធានមនុស្ស នៅផ្នែកមធ្យមសិក្សាបឋមភូមិនៃសាលាគោលដៅទាំងប្រាំពីរក្នុងរាជធានីភ្នំពេញ គឺមិនទាន់បានបំពេញស្តង់ដានៅឡើយទេដោយឃើញថាពិន្ទុសរុបដែលបានមកពីការចូលរួមផ្តល់មតិយោបល់នាយក គ្រូបង្រៀននៅតាមសាលារៀនគោលដៅទាំងប្រាំពីរឃើញថាពិន្ទុសរុបបាន៥ពិន្ទុ បើធៀបទៅនឹងស្តង់ដាសាលារៀនមានប្រសិទ្ធភាពយើងឃើញថាសាលារៀនគោលដៅទាំងប្រាំពីរក្នុងរាជធានីភ្នំពេញមិនទាន់បានបំពេញនូវស្តង់ដាអប្បបរមានៅឡើយទេ ដែលស្មើនឹង៦៥% រឺស្មើ៦ពិន្ទុ ។ តាមរយៈការផ្តល់យោបល់ពីនាយក គ្រូបង្រៀនសាលាគោលដៅទាំងប្រាំពីរនៅក្នុងរាជធានីភ្នំពេញបានបង្ហាញឱ្យឃើញថាធនធានមនុស្សនៅក្នុងសាលារៀនគឺស្ថិតក្នុងកម្រិតនៅឡើយសម្រាប់ការអភិវឌ្ឍលើគុណវុឌ្ឍិគ្រូបង្រៀន គុណវុឌ្ឍនាយកសាលារៀន ។ តាមរយៈការស្រាវជ្រាវឃើញថាសាលារៀនមួយចំនួនក្នុងចំណោមសាលាគោលដៅទាំងប្រាំ ពីរក្នុងរាជធានីភ្នំពេញនៅមានបញ្ហាប្រឈម និងការខ្វះគ្រូមុខវិជ្ជាភាសាខ្មែរ គណិតវិទ្យា វិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រ សង្គម(ប្រវត្តវិទ្យា)នៅឡើយ ។ មូលហេតុដែលធ្វើអោយមានការខ្វះខាតគ្រូមុខវិជ្ជាគឺគ្រូមួយចំនួនដល់អាយុចូលនិវត្ត មួយផ្សេងទៀតលោកគ្រូអ្នកគ្រូមួយចំនួនបានធ្វើការសុំផ្លាស់ប្តូរទីកន្លែងធ្វើការដោយសាលាឆ្ងាយពីផ្ទះរបស់គាត់ ដែលជាហេតុធ្វើអោយ សាលាមានការខ្វះខាតលើគ្រូមុខវិជ្ជាមួយចំនួនតូច ។

### ៤.១.២.៧ សៀវភៅសិក្សាគោល និងសម្ភារៈរៀន និងបង្រៀន

***តារាងទី១០ ៖ សៀវភៅសិក្សាគោល និងសម្ភារៈរៀន និងបង្រៀន***

| ល.រ | ខ្លឹមសារ | ១ | ២ | ៣ |
|---|---|---|---|---|
| ១ | ភាគរយសិស្សមានសៀវភៅគោលតាមមុខវិជ្ជា និងតាមកម្រិតថ្នាក់តាមបទដ្ឋាន | | 2 | |
| ២ | ចំនួនគ្រូបង្រៀនមុខវិជ្ជាគោលបានបំប៉នពីការប្រើប្រាស់សៀវភៅលំហាត់ | | 2 | |
| ៣ | បណ្ណាល័យបានបង្កើត និងមានស្តង់ដា | 1 | | |
| សរុប | | 5 | | |
| ពិន្ទុស្តង់ដាអប្បរមាគឺ ៦៥% មានន័យថាស្តង់ដានេះត្រូវមានពិន្ទុយ៉ាងតិច៦ ដើម្បីបំពេញបាននូវស្តង់ | | | | |

| ដាអប្បរមា ។ |
| --- |

សម្រាប់តារាងទី១០នេះបានបង្ហាញឱ្យឃើញថាការអនុវត្តស្តង់ដាទី៦ស្តីពីសៀវភៅសិក្សាគោល និងសម្ភារៈរៀននិងបង្រៀននៅផ្នែកមធ្យមសិក្សាបឋមភូមិនៃសាលាគោលដៅទាំងប្រាំពីរ ក្នុងរាជធានីភ្នំពេញ គឺមិនទាន់បានបំពេញស្តង់ដានៅឡើយទេដោយឃើញថាពិន្ទុសរុបដែលបានមកពីការចូលរួមផ្តល់មតិយោបល់នាយក គ្រូបង្រៀន នៅតាមសាលារៀនគោលដៅទាំងប្រាំពីរឃើញថាពិន្ទុសរុបបាន៥ពិន្ទុ បើធៀបទៅនឹងស្តង់ដាសាលារៀនមានប្រសិទ្ធភាពយើងឃើញថាសាលារៀនគោលដៅទាំងប្រាំពីរក្នុងរាជធានីភ្នំពេញមិនទាន់បានបំពេញនូវស្តង់ដាអប្បបរមានៅឡើយទេដែលស្មើនឹង៦៥% រឺស្មើ៦ពិន្ទុ ។ យោងតាមទិន្នន័យក្នុងតារាងបានបង្ហាញអោយឃើញថាសៀវភៅសិក្សាគោលតាមមុខវិជ្ជា និងតាមកម្រិតថ្នាក់តាមមូលដ្ឋាននៅតាមសាលានីមួយៗគឺសិស្សមានប្រើប្រាស់គ្រប់ៗគ្នា ដោយសិស្សម្នាក់ មានសៀវភៅសិក្សា១ក្បាលគ្រប់មុខវិជ្ជា រីឯលោកគ្រូអ្នកគ្រូវិញក៏មានសៀវភៅប្រើប្រាស់ គ្រប់គ្រាន់សម្រាប់ជំនួយដល់ការបង្រៀនផងដែរ ។ ចំណែកឯគ្រូបង្រៀនមុខវិជ្ជាគោលសាលារៀនបានជំរុញឱ្យទៅបំប៉នពីការប្រើប្រាស់សៀវភៅតាមរយៈការចូលរួមសិក្សាសាលាពីការប្រើប្រាស់ និងអនុវត្តកម្មវិធីសិក្សាថ្មីៗជាមួយថ្នាក់មន្ទីរ រឺក្រសួងដើម្បីឱ្យលោកគ្រូអ្នកគ្រូយល់កាន់តែច្បាស់ពីអត្ថន័យខ្លឹមសារនៃសៀវភៅព្រមទាំងងាយស្រួលក្នុងការស្វែងរកគន្លឹះដើម្បីងាយស្រួលក្នុងការពន្យល់សិស្សអោយកាន់តែឆាប់ចាប់បាន និងងាយយល់ ។ ចំពោះការបង្កើតបណ្ណាល័យសាលារៀននៅតាមសាលារៀនគោលដៅទាំងប្រាំពីរវិញឃើញថាមានសាលាមួយចំនួនបានអនុវត្ត និងមានបន្ទប់បណ្ណាល័យព្រមទាំងមានសៀវភៅគ្រប់គ្រាន់ប៉ុន្តែ ក៏នៅតែមិនទាន់ជាបណ្ណាល័យដែលស្របតាមស្តង់ដាបណ្ណាល័យធម្យមសិក្សាផងដែរ ដោយសារបណ្ណាល័យនៅមិនទាន់មានសម្ភារៈគ្រប់គ្រាន់ដូចជាកុំព្យូទ័រ ការកត់ត្រាកូដសៀវភៅ បណ្ណារ័ក្សមិនមានជំនាញច្បាស់លាស់និងពុំបានឆ្លងកាត់វគ្គបណ្តុះបណ្តាលបណ្ណារ័ក្សដែលជាមូលហេតុធ្វើអោយដំណើរ ការបណ្ណាល័យនៅមានកម្រិតទាបនៅឡើយ ។

### ៤.១.២.៨ ហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថានសាលារៀន

***តារាងទី១១ ៖ ហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថានសាលារៀន***

| ល.រ | ខ្លឹមសារ | ១ | ២ | ៣ |
| --- | --- | --- | --- | --- |
| ១ | កង្វះបន្ទប់រៀនថយចុះរហូតមានចំនួនសិស្សក្នុងបន្ទប់រៀនតាមបទដ្ឋាន | | 2 | |
| ២ | បន្ទប់ស្នាក់នៅរបស់គ្រូបង្រៀនបានសាងសង់ តាមតម្រូវការ | 1 | | |
| ៣ | បន្ទប់រដ្ឋបាលសាលារៀន និងសង្ហារឹមបានផ្តល់ តាមតម្រូវការ | | 2 | |
| ៤ | បន្ទប់ទឹកបានសាងសង់តាមស្តង់ដា និងគ្រប់គ្រាន់តាម | | 2 | |

| | | | | |
|---|---|---|---|---|
| | បទដ្ឋានសម្រាប់សិស្សទាំងស្រីទាំងប្រុស | | | |
| សរុប | | 7 | | |
| ពិន្ទុស្តង់ដាអប្បរមាគឺ ៦៥% មានន័យថាស្តង់ដានេះត្រូវមានពិន្ទុយ៉ាងតិច១០ ដើម្បីបំពេញបាននូវស្តង់ដាអប្បរមា ។ | | | | |

តារាងទី៩នេះបានបង្ហាញឱ្យឃើញថាការអនុវត្តស្តង់ដាទី៨ស្តីពីហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថានសាលារៀននៅផ្នែកមធ្យមសិក្សាបឋមភូមិនៃសាលាគោលដៅទាំងប្រាំពីរ ក្នុងរាជធានីភ្នំពេញ គឺមិនទាន់បានបំពេញស្តង់ដានៅឡើយទេដោយឃើញថាពិន្ទុសរុបដែលបានមកពីការចូលរួមផ្តល់មតិយោបល់នាយក និងការអង្កេតផ្ទាល់នៅតាមសាលារៀនគោលដៅទាំងប្រាំពីរឃើញថាពិន្ទុសរុបបាន ៧ពិន្ទុ បើធៀបទៅនឹងស្តង់ដាសាលារៀនមានប្រសិទ្ធភាពយើងឃើញថាសាលារៀនគោលដៅទាំងប្រាំពីរក្នុងរាជធានីភ្នំពេញមិនទាន់បានបំពេញនូវស្តង់ដាអប្បបរមានៅឡើយទេដែលស្មើនឹង៦៥% រឺស្មើ ១០ពិន្ទុ ។ មូលហេតុដែលធ្វើអោយការអនុវត្តមិនអាចបំពេញតាមស្តង់ដាសាលាមានប្រសិទ្ធភាពគឺបណ្តាលមកពីមូលហេតុមួយចំនួនដូចជាសាលាមួយចំនួននៅមានការខ្វះខាតសម្ភារៈបរិក្ខាសម្រាប់បន្ទប់ស្នាក់នៅរបស់គ្រូបង្រៀន និងសាលាខ្លះពុំមានបន្ទប់ស្នាក់នៅរបស់គ្រូបង្រៀន ។ មួយវិញទៀតសាលាមួយចំនួន ពុំមានសង្ហារឹមដែលបានផ្តល់តាមតម្រូវការប្រើប្រាស់នៅឡើយ និងសាលាពុំបានសាងសង់ បន្ទប់ទឹកស្របតាមស្តង់ដាតម្រូវការរបស់សិស្សគ្រប់គ្រាន់ និងពុំទាន់មានអនាម័យគ្រប់គ្រាន់ក្នុងបន្ទប់ទឹក ។

### ៤.១.២.៩ ហិរញ្ញប្បទាន និងការគ្រប់គ្រងហិរញ្ញវត្ថុ

***តារាងទី១២ ៖ ហិរញ្ញប្បទាន និងការគ្រប់គ្រងហិរញ្ញវត្ថុ***

| ល.រ | ខ្លឹមសារ | ១ | ២ | ៣ |
|---|---|---|---|---|
| ១ | ថវិកាសាលារៀន ពីប្រភពផ្សេងៗ បានទទួល ជាក់ស្តែងតាមត្រីមាស មានភាពប្រសើរឡើង | | 2 | |
| ២ | ការចាត់ចែងការប្រើប្រាស់និងតម្លាភាពថវិកាសាលារៀនបានប្រសើរ (សរុប៥សូចនាករ) | | 2 | |
| ៣ | ការរាយការណ៍ការចំណាយតាមខ្ទង់ចំណាយ ធំៗ (រដ្ឋបាល ការបង្រៀន និងរៀននិងបរិស្ថាន) បានប្រសើរដោយផ្តោតការចំណាយលើការបង្រៀននិងរៀន | | 2 | |
| សរុប | | 6 | | |
| ពិន្ទុស្តង់ដាអប្បរមាគឺ ៦៥% មានន័យថាស្តង់ដានេះត្រូវមានពិន្ទុយ៉ាងតិច៦ ដើម្បីបំពេញបាននូវស្តង់ដាអប្បរមា ។ | | | | |

តារាងទី១២នេះបានបង្ហាញឱ្យឃើញថាការអនុវត្តស្តង់ដាទី៩ស្តីពីហិរញ្ញប្បទាន និងការគ្រប់គ្រងហិរញ្ញវត្ថុសាលារៀននៅផ្នែកមធ្យមសិក្សាបឋមភូមិនៃសាលាគោលដៅទាំងប្រាំពីរក្នុងរាជធានីភ្នំពេញ គឺបំពេញបាននូវស្តង់ដាដោយឃើញថាពិន្ទុសរុបដែលបានមកពីការចូលរួមផ្តល់មតិយោបល់

នាយក គ្រូបង្រៀន សហគមន៍នៅតាមសាលារៀនគោលដៅទាំងប្រាំពីរឃើញថាពិន្ទុសរុបបាន៦ពិន្ទុ បើធៀបទៅនឹងស្តង់ដាសាលារៀនមានប្រសិទ្ធភាពយើងឃើញថាសាលារៀនគោលដៅទាំងប្រាំពីរក្នុងរាជធានីភ្នំពេញបានបំពេញនូវស្តង់ដាអប្បបរមាដែលស្មើនឹង៦៥% រឺស្មើ៦ពិន្ទុ ។ តាមរយៈទិន្នន័យតារាងខាងលើបានឆ្លុះបញ្ចាំងថាការប្រើប្រាស់ហិរញ្ញប្បទាន និងការគ្រប់គ្រងហិរញ្ញវត្ថុនៅតាមសាលារៀនបិតក្នុងកម្រិតខ្ពស់នេះបញ្ជាក់ថាសាលារៀនពិតជាបានអនុវត្តផ្នែកហិរញ្ញវត្ថុប្រកបដោយតម្លាភាព គណនេយ្យភាពត្រឹមត្រូវដែលជាទីទុកចិត្តសម្រាប់សហគមន៍មាតាបិតាសិស្ស លោកគ្រូអ្នកគ្រូក៏ដូចជាសិស្សានុសិស្ស ក្នុងដំណើរការអភិវឌ្ឍសាលារៀនប្រកបដោយចីរភាព ។

## ៤.២ ការពិភាក្សា

ផ្អែកលើលទ្ធផល នៃការសិក្សាស្រាវជ្រាវ យើងអាចសំយោគបានចំណុចវិជ្ជមាន និងបញ្ហាប្រឈម លើប្រសិទ្ធភាពនៃការអនុវត្តការគ្រប់គ្រងតាមសាលារៀន (SBM) នៅមធ្យមសិក្សាបឋមភូមិក្នុងរាជធានីភ្នំពេញដូចជា ៖

**ក- ចំណុចវិជ្ជមានលើការអនុវត្តការគ្រប់គ្រងតាមសាលារៀន (SBM)**

- វត្ថុបំណងគោលនយោបាយសាលារៀនមានចំណុចល្អ បំពេញបាននូវស្តង់ដាធៀបទៅនឹងស្តង់ដាសាលាមានប្រសិទ្ធភាព ។

- ការដឹកនាំ និងការគ្រប់គ្រងសាលារៀន បំពេញបាននូវស្តង់ដាធៀបទៅនឹងស្តង់ដាសាលាមានប្រសិទ្ធភាពអនុវត្តបានកម្រិតមធ្យម ។

- ហិរញ្ញប្បទាន និងការគ្រប់គ្រងហិរញ្ញវត្ថុ បានអនុវត្តសមស្របតាមស្តង់ដាបានកំណត់ ។

**ខ- បញ្ហាប្រឈមលើការអនុវត្តការគ្រប់គ្រងតាមសាលារៀន (SBM)**

- បញ្ហាសិស្សត្រួតថ្នាក់ និងសិស្សបោះបង់នៅតែជាបញ្ហាដែលកើតមានឡើងនៅកម្រិតមធ្យមសិក្សាមបឋមភូមិ ដែលមូលហេតុនេះបណ្តាលមកពី ការផ្លាស់ប្តូរទីលំនៅញឹកញ៉ាប់តាមគ្រួសារ បញ្ហាជីវភាពមានការខ្វះខាត និងបញ្ហាសិស្សមួយចំនួនសមត្ថភាពមានកម្រិត ។

- ការអនុវត្តម៉ោងសិក្សាមុខវិជ្ជា ICT នៅកម្រិតមធ្យមសិក្សាមបឋមភូមិមោនទាន់មានដំណើរការល្អនៅឡើយ មូលហេតុដោយសារ សាលាមួយចំនួនមានការខ្វះខាតកុំព្យូទ័រសម្រាប់ សិស្សប្រើប្រាស់ សាលាមួយចំនួនខ្វះគ្រូឯកទេសកុំព្យូទ័រ ។

- ការអនុវត្តមុខវិជ្ជាអប់រំកាយ និងកីឡា ព្រមទាំងសិល្បៈនៅតាមសាលារៀនពុំសូវមានដំណើរការ ដោយមូលហេតុសិស្សពុំសូវចាប់អារម្មណ៍ និងគ្រូបានអនុវត្តន៍តែពេលដើមឆ្នាំ ។

- ទំនាក់ទំនងមាតាបិតាសិស្សជាមួយសាលារៀននៅមានកម្រិតទាប ដោយមាតាបិតាមួយចំនួនពុំមានពេលគ្រប់គ្រាន់ក្នុងការចូលរួមជាមួយសាលា សាលាមួយចំនួនមិនទាន់បាន ធ្វើការផ្សព្វផ្សាយ

ដល់សហគមន៍ មាតាបិតាសិស្សពីគោលបំណង នឹងការអនុវត្តការគ្រប់គ្រងតាមសាលារៀនឱ្យពួកគាត់បានយល់ច្បាស់ ។

- សេវាសិស្សជួយសិស្សនៅមានកម្រិតទាបដោយផ្អែកលើការអនុវត្តការប្រើប្រាស់ បណ្ណាល័យ ការប្រើប្រាស់បន្ទប់ពិសោធន៍ ការប្រើប្រាស់កុំព្យូទ័ររបស់សិស្សនៅកម្រិតមធ្យមសិក្សាមបឋមភូមិមានកម្រិតទាប ។ មូលហេតុគឺបណ្តាលមកពី សាលាមួយចំនួនមានភាពខ្វះខាតសម្ភារៈក្នុងបណ្ណាល័យ បណ្ណាល័យនៅមិនទាន់មានស្តង់ដាគ្រប់គ្រាន់តាមននិយាមស្តង់ដា បណ្ណាល័យមធ្យមសិក្សា និងសាលាពុំមានម៉ោងសម្រាប់ការប្រើប្រាស់បណ្ណាល័យព្រមទាំងខ្វះការជំរុញសិស្សចូលអាចសៀវភៅក្នុងបណ្ណាល័យ ។ រីឯបន្ទប់ពិសោធន៍វិញសិស្សមិនសូវអនុវត្តដោយសារការខ្វះខាតលើសម្ភារៈពិសោធន៍លើមុខវិជ្ជាវិទ្យាសាស្រ្ត គ្រូមួយចំនួនពុំបានទទួលការបណ្តុះ បណ្តាលពីរបៀបនៃការប្រើប្រាស់សម្ភារៈពិសោធន៍ ។

- ការអនុវត្តផែនការអធិការកិច្ចរបស់នាយក ឬនាយករងដែលជាអធិការអចិន្ត្រៃយ៍នៅមានកម្រិតនៅឡើយសម្រាប់ការចុះអធិការលើការបង្រៀន និងរៀននៅតាមសាលារៀន ។

- ខ្វះខាតគ្រូឯកទេសសម្រាប់មុខវិជ្ជាមួយចំនួន គ្រូមិនទាន់បានបំពេញគុណវុឌ្ឍិគ្រប់ គ្រាន់ដោយមើលឃើញមានគ្រូបឋមសិក្សាមកបង្រៀននៅមធ្យមសិក្សាបឋមភូមិនៅឡើយ ។

- ហេដ្ឋារចនាសម្ព័ន្ធសាលារៀនមិនទាន់មានលក្ខណៈល្អប្រសើរនោះទេ បើធៀបនឹងស្តង់ដាសាលាមានប្រសិទ្ធភាព ។ មូលហេតុដោយសារតែសាលាមួយចំនួននៅមិនទាន់មាន បរិស្ថានស្អាតល្អ ខ្វះខាតបន្ទប់សម្រាប់គ្រូស្នាក់នៅ បន្ទប់រដ្ឋបាលសាលារៀនមិនទាន់មានគ្រឿងសង្ហារឹមគ្រប់គ្រាន់តាមស្តង់ដា ។ បន្ទប់ទឹកសាលារៀនមិនមានស្តង់ដា និង មិនមានគ្រប់គ្រាន់ស្របតាមតម្រូវការរបស់សិស្ស ។

# ជំពូកទី៥

# សេចក្តីសន្និដ្ឋាន និងសំណូមពរ

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន និងសំណូមពរ

## ៥.១ សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវ នឹងសង្កេតនៅតាមសាលារៀនគោលដៅទាំងប្រាំពីរក្នុងរាជធានីភ្នំពេញលើប្រធានបទ « ប្រសិទ្ធភាពការអនុវត្តការគ្រប់គ្រងតាមសាលារៀននៅមធ្យមសិក្សាបឋមភូមិក្នុងរាជធានីភ្នំពេញ » អ្នកសិក្សាស្រាវជ្រាវអាចសន្និដ្ឋានជារួមបានថា ការអនុវត្តការគ្រប់គ្រងតាមសាលារៀននៅមធ្យមសិក្សាបឋមភូមិក្នុងរាជធានីភ្នំពេញនៅមិនទាន់បំពេញបានស្តង់ដានៅឡើយទេ បើធៀបទៅនឹង ស្តង់ដាសាលាមានប្រសិទ្ធភាព ។

ផ្អែកទៅលើលទ្ធផលនៃការសិក្សាស្រាវជ្រាវបានរកឃើញថា ការអនុវត្តការគ្រប់គ្រងតាមសាលារៀននៅមធ្យមសិក្សាបឋមភូមិក្នុងរាជធានីភ្នំពេញឃើញថា ៖

១. ការអនុវត្តលើវត្ថុបំណងគោលនយោបាយសាលារៀននៅតាមសាលារៀនគោលដៅទាំងប្រាំពីរក្នុងរាជធានីភ្នំពេញគឺមានកម្រិតមធ្យមដោយសាលាបានអនុវត្តមានលក្ខណៈល្អលើផ្នែកមួយចំនួនធំដូចជា ការប្រមូលសិស្សចូលរៀន សិស្សឡើងថ្នាក់ អំណានរបស់សិស្សថ្នាក់ទី៩ និងសិស្សថ្នាក់ទី៩បានប្រឡងជាប់មធ្យមសិក្សាបឋមភូមិក្នុងកម្រិតខ្ពស់ ។ តែនៅមានផ្នែកខ្លះដែលសាលាអនុវត្តមិនទាន់មានលក្ខណៈល្អប្រសើរនៅឡើយដូចជា នៅមធ្យមសិក្សាបឋមភូមិសាលាគោលដៅទាំងប្រាំពីរគឺនៅមានបញ្ហាសិស្សត្រួតថ្នាក់ និងសិស្សបោះបង់នៅឡើយ ។ មួយវិញទៀតសិស្សមួយចំនួននៅមានកម្រិតទាបចំពោះអំណាន និងគណិតវិទ្យា រីឯបញ្ហាដែលប្រឈមការអនុវត្តម៉ោងសិក្សាមុខវិជ្ជា ICT នៅកម្រិតមធ្យមសិក្សាបឋមភូមិសម្រាប់សាលាគោលដៅមួយចំនួនគឺមិនទាន់មានដំណើរការនៅឡើយទេដោយសារតែសាលាមានការខ្វះខាតកុំព្យូទ័រសម្រាប់អោយសិស្សប្រើប្រាស់ និងសាលាមួយចំនួនទៀតមានកុំព្យូទ័រប៉ុន្តែភាគច្រើនខូច និងពុំមានការជួសជុល ព្រមទាំងខ្វះគ្រូឯកទេសកុំព្យូទ័រផងដែរ ។

២. ការបង្រៀន និងរៀននៅតាមសាលារៀនគោលដៅទាំងប្រាំពីរក្នុងរាជធានីភ្នំពេញគឺមិនទាន់បំពេញបានស្តង់ដានៅឡើយមានន័យថាការអនុវត្តសម្រាប់ការបង្រៀន និងរៀនគឺនៅមានកម្រិតទាប ។ សម្រាប់ការអនុវត្តការបង្រៀន និងរៀននៅតាមសាលារៀនគោលដៅទាំងប្រាំពីរក្នុងរាជធានីភ្នំពេញឃើញថាមានការអនុវត្តបានយ៉ាងល្អនៅចំណុចមួយចំនួនធំដូចជា លោកគ្រូអ្នកគ្រូមានធ្វើបំណែងចែកកម្មវិធីសិក្សាតាមមុខវិជ្ជាគ្រប់កម្រិតថ្នាក់ទាំងអស់ដោយមានការបែងចែកជាសប្តាហ៍ និងខែ ។ ចំពោះការសិក្សារបស់សិស្សវិញឃើញថាអត្រាឡើងថ្នាក់ និងការប្រឡងជាប់ឆមាសរបស់សិស្សានុសិស្សគឺមានអត្រាកើនឡើងខ្ពស់សម្រាប់ពិន្ទុ មុខវិជ្ជាគោល និងទទួលបានលទ្ធផលល្អ ។ ចំណែកឯកង្វះខាតម៉ោងបង្រៀននៅតាមថ្នាក់រៀនវិញឃើញថាមានការថយចុះគួរអោយកត់សម្គាល់ដោយសិស្សានុសិស្សបានផ្តល់ព័ត៌មានត្រឡប់ថាពួកគាត់ពុំមានការខ្វះខាតម៉ោងសិក្សាដូចមុនៗទៀតនោះទេ ។ នៅក្នុងនេះផងដែរ

សាលាក៏នៅមិនទាន់បានអនុវត្តបានល្អលើផ្នែកមួយចំនួនធំនៅក្នុងការបង្រៀន និងរៀនផងដែរដូចជា គ្រូបង្រៀននៅមិនទាន់បានប្រើប្រាស់កិច្ចតែងការបង្រៀន និងប្រើប្រាស់សំភារៈឧបទ្ទេសក្នុងម៉ោងបង្រៀន ការប្រជុំរវាងគ្រូបង្រៀន មាតាបិតាសិស្សរៀនយឺតនៅមិនទាន់មានដំណើរការគ្រប់សាលារៀននៅឡើយ ដោយសាលារៀនមួយចំនួនពុំមានទំនាក់ទំនងជាមួយមាតាបិតាសិស្សក្នុងការតាមដានការសិក្សារបស់កូនៗ ។ មួយវិញទៀតនោះអត្រាអវត្តមានសិស្សនៅមានកម្រិតមធ្យមនៅឡើយដែលបញ្ហាសិស្សអវត្តមានក៏ជាកិច្ចការប្រឈមមួយដែរ ដែលអាចជះឥទ្ធិពលទៅលើគុណភាពសិក្សារបស់សិស្ស ។ ចំណែកឯការអនុវត្តមុខវិជ្ជាអប់រំ កាយ និងកីឡា និងសិល្បៈនៅតាមសាលារៀនគោលដៅទាំងប្រាំពីរនេះយើងឃើញថានៅមានកម្រិតនៅឡើយដោយសាលារៀនមួយចំនួនពុំបានអនុវត្តសកម្មភាពអប់រំកាយ និងកីឡា និងសិល្បៈនោះទេគ្រាន់តែមានជារូបភាពនៅដើមឆ្នាំសិក្សា បន្ទាប់មកសកម្មភាព នៃការសិក្សាផ្នែកមុខវិជ្ជាអប់រំកាយ និងកីឡា និងសិល្បៈពុំបានអនុវត្តនោះទេ ។

៣. មាតាបិតា និងសហគមន៍ជួយការសិក្សាសិស្សនៅតាមសាលារៀនគោលដៅទាំងប្រាំពីរនៅក្នុងរាជធានីភ្នំពេញគឺនៅមានកម្រិតទាបដោយមើលឃើញថាពិន្ទុនៃការអនុវត្តតាមសាលារៀនគោលដៅទាំងប្រាំពីរ ធៀបនឹងស្តង់ដាសាលាមានប្រសិទ្ធភាពគឺមិនទាន់បំពេញបានស្តង់ដា ។ នៅក្នុងចំណុចនេះឃើញថាក្នុងចំណោមសាលាគោលដៅទាំងប្រាំពីរក្នុងរាជធានីភ្នំពេញគឺមានសាលាចំនួន៣ដែលបានអនុវត្តក៏ដូចជាមានការគាំទ្រពីសំណាក់មាតាបិតាក្នុងការចូលរួមតាមដាន ព្រមទាំងជួយដល់ការសិក្សារបស់កូនៗពួកគាត់ដោយពួកគាត់បានចូលរួមប្រជុំជាមួយគណៈកម្មការគ្រប់គ្រងសាលារៀន និងគណៈនាយកក្នុងការជំរុញតាមដានការសិក្សារបស់កូនៗពួកគាត់នៅផ្ទះក៏ដូចជានៅសាលារៀន ។ ចំណែកឯសាលាគោលដៅមួយចំនួនទៀតនៅពុំទាន់មានទំនាក់ទំនងល្អជាមួយមាតាបិតាសិស្សក្នុងការតាមដាន និងជួយដល់ការសិក្សារបស់កូនៗពួកគាត់នៅឡើយ ដោយក្នុងនោះនាយកសាលាបានរៀបរាប់ប្រាប់ថាមាតាបិតាសិស្សពុំមានពេលវេលាគ្រប់គ្រាន់ក្នុងការចូលរួមជាមួយសាលារៀន និង មានមាតាបិតាមួយចំនួនគឺពឹងផ្អែកទាំងស្រុងលើសាលាដោយពុំបានយកចិត្តទុកដាក់ក្នុងការជួយជំរុញកូនៗក្នុងការសិក្សាបន្ថែម ។

៤. សិស្ស និងសេវាជួយសិស្សនៅក្នុងសាលាគោលដៅទាំងប្រាំពីរក្នុងរាជធានីភ្នំពេញការអនុវត្តស្ថិតក្នុងកម្រិតទាប ។ បើធៀបទៅនឹងស្តង់ដាសាលាមានប្រសិទ្ធភាព សាលាគោលដៅទាំងប្រាំពីរអនុវត្តមិនទាន់បានល្អលើបញ្ហាមួយចំនួនដូចជា ការប្រើប្រាស់បណ្ណាល័យរបស់សិស្ស ការប្រើប្រាស់បន្ទប់ពិសោធន៍ និងការអនុវត្តការប្រើប្រាស់កុំព្យូទ័ររបស់សិស្សនៅមានកម្រិតទាប ។ តាមការសម្ភាសនិងការបកស្រាយពីសំណាកមួយចំនួនធំបានបង្ហាញអោយឃើញ ថាសាលារៀននៅមានការខ្វះខាតសម្ភារៈបណ្ណាល័យ បណ្ណាល័យនៅមិនទាន់មានស្តង់ដាគ្រប់គ្រាន់តាមនិយាម ស្តង់ដាបណ្ណាល័យមធ្យមសិក្សា និងសាលាពុំមានម៉ោងសម្រាប់ការប្រើប្រាស់បណ្ណាល័យព្រមទាំងពុំមានការជំរុញទឹកចិត្តសិស្សក្នុងការចូលប្រើប្រាស់បណ្ណាល័យ ។ រីឯបន្ទប់ពិសោធន៍វិញគឺសិស្សានុសិស្សពុំសូវបានចូលអនុវត្តលើមុខវិជ្ជា

ពិសោធន៍នោះទេ ដោយសារការខ្វះខាតលើសម្ភារៈពិសោធន៍លើមុខវិជ្ជាវិទ្យាសាស្ត្រគ្រូមួយចំនួនមិនចេះប្រើប្រាស់ សម្ភារៈពិសោធន៍មួយចំនួន ពុំមានកាលវិភាគលើម៉ោងបន្ទប់ពិសោធន៍ ។ ចំណែកឯការប្រើប្រាស់កុំព្យូទ័រវិញយើងឃើញថាសាលារៀនមួយចំនួនពុំមានកុំព្យូទ័រគ្រប់គ្រាន់សម្រាប់បំរើដល់ការសិក្សារបស់សិស្ស ចំពោះសាលាមួយចំនួនមានកុំព្យូទ័រប៉ុន្តែក្នុងនោះភាគច្រើនជាកុំព្យូទ័រខូច និងមិនមានការជួសជុល ម៉្យាងវិញទៀតសាលាមួយចំនួនទៀតនៅមានការខ្វះខាតគ្រូបច្ចេកទេសផ្នែកព័ត៌មានវិទ្យា ។

៥. ការអនុវត្តលើ ការដឹកនាំ និងគ្រប់គ្រងសាលារៀននៅតាមសាលាគោលដៅទាំងប្រាំពីរក្នុងរាជធានីភ្នំពេញបំពេញបាននូវពិន្ទុស្តង់ដាដោយធៀបនឹងស្តង់ដាសាលាមានប្រសិទ្ធភាព ។ សាលារៀនបានអនុវត្តបានល្អលើចំណុចមួយចំនួនធំ ការរៀបចំរដ្ឋបាលសាលារៀន ការប្រជុំប្រចាំខែ ការបំពេញការងាររបស់លោកគ្រូអ្នកគ្រូ ការកាត់បន្ថយភាពមិនប្រក្រតីនានានៅក្នុងសាលារៀន គឺបានអនុវត្តបានយ៉ាងល្អ ។ ប៉ុន្តែក្នុងនេះផងដែរការអនុវត្តការដឹកនាំ និងគ្រប់គ្រងនៅតាមសាលារៀនគោលដៅទាំងប្រាំពីរក្នុងរាជធានីភ្នំពេញក៏នៅមានការខ្វះចន្លោះមួយចំនួនផងដែរដូចជា ការអនុវត្តផែនការអធិការកិច្ចរបស់នាយក ឬនាយករងដែលជាអធិការអចិន្ត្រៃយ៍ នៅមានកម្រិតនៅឡើយសម្រាប់សាលាមួយចំនួន និងសាលាមួយចំនួនទៀតពុំបានអនុវត្តទាល់តែសោះ ។

៦. ធនធានមនុស្សនៅតាមសាលាគោលដៅទាំងប្រាំពីរក្នុងរាជធានីភ្នំពេញផ្នែកមធ្យមសិក្សាបឋមភូមិមិនទាន់បំពេញបានស្តង់ដានៅឡើយទេបើធៀបទៅនឹងស្តង់ដាសាលាមានប្រសិទ្ធភាព ។ បញ្ហាប្រឈមសាលាមួយចំនួនគឺនៅមានការខ្វះខាតគ្រូមុខវិជ្ជា និងមានការប្រើប្រាស់គ្រូបឋមសិក្សាមកធ្វើការបង្រៀននៅមធ្យមសិក្សាបឋមភូមិនៅឡើយ ។

៧. សៀវភៅសិក្សាគោល និងសម្ភាររៀន និងបង្រៀន នៅតាមសាលាគោលដៅទាំងប្រាំពីរក្នុងរាជធានីភ្នំពេញនៅមានកម្រិតទាបនៅឡើយដោយឃើញថាពិន្ទុនៃការចូលរួមវង្វាយតម្លៃមិនទាន់បំពេញបាននូវស្តង់ដាធៀបនឹងសាលាមានប្រសិទ្ធភាពនៅឡើយ ។ ក្នុងនេះយើងឃើញថាសាលានៅមានការខ្វះខាតលើបណ្ណាល័យដែលសាលាពុំទាន់មានបណ្ណាល័យស្តង់ដា ។

៨ . ហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថានសាលារៀនគោលដៅទាំងប្រាំពីរក្នុងរាជធានីភ្នំពេញគឺនៅមិនទាន់មានលក្ខខណ្ឌល្អប្រសើរនោះទេដោយមើលឃើញថាសាលារៀនមួយចំនួននៅ មានបរិស្ថានមិនទាន់ស្អាត មានការខ្វះខាតបន្ទប់សម្រាប់គ្រូស្នាក់នៅ មិនទាន់មានសង្ហារឹមគ្រប់គ្រាន់សម្រាប់បន្ទប់រដ្ឋបាលសាលារៀន បន្ទប់ទឹកសាលារៀនមិនមានស្តង់ដា និងមិនមានគ្រប់គ្រាន់ស្របតាមតម្រូវការរបស់សិស្ស ។

៩. ហិរញ្ញប្បទាន និងការគ្រប់គ្រងហិរញ្ញវត្ថុនៅតាមសាលារៀនគោលដៅទាំងប្រាំពីរក្នុងរាជធានីភ្នំពេញឃើញថាមានការអនុវត្តបានល្អប្រសើរដោយមើលឃើញថាការអនុវត្តលើ ហិរញ្ញប្បទាន និងការគ្រប់គ្រងហិរញ្ញវត្ថុគឺមានតម្លាភាព និងគណនេយ្យភាពបានល្អ ។

## ៥.២ សំណូមពរ

តាមរយៈការសិក្សាស្រាវជ្រាវនេះ យើងខ្ញុំយល់ថា ការអភិវឌ្ឍវិស័យអប់រំឱ្យមានគុណភាពតាម រយៈការអនុវត្តការគ្រប់គ្រងតាមសាលារៀន វាពិតជាមានសារៈសំខាន់ណាស់ សម្រាប់ លើកកម្ពស់គុណភាពអប់រំឱ្យកាន់តែមានភាពប្រសើរឡើង ។ ស្របជាមួយគ្នានេះដែរការសិក្សាស្រាវជ្រាវលើប្រធានបទ « ប្រសិទ្ធភាពនៃការអនុវត្តការគ្រប់គ្រងតាមសាលារៀននៅមធ្យមសិក្សាបឋមភូមិ » អ្នកស្រាវជ្រាវសង្កេតឃើញថាស្ថានភាពនៃការអនុវត្ត នៅតាមសាលារៀនគោលដៅទាំងប្រាំពីរក្នុងរាជធានីភ្នំពេញមិនទាន់បំពេញបានស្តង់ដានៅឡើយទេ បើធៀបនឹងស្តង់ដាប្រសិទ្ធភាពសាលារៀន ។ នៅក្នុងនេះផងដែរផ្នែកអំណានរបស់សិស្សនៅមានកម្រិតនៅឡើយ សិស្សត្រួតថ្នាក់ សិស្សបោះបង់នៅមានកម្រិតនៅឡើយ សម្រាប់កម្រិតមធ្យមសិក្សាបឋមភូមិ ខ្វះគ្រូឯកទេសផ្នែកព័ត៌មានវិទ្យា គ្រូមិនប្រើប្រាស់សម្ភារៈឧបទ្ទេសក្នុងម៉ោងបង្រៀន គ្រូប្រើប្រាស់កិច្ចតែងការក្នុងម៉ោងបង្រៀននៅមានកម្រិតនៅឡើយ សិស្សអវត្តមានក្នុងម៉ោងសិក្សានៅមានកម្រិតមធ្យម ក្លឹបសិក្សាពុំមានដំណើរការលើសេវាសិស្សជួយសិស្ស ខ្វះការចូលរួមជំរុញពីមាតាបិតាលើការសិក្សារបស់កូន ខ្វះការជំរុញសិស្សអោយប្រើប្រាស់បណ្ណាល័យ ប្រើប្រាស់បន្ទប់ពិសោធន៍ និងការប្រើប្រាស់កុំព្យូទ័រ ខ្វះការចុះពិនិត្យតាមដានរបស់ថ្នាក់លើក្នុងការអនុវត្តការគ្រប់គ្រងតាមសាលារៀនជាដើម ។ យើងខ្ញុំជាអ្នកសិក្សាស្រាវជ្រាវមានសំណូមពរមួយចំនួន ដែលពាក់ព័ន្ធនឹងស្ថានភាពការអនុវត្តការគ្រប់គ្រងតាមសាលារៀននៅមធ្យមសិក្សាបឋមភូមិ ។ សំណូមពរទាំងនោះមានដូចជា ៖

- ថ្នាក់ក្រសួងអប់រំ យុវជន និងកីឡា គួររៀបចំបើកវគ្គបណ្តុះបណ្តាលជំនាញគ្រប់គ្រងដល់នាយកសាលា នៅតាមវិទ្យាល័យឱ្យបានគ្រប់សាលា ពិសេសធ្វើឱ្យនាយកយល់កាន់តែច្បាស់ពីអត្ថន័យ និងអត្ថប្រយោជន៍នៃការគ្រប់គ្រងតាមបែបសាលារៀន ។

- ថ្នាក់ក្រសួងអប់រំ ថ្នាក់មន្ទីរអប់រំ ថ្នាក់ការិយាល័យអប់រំ ត្រូវចុះពិនិត្យតាមដានផ្ទាល់ លើការអនុវត្តការគ្រប់គ្រងតាមសាលារៀន មួយឆ្នាំពីរដង និងទៀតទាត់ សូមជៀសវាងរង់ចាំតែរបាយការណ៍ពីសាលារៀន ។

- ថ្នាក់ក្រសួងអប់រំ ថ្នាក់មន្ទីរអប់រំ គួរផ្តល់សិទ្ធអំណាចដល់នាយកក្នុងការស្នើសុំគ្រូបង្រៀនស្របតាមតម្រូវការរបស់សាលារៀនជាក់ស្តែងជៀសវាងការខ្វះគ្រូឯកទេស ។

- នាយកសាលារៀនគួរធ្វើការស្នើសុំថ្នាក់ក្រសួង មន្ទីរ ដៃគូរអភិវឌ្ឍ សហគមន៍សាលារៀនដើម្បីជួយសាងសង់អគារបណ្ណាល័យមានលក្ខណៈស្តង់ដាមានអាគារដាច់ដោយឡែកនៅក្នុងបរិវេណសាលារៀន ជៀសវាងយកបន្ទប់រៀនធ្វើជាបណ្ណាល័យ ។

- នាយកសាលារៀន ក៏ដូចជាគណៈកម្មការគ្រប់គ្រងសាលារៀនគួរតែមានការផ្សព្វផ្សាយពីកម្មវិធីការគ្រប់គ្រងតាម សាលារៀនអោយបានទូលំទូលាយ ដល់សហគមន៍ អាណាព្យាបាល មាតាបិតាសិស្សឱ្យពួកគាត់យល់កាន់តែច្បាស់ពីសកម្មភាព ព្រមទាំងតួនាទីរបស់ពួកគាត់ក្នុងការចូលរួមការអនុវត្តកម្មវិធីការគ្រប់គ្រងតាមសាលារៀននេះអោយបានច្បាស់ ។

- នាយក គ្រូបង្រៀន ត្រូវមានទំនាក់ទំនងល្អជាមួយអាណាព្យាបាល មាតាបិតាសិស្សក្នុងការគៀងគរសិស្សអោយចូលរៀន និងមករៀនអោយបានទៀងទាត់ និងត្រូវស្វែងរកមូលហេតុឱ្យបានច្បាស់លាស់សម្រាប់ការអវត្តមានរបស់សិស្ស និងការបោះបង់របស់សិស្ស ។

- នាយកសាលាត្រូវបង្កើនសកម្មភាពប្រជុំជាមួយអាណាព្យាបាលសិស្សរៀនយឺត ដើម្បីជំរុញការសិក្សាកូនៗរបស់ពួកគាត់ និងផ្តល់ព័ត៌មានអំពីការសិក្សារបស់សិស្សទៅកាន់សហគមន៍ជារៀងរាល់ខែ ។

- នាយកសាលារៀនត្រូវយកចិត្តទុកដាក់ខ្ពស់ក្នុងការចុះត្រួតពិនិត្យតាមដានធ្វើអធិការអេចិន្ត្រៃយ៍លើការបង្រៀន និងរៀនរបស់គ្រូសិស្សជាប្រចាំ ដោយមានផែនការច្បាស់លាស់ក្នុង ឆ្នាំសិក្សានីមួយៗ

- នាយកសាលារៀនត្រូវយកចិត្តទុកដាក់ក្នុងការបង្រៀនរបស់លោកគ្រូអ្នកគ្រូផ្នែកវិទ្យាសាស្ត្រដោយជំរុញអោយធ្វើការពិសោធន៍លើមេរៀនទាក់ទងការពិសោធន៍ និងរៀបចំកាលវិភាគសិស្សក្នុងការប្រើប្រាស់បណ្ណាល័យដើម្បីបង្កើនសមត្ថភាពអំណានរបស់សិស្សបន្ថែម ។

- នាយកសាលារៀនត្រូវបង្កើតក្លឹបសិក្សាក្នុងសាលារៀន និងជ្រើសរើសគ្រូជួយសិស្សរៀនយឺត និងសិស្សរៀនខ្សោយដើម្បីបំប៉នបន្ថែម ។

- អ្នកសិក្សាស្រាវជ្រាវជំនាន់ក្រោយ គួរតែពង្រឹងវិសាលភាពនៃការសិក្សាស្រាវជ្រាវបន្ថែមទៀត ជាពិសេស ភាគសំណាកឱ្យបានធំជាងនេះ សាលារៀន ស្រុក ខេត្ត នៅតាមតំបន់ជនបទ តំបន់ជួបការលំបាកជាដើម ។

# ឯកសារយោង


- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ។
- ក្រសួងអប់រំ យុវជន និងកីឡា២០១៥, ប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃផ្អែកលើលទ្ធផលអនុវិស័យមធ្យមសិក្សា, ទំ.៥១
- ក្រសួងអប់រំ យុវជន និងកីឡា២០១៨ សៀវភៅណែនាំប្រតិបត្តិស្តីពីការគ្រប់គ្រងតាមសាលារៀនគម្រោងកែលំអការអប់រំនៅមធ្យមសិក្សា, ទំ. ៥, ១១
- ក្រសួងអប់រំ យុវជន និងកីឡា, ផែនការយុទ្ធសាស្រ្តស្តីពីការអប់រំ២០១៤-២០១៨, ទំ.៣
- ក្រសួងអប់រំ យុវជន និងកីឡា, ការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផលឯកសារប្រតិបត្តិក្រុមប្រឹក្សាយុវជន និងកុមារ ២០១៧
- ក្រសួងអប់រំ យុវជន និងកីឡា, ការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផល ឯកសារប្រតិបត្តិគោលនយោបាយនិងនីតិវិធីគ្រប់គ្រងសាលារៀន ២០១៧
- Gamage, D. R. & Zajda, J. (2009). Decentralization and school-based governance: A Comparative study of self-governing school models. In Zajda, J. & Gamage, D. T. (Eds.) *Globalization, Comparative Education and Policy Research: Vol 8. Decentralization, School-Based Management, and Quality* (pp. 3-22). doi: 10.1007/978-90-481-2703-0
- Caldwell, B. J. (2009). Centralization and decentralization in education: A New Dimension to policy. In
- Zajda, J. & Gamage, D.T. (Eds.) *Globalization, Comparative Education and Policy Research: Vol 8. Decentralization, School-Based Management, and Quality* (pp. 53-66). doi: 10.1007/978-90-481-2703-0.
- Hong Hoklim, 2012. Crucial Factors Needed for Implementing School-Based Management in Cambodia:. Royal University of Phnom Penh.
- Sackney, L. E. & Dibski, D. J. (1995). School-based management: Will it fly? In Cheung, W.K. & Ming, C. K. (Eds), *Educational Leadership and Change: An International Perspectiv (29-42)*. Hong Kong: Hong Kong University Press.
- Malen, B., Ogawa, R. T., & Kranz, J. (1990). What do we know about site-based management: A case study of literature- A call for research. In Clune, W. H. & Witte, J. F. (Eds.), *Choice and Control in American Education Vol 2. The practice of choice, decentralization, and school restructuring* (pp. 289-342). London: The Falmer Press.
- Caldwell, B. J. (2009). Centralization and decentralization in education: A New Dimension to policy. In
- Zajda, J. & Gamage, D.T. (Eds.) *Globalization, Comparative Education and Policy Research: Vol 8. Decentralization, School-Based Management, and Quality* (pp. 53-66). doi: 10.1007/978-90-481-2703-0.
- Grauwe, A. D. (2005). Improving the quality of education through school-based management: Learning from international experiences. *Review of Education*, 51, 269-287.
- Wong, E. O. W. (2003). Leadership style for school-based management in Hong Kong. *The International Journal of Educational Management*, 17 (6), 243-247.
- Heun, Y. (2003 September). *Country report on school-based management in Hong Kong SAR*. Paper presented to The Third International Forum on Education Reform Education Decentralization Visited: School-Based Management, Bangkok.
- Shoraku, A. (2008). *Educational movement toward school-based management in East Asia: Cambodia, Indonesia, and Thailand*. Paper commissioned for the EFA Global Monitoring Report, 2009, Overcoming Inequality: why government matters. Retrieved July 25, 2010 from http://unesdoc.unesco.org/images/0017/001787/178720e.pdf
- Indriyanto, B. (2003 September). *School-based management: Issues and hopes toward*

*decentralization in education in Indonesia*. Paper presented to The Third International Forum on Education Reform Education Decentralization Visited: School-Based Management, Bangkok.
- Guzman, A. B. D. (2003, September). *School-based management in Philippines basic and higher education sectors: Rationale, practices and policy directions*. Paper presented to The Third International Forum on Education Reform Education Decentralization Visited: School-Based Management, Bangkok.
- Santibanez, L. (2006). *School-based management effects on educational outcomes: A literature review and assessment of the evidence base*. Washington D.C.: The World Bank.
- Gertler, P., Patrinos, H. A. & Rubio-Codina, M. (2007). *Methodolical issues in the evaluation of school-based management reforms*. Washington D.C.: The World Bank.
- Candoli, I.C. (1995). *Site-based management in education*: *How to make it work in your school*. Lancaster, Britain: Technomic Publishing Co.
- Wong, E.O.W. (2003). Leadership style for SBM in Hong Kong.*The International Journal of Educational Management*, 17(6/7), 243-247.
- Duhou, I.A. (1999). *School-based management*: *Fundamentals of educational planning*. Paris: UNESCO: International Institute for Educational Planning.
- McGinn, N., & Welsh, T. (1999).*Decentralisation of education: Why, when, what and how?* Paris: France, UNESCO: International Institute for Educational Planning.
- Pellini, A. (2007). *Decentralisation Policy in Cambodia.* Finland: University of Tampere.
- Ministry of Education, Youth and Sport (2002a).*Cluster School Guidelines*, Phnom Penh: Cambodia, Ministry of Education, Youth and Sport.
- Bredenberg, K. (20002). *Cluster School Development: Analysis of Process and Outcomes*, Phnom Penh: UNICEF/Sida
- Ministry of Education, Youth and Sport (2000).*Education strategic plan 2001-2005*. Phnom Penh: Cambodia, Ministry of Education, Youth and Sport.
- Yukl, G. (1989). Managerial leadership: A review of theory and research. Journal of management, 15(2),251-289
- Hollander, E.P ., & Offermann, L. R. (1990). Power and leadership in organiqations: Relationships in transition. American psychologist, 45(2), 179.
- Ekvall, G., &Arvonen, J. (1991). Change-centered leadership: An extension of the two-Dimensional model. Scandinavian Journal of Management, 7(1), 17-26
- Keller, R. T. (2006). Transformational leadership, initiating structure, and substitutes for leadership: A longitudinal study of research and development project team performance. Journal of applied pshychology, 91(1), 202.
- Spillane, J. P., Halverson, R., & Diamond, J. B. (2004). Towards a theory of leadership practice: A distributed perspective. Journal of curriculum studies, 36(1), 3-34.
- Maxwell, J. C. (2007). The 21 indispensable qualities of a leader: Becoming the person others will want to follow. Thomas Nelson Inc.

# ឧបសម្ព័ន្ធ១

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានជាតិអប់រំ

# កម្រងសំណួរសម្រាប់សម្ភាសគ្រូ

## ក. កម្រងសំណួរទម្រង់បិទ

ខ្ញុំបាទឈ្មោះ **ហ៊ែល ម៉ូណូ** ជានិសិត្សថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦ នៃវិទ្យាស្ថានជាតិអប់រំ បាននឹងកំពុងធ្វើការសិក្សាស្រាវជ្រាវ ដើម្បីសរសេរសារណាមួយក្រោមប្រធានបទ ៖ "**ប្រសិទ្ធភាពនៃការអនុវត្តការគ្រប់គ្រងតាមសាលារៀន (SBM) នៅមធ្យមសិក្សាបឋមភូមិក្នុងរាជធានីភ្នំពេញ**" ដើម្បីបញ្ចប់ឆ្នាំសិក្សាបរិញ្ញាប័ត្រជាន់ខ្ពស់ផ្នែក គ្រប់គ្រងអប់រំនៃវិទ្យាស្ថានជាតិអប់រំ ។

ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះលោក លោកស្រី នាយក នាយិកា លោកគ្រូ/អ្នកគ្រូ ទាំងអស់ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការឆ្លើយកម្រងសំណួរ របស់ខ្ញុំបាទ ។ សូមលោក លោកស្រី លោកនាយក នាយិកា លោកគ្រូ/អ្នកគ្រូ មេត្តាជួយគូស សញ្ញា ✓ ឬឆ្លើយសំណួរខាងក្រោម

កម្រងសំណួរនេះបែងចែកជាពីរផ្នែករួមមាន ៖

១. ស្ដីពីព័ត៌មានស្ថានភាពទូទៅរបស់លោកគ្រូ/អ្នកគ្រូ

២. ស្ដីពីប្រសិទ្ធភាពនៃការអនុវត្តការគ្រប់គ្រងតាមបែបសាលារៀន (SBM)

**ផ្នែកទី១** ៖ ព័ត៌មានអំពីស្ថានភាពទូទៅរបស់លោកគ្រូ-អ្នកគ្រូ ។

ការស្ទង់មតិនេះត្រូវបានធ្វើឡើងដើម្បីសិក្សាអំពីការអនុវត្តការគ្រប់គ្រងសាលាតាមរៀន (SBM) នៅមធ្យមសិក្សាក្នុងរាជធានីភ្នំពេញ ។ សូមមេត្តាបំពេញចម្លើយ ឬគូសសញ្ញា (✓) ក្នុងប្រអប់ □ ដែលត្រូវជាមួយនឹងស្ថានភាពទូទៅរបស់លោកគ្រូ-អ្នកគ្រូ ។

ព័ត៌មានប្រជាសាស្ត្រ

១. ឈ្មោះវិទ្យាល័យ..........................................................ខណ្ឌ......................................

២. ភេទ □ ប្រុស □ ស្រី

៣. កម្រិតវប្បធម៌

1.□ ទាបជាងបរិញ្ញាបត្រ 2.□ បរិញ្ញាបត្រ

3.□ បរិញ្ញាបត្រជាន់ខ្ពស់ 4.□ បណ្ឌិត

៤. ប្រភេទសមាជិករបស់អ្នក

1.□ នាយក 2.□ គ្រូបង្រៀន

3.□ សហគមន៍ 4.□ គណៈកម្មការគ្រប់គ្រងសាលារៀន

5.□ អាជ្ញាធរដែនដី 6.□ សិស្ស

